ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ហ្វ្រាហា ហាមីដ រចនាប្លង់វិទ្យាស្ថានស្លឹករឹត

◆ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលគឺជាអ្វី?

រូបផ្នែកខាងក្រោម អ.វ.ត.ក

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦៦ ខែតុលា ឆ្នាំ២០១៣

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៦៦ ខែតុលា ឆ្នាំ២០១៣

## មាតិកា

◆ ហ្សាហា ហាឌីជ រចនាប្លង់វិទ្យាស្ថានស្លឹករឹត ....................................១

◆ តើអ្វីជាកិច្ចការបន្ទាប់សម្រាប់សាលាក្តីខ្មែរក្រហម? ...........................៥

**ផ្នែកឯកសារ**

◆ បទខ្ទេសនាមរបស់សមមិត្តគំណាង ...............................................៦

◆ ចម្លើយសារភាពរបស់ នួន រឿន ហៅ ទៀង ..............................១៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ទំនាក់ទំនងផ្នែកនយោបាយរវាងកម្ពុជាប្រជាធិបតេយ្យ .....................២០

◆ អតីតកងជីវពលខ្មែរក្រហមចង់ឲ្យតុលាការ .....................................២៨

◆ ទិម យ៉ុង : ជីវិតមិនអាចដូចដើមក្រោយរបប ................................៣០

**ផ្នែកច្បាប់**

◆ កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌល ..........................................៣៣

◆ អ្វីទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ? .........................................៣៧

◆ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ................................៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ ជនសង្ស័យក្នុងសំណុំរឿង០០៤មិនត្រូវបានអនុញ្ញាត .......................៤៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ទណ្ឌិតផ្លែល្ហុ .......................................................................៤៨

◆ ទិដ្ឋភាពសោកសៅនៅជិវិជនភៀសខ្លួន..........................................៥៧




នួន ជា កំពុងថ្លែងសុន្ទរកថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ



## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** : អាន ហាញ្ញុឌល, ទី លីកូ, រ៉េនឌល ឌីហ្វាល់កូ, ម៉ែន ពិចិត្រ, លន់ ដាលីន, លឹម ជ័យទ័ត្ត, វ៉ាន់ថាន់ ពៅដារ៉ា, ឆាយ ស៊ូឆាត្រ, លីន ចយ ***អ្នកនិពន្ធនិងស្រាវជ្រាវ*** : ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា ***អ្នកបកប្រែ*** : នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត ***និពន្ធនាយកទូទៅ*** : ឆាំង យុ និង ញាណ សុជាតិ ***ជំនួយការនិពន្ធនាយក*** : សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ*** : សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ*** : ផេង ពង្ស Email: dccam@online.com.kh,

Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ហ្សាហា ហាឌីដ រចនាប្លង់វិទ្យាស្ថានស្លឹករឹត

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និង លោកស្រី ហ្សាហា ហាឌីដ ប្រកាសអំពីការតែងក្រុមហ៊ុនរបស់ លោកស្រី ហ្សាហា ហាឌីដ ដើម្បីរចនាប្លង់ថ្មីរបស់វិទ្យាស្ថានស្លឹករឹត ដែលជា អនាគតការិយាល័យអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ក្នុងគោលបំណងចងក្រងពីអំពើឃោរឃៅដែលបានកើត ឡើងក្នុងរបបខ្មែរក្រហម ។ នៅក្នុងបណ្ណសារដែលមានជាងមួយ លានឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាបានកសាងកេរឈ្មោះ ជាអ្នកនាំមុខគេក្នុងការស្វែងរកឲ្យមានការចងចាំ និងយុត្តិធម៌ ។ ក្នុងន័យនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងមិនត្រឹម តែចងក្រងពីរឿងរ៉ាវដ៏ខ្លោចផ្សានៃប្រវត្តិសាស្ត្រកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងខ្នះខ្នែងជួយប្រទេសជាតិមួយនេះឲ្យសះស្បើយពី បញ្ហាផ្សេងៗ ។

វិទ្យាស្ថានស្លឹករឹតថ្មីនឹងក្លាយជាមជ្ឈមណ្ឌលនាំមុខគេសម្រាប់ សិក្សាស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍ នៅអាស៊ីជាវិទ្យាស្ថានមួយដើម្បីបន្តចងក្រង ឯកសារ វិភាគ និងថែរក្សាព័ត៌មានទាក់ទង ទៅនឹងសម័យខ្មែរក្រហម ។ កន្លែងសម្រាប់ក សាងវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងនៅជិត បណ្ណាល័យសាធារណៈថ្មីមួយ និងសាលាច្បាប់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងទីក្រុងភ្នំពេញ ត្រូវ បានផ្តល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០០៨ ។



ប័ណ្ណផ្សព្វផ្សាយបង្ហាញអំពីក្រុមហ៊ុន ហ្សាហា ហាឌីដ រចនាប្លង់ថ្មីរបស់វិទ្យាស្ថានស្លឹករឹត

ការជ្រើសរើសយកក្រុមហ៊ុន ហ្សាហា ហាឌីដ ដែលជាក្រុមហ៊ុនមួយមានភាពល្បីរន្ទឺ ខាងការរចនាប្លង់ស្ថាបត្យកម្ម ឆ្លុះបញ្ចាំងពី សេចក្តីសម្រេចរបស់មជ្ឈមណ្ឌលឯកសារ កម្ពុជាដើម្បីបំបែកនូវគំរូស្ថាបត្យកម្មនៃការ ចងចាំដែលតែងតែទោទន់ទៅរកការបង្ហាញ តែភាពងងឹតនិងការឈឺចាប់ជិះជាន់ ។

លោក ឆាំង យុ បានមានប្រសាសន៍ ថា "ទោះបីជាមានផលលំបាកជាអវិជ្ជមាន មាននៅចំពោះមុខក៏ដោយ វិទ្យាស្ថានស្លឹករឹត មិនបានឆ្លុះបញ្ចាំងទិសដៅ និងគោលបំណង

ក្នុងការបង្កើតទីកន្លែង ដើម្បីឲ្យមានការចងចាំជនរងគ្រោះនៃរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាទេ ។ ទស្សនវិស័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជានិច្ចជាកាលចងចាំរឿងរ៉ាវកាលពីអតីតកាល ប៉ុន្តែក្នុងពេលជាមួយគ្នានោះដែរ ក៏សម្លឹងទៅរកអនាគតដោយផ្តល់ឲ្យមានបទពិសោធសុទិដ្ឋិនិយមមួយឆ្លុះបញ្ចាំងពីមហិច្ឆតា និងសេចក្តីប្រាថ្នាចង់បានរបស់ជាតិទាំងមូល ។ វិទ្យាស្ថានស្លឹករឹតនិងសម្របសម្រួលទៅតាមរបៀបដែលសមទៅនឹងវិស័យឯកទេសនៃស្ថាបត្យកម្មរំឭកការចងចាំដែលធ្វើឲ្យមានបទពិសោធដ៏ច្បាស់លាស់ មិនបង្ហាញពីភាពឃោរឃៅប៉ុន្នោះទេ តែបង្ហាញពីគុណភាពនិងបទពិសោធរបស់អ្នកទស្សនាជាមួយនឹងភាពសុទិដ្ឋិនិយមដែលសម្លឹងទៅរកអនាគត ។ ស្ថាបត្យកម្មដែលមានលក្ខណៈប្លែក តែបង្ហាញពីអំណាចឋាមពលរបស់ក្រុមហ៊ុន ហ្សាហា ហាឌីដ ផ្តោតទៅលើការរចនាប្លង់មានលក្ខណៈដូចបន្ទាត់កោង ។ ក្រុមហ៊ុន ហ្សាហា ហាឌីត មានសក្តានុពល ក្នុងការកែប្រែការរចនាប្លង់នៃស្ថាបត្យកម្មតាមបែបរំឭក ការចងចាំក្នុងទិសដៅថ្មីស្រឡាងទាំងស្រុង និងសម្បូរបែប» ។

លោកស្រី ហ្សាហា ហាឌីត ក៏បានមានប្រសាសន៍ដែរថា «ទស្សនវិស័យរបស់លោក ឆាំង យុ មានលក្ខណៈបណ្តុះគំនិតខ្លាំងណាស់ ។ វិទ្យាស្ថានស្លឹករឹតថ្មីរបស់គាត់ទាមទារឲ្យមានសម្រស់ និងសុទិដ្ឋិនិយមសម្រាប់អនាគត ដើម្បីធ្វើឲ្យជាសះស្បើយរបួស និងផ្សារភ្ជាប់ប្រទេសកម្ពុជាឡើងវិញ ដែលមានមជ្ឈមណ្ឌលឯកសារកម្ពុជាជាគន្លឹះដ៏សំខាន់ក្នុងការសម្រេចការងារនេះ ។ ដោយធ្វើការជាមួយ លោក ឆាំង យុ និងវិទ្យាស្ថានស្លឹករឹត យើងបានរួមគ្នាបង្កើតឲ្យមានក្រុមការងារពិសេសមួយ រួមមានក្រុមប្រឹក្សាកម្ពុជា និងអន្តរជាតិដែលបានចែករំលែកទស្សនវិស័យទៅវិញទៅមកដើម្បីរចនាប្លង់វិទ្យាស្ថានស្លឹករឹតដោយស្មារតីប្រុងប្រយ័ត្នជាទីបំផុត ។ កេរដំណែលវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជា រួមមាន ប្រាសាទបុរាណដ៏អស្ចារ្យគ្មានពីរលើលោកដែលឆ្លុះបញ្ចាំងអំពីស្ថាបត្យកម្ម និងបច្ចេកវិទ្យាដ៏វិសេសវិសាលកាលពីសម័យបុរាណ ។ ក្រុមហ៊ុន ហ្សាហា ហាឌីត ចង់ធ្វើការជាមួយលោក ឆាំង យុ និងក្រុមការងាររបស់លោកនៅថ្ងៃអនាគតទៅមុខទៀត ដើម្បីធ្វើឲ្យទស្សនវិស័យរបស់លោកចេញជារូបរាងឡើងនៅក្នុងអគារដ៏ទំនើបមួយដែលរំឭក និងចងចាំអតីតកាល តែក៏ឆ្លុះបញ្ចាំងអំពីជំនឿឥតងាករេ និងសុទិដ្ឋិនិយមសម្រាប់អនាគតតាមរយៈការប្រើប្រាស់វិស័យអប់រំ ការយោគយល់គ្នា និងការបណ្តុះគំនិតដើម្បីផ្សារភ្ជាប់អ្នកមកទស្សនាក្នុងលក្ខណៈវិជ្ជមាន» ។

លោកស្រី ហ្សាហា ហាឌីត បានបន្តទៀតថា «អ្នកមកទស្សនាទីក្រុងភ្នំពេញអាចរៀនសូត្រអំពីកេរដំណែលខ្លោចផ្សាររបស់ខ្មែរក្រហម ដោយចងចាំជនរងគ្រោះថាជាមនុស្សជាតិដែលបានជាប់ខ្លួននៅក្នុងការវិលវល់នៃសង្គ្រាម មនោគមន៍វិជ្ជាជ្រុលនិយម និងភាពមិនសមហេតុសមផល ។ វិទ្យាស្ថានស្លឹករឹតថ្មីនឹងផ្តោតទៅលើការធ្វើឲ្យប្រាកដថា នឹងមិនមានការងើបឡើងវិញនៃលក្ខខណ្ឌលំបាកដូចដែលបានកើតឡើងកាលពីអតីតកាលទៀតទេតាមរយៈកម្មវិធីបង្រៀនពីប្រវត្តិសាស្ត្រ ។ អ្នកទស្សនាក៏និងអាចរៀនសូត្រអំពីរបៀបដែលតម្លៃនៃចំណេះដឹង ការអភ័យទោស និងផ្សះផ្សាជាតិ និងការយោគយល់ ផ្តល់ជាមធ្យោបាយសម្រាប់ភ្ជាប់ខ្លួនទៅនឹងអនាគតប្រកបដោយភាពវិជ្ជមាននិងផ្លែផ្កាជាងមុន ។ អ្នកទស្សនាក៏និងរៀនសូត្រអំពីរបៀបដាក់ព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីអតីតកាលបញ្ចូលទៅក្នុងបុព្វបទថ្មីនិងធំទូលាយជាងមុននៃប្រវត្តិសាស្ត្រដ៏វែងឆ្ងាយរបស់កម្ពុជា» ។

លោក ឆាំង យុ និងលោកស្រី ហ្សាហា ហាឌីត គិតទុកជាមុនរួចស្រេចហើយថា សម្រស់និងនិមិត្តរូបរបស់វិទ្យាស្ថានស្លឹករឹតថ្មីនិងស្របទៅនិងទស្សនវិស័យរបស់វិទ្យាស្ថាននេះ ហើយនេះគឺជាគម្រោងមួយដែលនិងបម្រើដល់ការស្ថាបនា និងពង្រឹងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសព្វថ្ងៃ បង្កើនឲ្យមានការយល់ដឹងដល់សាធារណជន និងបង្កើតការយោគយល់ និងស្វែងរកផលប្រយោជន៍សង្គមនៃការផ្សះផ្សាជាតិតាមរយៈការអប់រំ ការមុជរកចំណេះដឹង និងធ្វើឲ្យមានភាពជិតស្និទ្ធ ដោយផ្អែកទៅលើការចងចាំនិងការផ្តល់ជូនផ្សេងៗ ។

លោក ឆាំង យុ និងសហការីរបស់លោកបានសម្តែងនូវមោទកភាពនិងការដឹងគុណយ៉ាងជ្រាលជ្រៅដល់លោកស្រី ហ្សាហា ហាឌីត និងក្រុមរចនាប្លង់របស់លោកស្រីដែលបានចូលរួមក្នុងការស្ថាបនាប្លង់វិទ្យាស្ថានស្លឹករឹតនេះ ។

## ប្រវត្តិសង្ខេប ឆាំង យុ

លោក ឆាំង យុ គឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នករស់រានមានជីវិតពីរបប "វាលពិឃាត" ខ្មែរក្រហម ។ លោកបានក្លាយជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ១៩៩៥ នៅពេលដែលមជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងក្នុងនាមជាការិយាល័យមួយរបស់សកលវិទ្យាល័យយែលនៃកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ដើម្បីធ្វើការសិក្សាស្រាវជ្រាវ បណ្ដុះបណ្ដាល និងចងក្រងឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ លោក ឆាំង យុ បន្តដឹកនាំមជ្ឈមណ្ឌលឯកសារកម្ពុជាបន្ទាប់ពីមជ្ឈមណ្ឌលនេះក្លាយជាអង្គការក្រៅរដ្ឋាភិបាលឯករាជ្យមួយ នៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៧ ហើយបច្ចុប្បន្ននេះ កំពុងតែធ្វើការកសាងលើកិច្ចការរបស់មជ្ឈមណ្ឌលនេះឲ្យទៅជាវិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលនាំមុខមួយសម្រាប់ការសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅអាស៊ី ដែលមានមូលដ្ឋាននៅក្នុងរាជធានីភ្នំពេញ ។


ឆាំង យុ

មុនបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ បានធ្វើការទាក់ទងទៅនឹងការបណ្ដុះបណ្ដាលលើបញ្ហាសិទ្ធិមនុស្ស និងប្រជាធិបតេយ្យនៅប្រទេសកម្ពុជាសម្រាប់វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក និងជាមន្ត្រីផ្នែកអន្តរជាតិក្នុងការជួយចាត់ចែងកិច្ចការបោះឆ្នោតរបស់អាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) ។

ពីឆ្នាំ១៩៨៩ដល់១៩៩២ លោកធ្វើការទាក់ទងទៅនឹងការទប់ស្កាត់បទឧក្រិដ្ឋកម្មក្នុងទីក្រុងដាឡាស់ រដ្ឋតិចសាស់ ។ លោក ឆាំង យុ ក៏ជាអ្នកស្រាវជ្រាវជាន់ខ្ពស់អំពីអំពើប្រល័យពូជសាសន៍នៅឯមជ្ឈមណ្ឌលស្ដីពីការសិក្សាអំពើប្រល័យពូជសាសន៍ ការដោះស្រាយជម្លោះ និងសិទ្ធិមនុស្សនៅឯសាកលវិទ្យាល័យរ៉ាត់ហ្គ័រ សហរដ្ឋអាមេរិក ។ លោកក៏ជាសមាជិកក្រុមដ៏ឆ្នើមមួយរូបដែលបានស្ថាបនាវិទ្យាស្ថានស៊ើបអង្កេតព្រហ្មទណ្ឌអន្តរជាតិ *(Institute for International Criminal Investigations)* នៅទីក្រុងឡាអេ ប្រទេសហូឡង់ ហើយក៏ជាសមាជិកគ្រប់គ្រងនៃក្រុមហ៊ុនAir Asia ដែរ ។

លោក ឆាំង យុ ក៏ជាអ្នកសរសេរអត្ថបទ និងកថាខណ្ឌនៅក្នុងសៀវភៅជាច្រើនទាក់ទងទៅនឹងការស្វែងរកការពិត ការចងចាំ និងយុត្តិធម៌របស់ប្រទេសកម្ពុជា និងជាសហនិពន្ធសៀវភៅ "ស្នាកស្នាមរបួសរបស់កម្ពុជា ៖ ការប៉ះទង្គិចផ្លូវចិត្តបន្ទាប់ពីរបបខ្មែរក្រហម" ដែលត្រូវបានបោះពុម្ពនៅឆ្នាំ២០១១ ។

លោកក៏ជានាយកផលិតកម្មខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "ក្បង់ទឹកទន្លេ" ផលិតឡើងឆ្នាំ២០១២ ស្ដីអំពីការប្រែប្រួលបរិយាកាសសង្គម សេដ្ឋកិច្ច និងបរិស្ថាន នៅក្នុងប្រទេសកម្ពុជា ។ ខ្សែភាពយន្តនេះ ទទួលបានពានរង្វាន់ភាពយន្តពិភពលោក នៅមហោស្រពសាន់ឌេន នៅសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ២០១៣ នៅក្នុងចំណោមពានរង្វាន់ជាច្រើនទៀត ។

លោក ឆាំង យុ បានទទួលពានរង្វាន់សេរីភាពប្រធានាធិបតីសហរដ្ឋអាមេរិក ទ្រូមេន-រីហ្គេន ពីមូលនិធិចងចាំជនរងគ្រោះនៃរបបកុម្មុយនីស្ត នៅក្រុងវ៉ាស៊ីនតោនឌីស៊ី ក្នុងឆ្នាំ២០០០ ។ លោកបានជាប់ជាមនុស្សមួយរូបក្នុងចំណោមវីរជននៅអាស៊ីចំនួន៦០រូប របស់ទស្សនាវដ្ដី "ថៃមស៍" ក្នុងឆ្នាំ ២០០៦ និងជាមនុស្សមួយរូបក្នុងចំណោមមនុស្ស១០០នាក់ ដែលមានឥទ្ធិពលបំផុតនៅក្នុងពិភពលោកក្នុងឆ្នាំ២០០៧ ចំពោះជំហររបស់លោកក្នុងការប្រឆាំងទៅនឹងនិទ្ទណ្ឌភាពនៅក្នុងប្រទេសកម្ពុជា អ៊ីរ៉ាក់ ភូមា និងស៊ីរី ។

## ហ្សាហា ហាឌីដ

លោកស្រី ហ្សាហា ហាឌីដ ដែលជាស្ថាបនិកក្រុមហ៊ុនស្ថាបត្យកម្ម ហ្សាហា ហាឌីដ ត្រូវបានប្រគល់ពានរង្វាន់ស្ថាបត្យកម្ម

ប្រាយស៍គើ *(Pritzker Architecture Prize)* ដែលអាចចាត់ទុកថាជាពានរង្វាន់ណូបែលស្ថាបត្យកម្មកាលពីឆ្នាំ២០០៤ ហើយលោកស្រីក៏ទទួលបាននូវភាពល្បីរន្ទឺជាអន្តរជាតិ ចំពោះការសិក្សាទ្រឹស្តី និងការស្ថាបនាអគាររកន្ទងមករបស់លោកស្រី ។ គម្រោងសិក្សា និងគម្រោងដែលបង្កើតមុនគេបង្អស់របស់លោកស្រីស្ថាបនាឡើងក្រោមការរុករកនិងស្រាវជ្រាវអស់រយៈពេលជាងសាមសិបឆ្នាំ នៅក្នុងវិស័យនគររូបនីយកម្ម ស្ថាបត្យកម្ម និងការរចនាប្លង់ ។

មានកំណើតនៅទីក្រុងបាដាត ប្រទេសអ៊ីរ៉ាក់ ក្នុងឆ្នាំ១៩៥០ លោកស្រី ហ្សាហា ហាឌីដ ចូលសិក្សាផ្នែកគណិតវិទ្យានៅសាកលវិទ្យាល័យអាមេរិកាំងបេរូត ប្រទេសឡេបាណន់ មុននឹងលោកស្រីធ្វើដំណើរទៅទីក្រុងឡុនដុន ក្នុងឆ្នាំ១៩៧២ ដើម្បីរៀននៅសាលាសមាគមស្ថាបត្យកម្ម ជាកន្លែងដែលលោកស្រីទទួលសញ្ញាបត្រ ក្នុងឆ្នាំ១៩៧៧ ។ លោកស្រីបានបង្កើតក្រុមហ៊ុនស្ថាបត្យកម្ម ហ្សាហា ហាឌីដ ក្នុងឆ្នាំ១៩៧៩ ហើយបានបញ្ចប់ការគូប្លង់លើកដំបូងរបស់គាត់គឺស្ថានីយ៍ពន្លត់អគ្គីភ័យវីត្រា នៅប្រទេសអាឡឺម៉ង់ ក្នុងឆ្នាំ១៩៩៣ ។


ហ្សាហា ហាឌីដ

លោកស្រី ហ្សាហា ហាឌីដ បានបង្រៀននៅសាលាសមាគមស្ថាបត្យកម្ម រហូតដល់ឆ្នាំ១៩៨៧ ហើយចាប់តាំងពីពេលនោះមក លោកស្រីបានកាន់មុខនាទីជាប្រធានការិយាល័យជាច្រើន និងជាភ្ញៀវពិសេសដែលត្រូវបានអញ្ជើញទៅបង្រៀននៅសាកលវិទ្យាល័យជាច្រើនទូទាំងពិភពលោក ។ នាពេលបច្ចុប្បន្ននេះ លោកស្រី ហ្សាហា ហាឌីដ គឺជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យសិល្បៈអនុវត្តនៅទីក្រុងវៀនណា ប្រទេសអូទ្រីស និងជាសាស្ត្រាចារ្យសម្រាប់វគ្គខ្លី ផ្នែករចនាប្លង់ស្ថាបត្យកម្មនៅសាកលវិទ្យាល័យយែល សហរដ្ឋអាមេរិក ។

ម៉ាក់ស៊ី *The MAXXI* ៈ សារមន្ទីរជាតិសិល្បៈសតវត្សរ៍ទី២១ នៅក្នុងទីក្រុងរ៉ូម ប្រទេសអ៊ីតាលី និងមជ្ឈមណ្ឌលកីឡាក្នុងទឹក នៅទីក្រុងឡុនដុនដែលសាងសង់ឡើងសម្រាប់កីឡាអូឡាំពិកកាលពីឆ្នាំ២០១២ គឺជាស្នាដៃដ៏វិសេសវិសាលរបស់ក្រុមហ៊ុន ហ្សាហា ហាឌីដ ចំពោះសំណង់អគារដ៏អស្ចារ្យ និងរស់រវើក ។ សំណង់ដែលធ្លាប់រចនារួចមកហើយមានដូចជាមជ្ឈមណ្ឌលសិល្បៈទំនើបរ៉ូសង់តាល់ នៅក្នុងទីក្រុងស៊ីនស៊ីណាទី រដ្ឋអូហាយូ និងសាលមហោស្រពហ្គងហ្សូ នៅប្រទេសចិន ត្រូវបានចាត់ទុកថាជាស្ថាបត្យកម្មមួយដែលសម្លឹងទៅរកអានាគត ជាមួយនឹងគំនិតនិងថាមពលអវកាស និងមានរូបរាងដែលមានទស្សនវិស័យវែងឆ្ងាយ ។

ការរួមចំណែកដ៏អស្ចារ្យរបស់លោកស្រី ហ្សាហា ហាឌីដ ទាក់ទងទៅនឹងឯកទេសស្ថាបត្យកម្ម ត្រូវបានបន្តទទួលស្គាល់ថាជាវិទ្យាស្ថានដែលគួរគោរពជាទីបំផុតក្នុងពិភពលោកក្នុងចំណោមអ្នកដែលគួរកោតសរសើរបំផុតលើលោក រួមមានស្ត្រីដែលមានឥទ្ធិពលបំផុតលើលោករបស់ទស្សនាវដ្តី *Forbes* និងសមាគមសិល្បៈជប៉ុនដែលបានជូនដល់លោកស្រីនូវពានរង្វាន់ *Praemium Imperial* ដែលជាពានរង្វាន់វប្បធម៌ពិភពលោក ។ ក្នុងឆ្នាំ២០១០ និង២០១១ ការរចនាប្លង់របស់លោកស្រីទទួលបានពានរង្វាន់ *Stirling Prize* ដែលជាពានឧត្តុង្គឧត្តមធំបំផុតសម្រាប់វិស័យស្ថាបត្យកម្ម ដោយរាជវិទ្យាស្ថានស្ថាបត្យករ ចក្រភពអង់គ្លេស ។ ពានរង្វាន់ថ្មីផ្សេងទៀតដែលលោកស្រី ហ្សាហា ហាឌីដ ទទួលបាន រួមមាន អង្គការ *UNESCO* បានប្រសិទ្ធនាមលោកស្រី ហ្សាហា ហាឌីដ ថាជា «សិល្បករសន្តិភាព» , សាធារណរដ្ឋបារាំងបានផ្តល់កិត្តិនាមដល់លោកស្រីថា « *Commandeur de l'Ordre des Arts et des Lettres* » , ទស្សនាវដ្តីថៃមស៍បានដាក់លោកស្រីថាជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលមានឥទ្ធិពលបំផុតទាំង១០០នាក់លើលោក ហើយក្នុងឆ្នាំ២០១២ លោកស្រី ហ្សាហា ហាឌីដ ទទួលងារជា *Dame Commander of the Order of the British Empire* ដោយម្ចាស់ក្សត្រីអេលីហ្សាប៉ែត២របស់ចក្រភពអង់គ្លេស ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# តើអ្វីជាកិច្ចការបន្ទាប់សម្រាប់សាលាក្តីខ្មែរក្រហម?

ដោយសារតែពេលនេះ សវនាការសំណុំរឿងទីពីរនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឈានដល់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ហើយ វានៅតែជារឿងមិនទាន់ច្បាស់នៅឡើយត្រង់ថាតើសាលាក្តីមួយនេះអាចនិងបន្តកិច្ចដំណើរការក្នុងករណីបន្តបន្ទាប់ទៀតដែរឬក៏អត់ រួមទាំងកិច្ចដំណើរការរឿងបទចោទប្រកាន់ថ្មីបន្ថែមប្រឆាំងនិងអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នួន ជា និង ខៀវ សំផន ឬបទចោទប្រកាន់ថ្មីបន្ថែមទៀតចំពោះជនសង្ស័យដែលនៅរស់រានមានជីវិតក្នុងករណី០០៣ និង០០៤ ។ ឆន្ទៈនិងបញ្ហាថវិកាតិចតួចអាចធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបន្តកិច្ចដំណើរការទៅមុខទៀតបាន ។

ទោះជាមានហេតុការណ៍អ្វីកើតឡើងក៏ដោយ ដំណើរការកាត់ទោសនៅសាលាក្តីខ្មែរក្រហមអាចនឹងធ្វើឲ្យកក្កូកកាយរឿងរ៉ាវដែលគួរឲ្យទិតៀនចំពោះសម័យកាលដ៏រន្ធត់នៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនគួរបញ្ចប់នូវការស្វែងរកការទទួលខុសត្រូវផ្លូវច្បាប់ និងការពិតទេ ។ ប្រជាជនកម្ពុជាបានឆ្លងកាត់ដំណាក់កាលនិងធ្វើកិច្ចការជាច្រើនរួចមកហើយដើម្បីទទួលបាននូវភាពយុត្តិធម៌និងការបង្រួបបង្រួមជាតិក្នុងរយៈកាលជាង៣០ឆ្នាំកន្លងទៅនេះ ហេតុដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនជាដំណើរការស្វែងរកយុត្តិធម៌និងការបង្រួបបង្រួមជាតិលើកតំបូងទេ ហើយក៏មិនមែនជាដំណើរការចុងក្រោយដែរ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារទាក់ទងនឹងរបបខ្មែរក្រហមនិងរឿងរ៉ាវរបស់អ្នកដែលរួចរស់ជីវិតពីរបបនេះរាប់សែនទំព័រ ដែលអនុញ្ញាតឲ្យសិស្ស-និស្សិត គ្រូបង្រៀន មេធាវី និងអ្នករួចរស់ជីវិតពីរបបខ្មែរក្រហមចូលស្រាវជ្រាវរកមើលថាតើអ្វីខ្លះបានកើតឡើងកាលពីរបបកម្ពុជាប្រជាធិបតេយ្យ និងតើកើតឡើងដោយសារមូលហេតុអ្វី ។ បណ្ណសារទាំងនេះគឺជាកេរដំណែលរបស់កម្ពុជា ដែលអាចប្រើប្រាស់សម្រាប់ការស្រាវជ្រាវនិងវិភាគ ក្នុងគោលបំណងបង្កើត និងជំរុញឲ្យមានការពិភាក្សាតទៅទៀតអំពីថាតើនរណាគួរទទួលខុសត្រូវចំពោះការសម្លាប់កាលពីរបបខ្មែរក្រហម ហើយទទួលខុសត្រូវដោយរបៀបណា ។ កិច្ចខិតខំប្រឹងប្រែងតទៅមុខទៀតដើម្បីប្រឈមមុខទៅនិងអំពើឃោរឃៅកាលពីអតីតកាលអាចនឹងធ្វើឲ្យផ្សះនូវស្លាកស្នាមដែលឈឺចាប់ជាយូរមកហើយដោយលើកទឹកចិត្តឲ្យមានការបញ្ចេញមតិ គំនិត និងយោបល់ និងការតាំងចិត្តខ្ពស់មកលើខ្លួនឯង ដែលជាកេរដំណែលថ្មីរបស់កម្ពុជាដើម្បីធ្វើឲ្យមានការគោរពសិទ្ធិបុគ្គល និងនិតីរដ្ឋ ។ **អាន ហាញឌុល**



ខៀវ សំផន (ឆ្វេង) និង នួន ជា នៅបន្ទប់សវនាការក្នុងខែតុលា ឆ្នាំ២០១៣ ។ រូបថត អ.វ.ត.ក

# បទឧទ្ទេសនាមរបស់សមមិត្តតំណាងអង្គការបក្សក្នុងឱកាសបុណ្យខួបទី៩នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជាដ៏អង់អាចក្លាហាន និងខ្លាំងពូកែមហាអស្ចារ្យ

*ដកស្រង់ចេញពីសៀវភៅ យុវជន និងយុវនារីបដិវត្តន៍ លេខ៥ ខែឧសភា ឆ្នាំ១៩៧៦*

**(តពីលេខមុន)**

ពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៥៤ ក៏មានការតស៊ូប្រឆាំងចក្រពត្តិបារាំង ។ មានកងទ័ពរបស់យើងដែរ វាយខ្លាំងដែរ ប៉ុន្តែកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ៥៤ គេស៊ីញ៉េតែមួយខ្ទាកថា ឲ្យឈប់ការតស៊ូរបស់ប្រជាជនកម្ពុជាត្រូវឈប់ ។ គេឆូតតែមួយខ្ទាក កងទ័ពត្រូវរលាយ ទៅឡើងត្នោតវិញ ទៅរត់ស៊ីក្លូវិញ ទៅធ្វើអីៗវិញ ។ យើងសួរថា តើមកពីអី? មកពីគ្មានបក្សដឹកនាំ គ្មានមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធី គ្មានមាគ៌ាយោធា គ្មានមាគ៌ាសង្គ្រាមប្រជាជនរបស់បក្សយើងដឹកនាំ បានជាកងទ័ពនេះរលាយយ៉ាងនេះ ។ រលំរលាយខ្ទួន ទៅឋិតក្នុងកណ្តាប់ដៃខ្មាំងវិញ ។

ប៉ុន្តែចាប់ពីឆ្នាំ១៩៦០ ដែលបក្សមានមាគ៌ាយុទ្ធសាស្ត្រ មានមាគ៌ាយុទ្ធវិធី ហើយក្នុងនោះ មានរៀបចំហិង្សាបដិវត្តន៍ មានរៀបចំកងទ័ព តើយ៉ាងម៉េច? ៦០ ដៃទទេ ។ ៦១-៦២-៦៣...៦៧ ដៃទទេ ។ កងការពារសម្ងាត់ ៦៨ ផ្ទុះអាវុធ ដូចបានជម្រាបហើយ ។ ៦៨-៦៩ ផ្ទុះអាវុធ ផ្ទុះសង្គ្រាម បាតដៃទទេ ។ ខាងក្នុងស្រុក វណ្ណៈកាន់អំណាច វាប្រមូលកម្លាំងដើម្បីវាយយើង ។



ប៉ុល ពត កំពុងថ្លែងសុន្ទរកថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ខាងក្រៅស្រុក យើងមានតែម្នាក់យើង ។ ខ្មាំងក្នុងស្រុក វាវាយកម្ទេចយើង វាវាយដោយនយោបាយ វាយដោយអាវុធ ។ ៦៨-៦៩ សមមិត្តជ្រាបហើយ វាវាយយើងយ៉ាងម៉េច ប៉ុន្តែយើងឈប់ទេ? អត់ឈប់ ។ យ៉ាងម៉េច បានជាមិនឈប់ ពីព្រោះមាគ៌ារបស់បក្សកំណត់ថា ត្រូវវាយ ហើយបក្សពិនិត្យថា ស្ថានការណ៍ទំនាស់រវាងយើងនឹងខ្មាំងត្រូវតស៊ូអាវុធ ។ បើយើងមិនតស៊ូអាវុធ កម្លាំងបដិវត្តន៍ត្រូវខ្ទេចហើយ ដៃទទេទៀតហើយ ។ តស៊ូជំនាន់មុនជាមួយបារាំងដៃទទេ ។ ៥៤ ក៏ដៃទទេ ។ ឥឡូវយើងតស៊ូទៀត បើយើងឈប់មិនមែនដៃទទេទេ គឺវាអារកស្លាប់ ។ ពីមុនវាអារកល្មមទេ តែម្ដងទៀត វាអារកទាំងអស់ ។ ដូច្នេះយើងមិនឈប់ពិបាកយ៉ាងម៉េចក៏យើងមិនឈប់ ។ នរណាថាម៉េច ក៏យើងមិនឈប់ ។ បក្សឯកភាពគ្នាទាំងមូលថា ត្រូវវាយ ។ ជំហររបស់យើងវាយតទៅទៀត នៅនិរតីក៏អ៊ីចឹង ឦសានក៏អ៊ីចឹង កន្លែងណាក៏អ៊ីចឹង ។ យើងវាយតទៅទៀត ។ យើងបាតដៃទទេ យើងហ៊ានវាយ ។ កងទ័ពនេះមិនស្លាប់ទេ កងទ័ពនេះមិនបរាជ័យទេ គឺកាន់តែកើនចម្រើនធំធាត់ឡើងជាលំដាប់ គឺ៦៨ កងការពារសម្ងាត់មកជាកងឈ្លបក្រុមឈ្លប អនុសេនាតូច អនុសេនាធំ ។ ដល់៧០ យើងមានអនុសេនាធំហើយ ។ មិនមែនកងទ័ពនេះវារាត់រាយទៅវិញ វាបរាជ័យទៅវិញទេ ។ មកពីអ្វី? គឺមកពីមានមាគ៌ារបស់បក្សដឹកនាំត្រឹមត្រូវ ។ ឆ្នាំ៧០ រដ្ឋប្រហារភ្លាម យើងវាយដោយឯករាជ្យម្ចាស់ការ ។ យើងកសាងកងទ័ពយើងដោយឯករាជ្យម្ចាស់ការ ។ បើប្រសិនណាជាយើងពឹងផ្អែកបរទេស តើកងទ័ពយើងធំធាត់ប៉ុណ្ណឹងទេ? តើយើងវាយចក្រពត្តិអាមេរិកឈ្នះទេ? បើយើងមិនឯករាជ្យខ្លួនយើង តើយើងវាយតទៅទៀតបានទេ នៅឆ្នាំ៧៣? អត់បានទេ ។ ប៉ុន្តែ រដ្ឋប្រហារភ្លាម យើងកសាងកងទ័ពយើងដោយឯករាជ្យ ។ និយាយជារួម គឺយ៉ាងនេះ ឆ្នាំ១៩៧៣ មានកិច្ចព្រមព្រៀងប៉ារីស វៀតណាមឈប់ ឡាវឈប់ ប្រទេសជាច្រើននៅក្នុងសកលលោកតស៊ូបង្ខំឲ្យយើងឈប់ ។ ប៉ុន្តែបក្សកំណត់ថា អត់ឈប់ទេ វាយតទៅទៀត ។ យើងឯកភាពគ្នាទាំងស្រុងថា វាយតទៅទៀត ហើយវាយនេះ មិនមែនប្រថុយប្រថានទេ គឺវាយនេះ មានលទ្ធភាពឈ្នះខ្មាំង ។ បើប្រសិនណា ជាយើងឈប់តែ១ខែ ខ្មាំងវាដកដង្ហើមបាន វាពង្រឹងពង្រីកកម្លាំងបាន ។ ប៉ុន្តែ យើងវាយជាប់ ខ្មាំងគ្មានឱកាសពង្រឹងពង្រីកកម្លាំងបានទេ ។ វាយតទៅទៀត ។ យើងអត់ឈប់ យើងសុខចិត្តបន្តវាយម្នាក់យើង អ្នកណាជួយមិនជួយខបត្ដម្ភ មិនខបត្ដម្ភ អត់មានបញ្ហាអីទេ ពីព្រោះមាគ៌ារបស់យើងកំណត់ថា ត្រូវវាយ ហើយហេតុផលរបស់យើងស្ថានការណ៍យើងថា ត្រូវតែវាយបានរស់ ។ បើមិនវាយ ខ្ញុំគេ ។ មានតែផ្លូវហ្នឹងទេ ប៉ុន្តែ បើវាយមានតែផ្លូវរស់ គ្មានផ្លូវស្លាប់ទេ ។ មាគ៌ារបស់បក្សបានកំណត់ច្បាស់យ៉ាងនេះ កងទ័ពឯកភាពគ្នាទាំងមូល ។ គោលជំហររបស់បក្សឯកភាពគ្នាទាំងមូល ។ គោលជំហររបស់បក្សឯកភាព ។ បូព៌ា និរតី ពាយ័ព្យ ឦសាន ឧត្តរ ទូរលេខមកថា យើងវាយតទៅទៀត ដាច់ខាតគ្មានសម្រុះសម្រួលគ្មានរាថយគ្មានចរចា ។ យើងឯកភាពគ្នាវាយតទៅទៀត ។

បើគ្មានបក្សដឹកនាំ គ្មានមាគ៌ាត្រឹមត្រូវដឹកនាំឲ្យកងទ័ពនេះប្រយុទ្ធអនុវត្តសង្គ្រាមប្រជាជនទេ កងទ័ពនេះមុខជាបរាជ័យ ។ ហេតុនេះហើយបានជាយើងមិនយកថ្ងៃ មិនយកខែ មិនយកឆ្នាំផ្សេងឯទៀត ដើម្បីកំណត់ជាថ្ងៃកំណើតរបស់កងទ័ពបដិវត្តន៍យើងក្រៅពីថ្ងៃ១៧ មករា ឆ្នាំ១៩៦៨ទេ ពីព្រោះមិនមែនជាថ្ងៃមិនមែនជាខែ មិនមែនជាឆ្នាំដែលកងទ័ពនេះ បក្សដឹកនាំទេ គឺ ១៧ មករា ឆ្នាំ ១៩៦៨ ដែលបក្សដឹកនាំកងទ័ព មានមាគ៌ាយុទ្ធសាស្ត្រមានមាគ៌ាយុទ្ធវិធី មានមាគ៌ាយោធា មានមាគ៌ាសង្គ្រាមប្រជាជនមានមាគ៌ាប្រយុទ្ធត្រឹមត្រូវ បានដណ្ដើមបានជ័យជម្នះយ៉ាងនេះ ។ នេះជាហេតុផលនៃការកកើតកងទ័ពបដិវត្តន៍របស់យើង ។ យើងមានជំនឿយ៉ាងនេះ ហេតុផលនេះច្បាស់លាស់ ។

ក្តាប់ប្រវត្តិនៃការកកើតកងទ័ពនេះ បានឃើញអានុភាពបានឃើញកម្លាំងនៃកងទ័ពបដិវត្តន៍យើង ហើយបើពង្រឹង និងពង្រីកកងទ័ពនេះ ទៅតាមទិសនេះ គ្មានខ្មាំងណាវាយបានទេ ។ កងទ័ពយើងមិនឈ្លានពាននរណាទេ ប៉ុន្តែ ប្រទេសណាមកឈ្លានពាន គឺកងទ័ពយើង និងប្រជាជនយើងវាយប៉ុន្មានឆ្នាំក៏បានដែរ ឲ្យតែឈរលើមាគ៌ានេះ ។ បើយើងមានកប៉ាល់ហោះ មានកប៉ាល់ទឹក មានរថក្រោះ មានកាំភ្លើងធំ តែបើយើងមិនឈរលើមាគ៌ាសង្គ្រាមប្រជាជន មិនឈរលើមាគ៌ាយោធារបស់បក្សទេ មិនខ្លាំងដូចកងទ័ពពេលដែលយើងវាយចក្រពត្តិអាមេរិកទេ ។ មិនខ្លាំងដូចពេលដែលយើងគ្មានកប៉ាល់ហោះ គ្មានរថក្រោះ គ្មានកប៉ាល់ទឹកទេ ។ ដូច្នេះ

ត្រូវនឹកឃើញពេលដែលយើងវាយចក្រពត្តិអាមេរិក កាលៈទេសៈ អី សម្ភារអីៗ សតិអារម្មណ៍នយោបាយយ៉ាងម៉េច ត្រូវពិនិត្យធាតុពិតកងទ័ពនេះ ។

## ៣) ទស្សនៈមួយចំនួនស្តីអំពីមាគ៌ាយោធារបស់បក្សយើង មាគ៌ាសង្គ្រាមប្រជាជន និងមាគ៌ាប្រយុទ្ធរបស់បក្សយើង

បញ្ហានេះទាក់ទងនឹងសមមិត្តខាងយោធាជាសំខាន់ ។ សំណូមពរ លើកឡើងក្នុងឱកាសនេះ ព្រោះយើងធ្វើបុណ្យខួបរបស់កងទ័ពបដិវត្តន៍យើង ។ ដូច្នោះ លើកបញ្ហាយោធាមួយចំនួន ។ សមមិត្ត ឯទៀតមិនមែនជាយោធា ក៏ត្រូវយល់ និងក្តាប់បញ្ហានេះដែរ ។

យើងរំពឹក ដើម្បីក្តាប់វា និងអនុវត្តវាជាបន្តបន្ទាប់ទៀត ។

◆ អំពីមាគ៌ាចាត់តាំងយោធារបស់បក្សៈ

មាគ៌ាចាត់តាំងយោធារបស់បក្សយើង គឺកសាងកងទ័ពក្នុងចលនារបស់មហាជន ។ មិនមែនកសាងកងទ័ពដាច់ដោយឡែកពីចលនាបដិវត្តន៍របស់មហាជនទេ ។ យើងកសាងកងទ័ពក្នុងចលនាបដិវត្តន៍របស់មហាជន ក្រោមការដឹកនាំរបស់បក្ស ។

ដូច្នេះហើយ បានជាកំណត់ថា កងទ័ពបដិវត្តន៍កម្ពុជាជាឧបករណ៍ផ្តាច់ការដ៏បរិសុទ្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីបម្រើបដិវត្តន៍កម្ពុជាប្រជាជនកម្ពុជា ។ កសាងកងទ័ព គឺមិនមែនដើម្បីឲ្យផ្ទុយនឹងមាគ៌ារបស់បក្ស ឬផ្ទុយពីផលប្រយោជន៍របស់កម្មករកសិករទេ ។

កងទ័ពយើងមិនមែនជាកងទ័ពបច្ចេកទេសទេ ។ ជាកងទ័ពនយោបាយបដិវត្តន៍របស់វណ្ណៈកម្មករ បម្រើប្រជាជាតិកម្ពុជាប្រជាជនកម្ពុជា កម្មករ កសិករ ។

បើកសាងផ្ទុយពីនេះ គឺមិនត្រូវទេ ។ កងទ័ពនេះខ្លាំងណាស់ ។ ពីឥឡូវទៅថ្ងៃក្រោយទៀត សមមិត្តមួយចំនួនទៅខាងកប៉ាល់ហោះ ។ កប៉ាល់ហោះឥឡូវ ល្មមៗទេ បន្តិចទៀត យើងមានកប៉ាល់ហោះប្រតិកម្ម ។ ទោះបីកប៉ាល់ហោះប្រតិកម្មក៏ដោយ សមមិត្តដែលប្រើកប៉ាល់ហោះមិនមែនឈរលើបច្ចេកទេសទេ គឺឈរលើមូលដ្ឋានបដិវត្តន៍ ឈរលើមាគ៌ារបស់បក្ស ដើម្បីប្រើកប៉ាល់ហោះ ។ រថក្រោះក៏ដូច្នោះ កាំភ្លើងក៏ដូច្នោះ បម្រើកម្ពុជាប្រជាធិបតេយ្យ បម្រើប្រជាជនកម្មករ កសិករសមូហភាព ។ សមមិត្តទទួលភារៈផ្នែកនីមួយៗ ត្រូវអប់រំបញ្ហានេះ ពិសេសខាងកប៉ាល់ហោះ ។ កប៉ាល់ហោះយើង មិនខ្លាំងជាងកប៉ាល់ហោះអាមេរិកទេ ទោះជាប្រតិកម្មក៏ដោយ តែបើអ្នកបើកខ្លាំង កប៉ាល់ហោះយើង ពិតជាខ្លាំងជាងកប៉ាល់ហោះខ្មាំងឆ្ងាយណាស់ ។

ឧទាហរណ៍ ខែ៥ ឆ្នាំ១៩៧៥ អាមេរិកយកកប៉ាល់ចម្បាំងនាវាទី៧ មកបុកយកកោះតាង ។ ប្រធានាធិបតីវាឈ្មោះ អាហ្វ័រ ដឹកនាំផ្ទាល់ មកវាយយើង មានឧទ្ធម្ភាគចក្រដឹកទាហានវាមកចុះលើកោះតាង ។ ពេលនោះយើងមានតែមួយអនុសេនាតូចទេ អាវុធក៏តិច ។ ពេលវាបាញ់ផ្លោង និងទម្លាក់ យើងអត់វាយទេ យើងរង់ចាំវា ។ ដល់វាឡើងមក យើងវាយកម្ទេចវាស្លាប់ និងរបួសជាង២០០នាក់ ។ ទាហានវាកំសាកបំផុត ដល់យើងបាញ់របួសហើយ វារវល់តែដឹកជញ្ជូនទាហានរបួសត្រឡប់វិញ ។

ដូច្នោះ កងទ័ពយើងខ្លាំងក្លាណាស់ មិនមែនមកពីអាវុធទេ ។ ទោះជាយើងមានបច្ចេកទេស មានសាស្ត្រាវុធកាន់តែច្រើន ក៏ដោយ ត្រូវកសាងខាងគោលជំហរបដិវត្តន៍ គោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឲ្យខ្លាំង ។ បើបំពាក់គោលជំហរនេះបាន កងទ័ពនេះខ្លាំងណាស់ ។

ឧទាហរណ៍ យើងរៀបចំផែនការវាយផ្តាច់អ្នកលឿង និងវាយផ្តាច់ភ្នំពេញព្រមជាមួយគ្នា ។ កងទ័ពសុំកាំជ្រួច១០៧អត់សុំគ្រាប់អត់ ។ ប្រមូលទៅគ្រាប់កាំភ្លើងធំបាន១០០ឬ២០០គ្រាប់ មួយសមរភូមិ ។ ឯគ្រាប់កាំភ្លើងតូច ក៏មិនគ្រប់ ។

កងទ័ពជឿជាក់លើបក្ស មានគោលជំហរនយោបាយ សតិអារម្មណ៍ខ្លាំង វាយឈ្នះមែនទែន មិនមែនអាវុធទេ គឺនយោបាយ សតិអារម្មណ៍ ដាច់ខាតវាយ ។ នេះមួយ ។ ម្យ៉ាងទៀត គឺមាគ៌ាប្រយុទ្ធត្រឹមត្រូវ ដូច្នោះ មិនមែនអាវុធទេ ដែលជាកត្តាកំណត់ ។

កងទ័ពយើងកកើតមានអាយុ៩ឆ្នាំ វាយឈ្នះកងទ័ពអាមេរិក មានអាយុ២០០ឆ្នាំ ។ ដូច្នោះ បច្ចុប្បន្ន ក៏ដូចអនាគត យើងកសាងកងទ័ពយើងយ៉ាងនេះតទៅទៀត គឺហ៊ឹកហ៊ឺនក្នុងចលនាបដិវត្តន៍ ។ កុំខ្លាចលំបាក ទាល់តែហ៊ឹកហ៊ឺនក្នុងចលនា ទើបមានពិសោធន៍ ។ យើងត្រូវកសាងកម្មាភិបាលយើងយ៉ាងនេះ ។

មាគ៌ាបក្សយើងគឺវាយទាំងយប់ទាំងថ្ងៃទាំងប្រាំងទាំងវស្សា មិនទុកឲ្យខ្មាំងដកដង្ហើមបាន ។ ក្នុងខែ១២ យើងវាយខ្មាំងទាំង

១២ខែ វាយទាំងយប់ ទាំងថ្ងៃ វាយទាំងសម្បុរបែប វាយទាំងឈ្លប វាយទាំងវស្សា កុំឲ្យខ្មាំងដកដង្ហើមទាន់ ។ យើងគ្មានអាវុធអីប៉ុន្មានទេ ប៉ុន្តែយើងរៀបចំវាយអ៊ីចឹង ។ ខែប្រាំងយើងវាយធំ ។ ខែវស្សាយើងបំបែកកម្លាំងវាយតូច ប៉ុន្តែវាយជាប់ ។ ដូច្នោះ ១ឆ្នាំ ១២ខែ យើងវាយទាំង១២ខែ ។ កងទ័ពយើងខ្លាំងណាស់ ហើយទៅថ្ងៃក្រោយទៀត ពួកឈ្លានពាន ពួកណាហ៊ានមកឈ្លានពានកម្ពុជា តើយើងវាយបានទេ? វានៅស្រុកយើងបានទេ? ១២ខែកុំឲ្យវាសម្រាក ។ វានៅបានទេ វានៅ១ឆ្នាំ វាយ១២ខែ វានៅ២ឆ្នាំ វាយ២៤ខែ ។ បើនៅ៣ឆ្នាំតទៅទៀត វាយរហូតគ្មានលោះខែនៅបានទេ ។ អត់នៅបានទេ ប៉ុន្តែវាយបានយ៉ាងនេះ វាយ១២ខែក្នុង១ឆ្នាំ បានយ៉ាងនេះ លុះត្រាតែមាគ៌ាប្រយុទ្ធត្រឹមត្រូវ លុះត្រាតែអង់អាចក្លាហាន គោលជំហរបដិវត្តន៍ អង់អាចក្លាហាន ។ សុំបន្ថែមទៀត ឥឡូវនេះ ខាងសម្ភារ និងខាងបច្ចេកទេស កងទ័ពយើងកាន់តែចម្រើនហើយ ។ ជាចំណុចល្អរបស់យើង ប៉ុន្តែកត្តានេះមិនមែនជាកត្តាកំណត់ទេ ពីព្រោះ ពីមុនយើងអត់មានសម្ភារប៉ុន្មានទេ ។ ដូច្នោះ មិនមែនបច្ចេកទេសទេ ដែលកំណត់ គឺសតិអារម្មណ៍បដិវត្តន៍របស់កងទ័ពយើងដែលជាកត្តាកំណត់ ។

ដូច្នេះ មាគ៌ាចាត់តាំង មាគ៌ាកសាងយោធារបស់យើងនៅតែផ្អែកលើគោលនយោបាយ នៅតែផ្អែកលើសតិអារម្មណ៍ មិនមែនផ្អែកលើបច្ចេកទេស ។ បច្ចេកទេសយើងចេះតែពង្រឹងពង្រីកថែមទៀត ឈរលើមូលដ្ឋាននយោបាយ ។ បច្ចេកទេសកាន់តែខ្លាំង សតិអារម្មណ៍កាន់តែខ្លាំងថែមទៀត ។ ប៉ុន្តែ បើបច្ចេកទេសកាន់តែខ្លាំង ហើយសតិអារម្មណ៍កាន់តែអន់ កងទ័ពនេះខ្សោយ ។ ត្រូវពិនិត្យក្រមនេះ ។

ពិនិត្យពីមាគ៌ាចាត់តាំងរបស់យើង ។ កសាងអង្គភាពមួយ កសាងយុទ្ធជន យុទ្ធនារីម្នាក់ កសាងកម្មាភិបាលម្នាក់ ឬប្រាំនាក់ ត្រូវឈរលើអី ដើម្បីធ្វើយ៉ាងនេះបាន គឺបក្សទាំងមូលត្រូវក្តាប់មាគ៌ានេះ ។ នេះទី១ ។ ទី២ ខាងគណៈយោធា ត្រូវក្តាប់មាគ៌ានេះ ។ ទី៣ សេនាធិការត្រូវក្តាប់មាគ៌ានេះ ។ ទាំងបក្សទូទាំងប្រទេស ទាំងភាគ ទាំងគ្រប់កន្លែង ទាំងបក្សនៅក្នុងអង្គភាពមួយៗ ត្រូវក្តាប់មាគ៌ានេះ ។ គណៈកម្មាធិការនៅក្នុងកងពល នៅក្នុងវរសេនាធំ នៅក្នុងវរសេនាតូច សាខានៅក្នុងអនុសេនាធំត្រូវក្តាប់មាគ៌ានេះ ។ បើបក្សក្តាប់មាគ៌ានេះជ្រួតជ្រាបហើយ អង្គភាពកងពល វរសេនាធំ វរសេនាតូច អនុសេនាធំនេះខ្លាំងណាស់ ។ យើងបន្តអនុវត្តមាគ៌ាយោធារបស់យើងតទៅទៀតអ៊ីចឹង ។

◆ អំពីមាគ៌ាសង្គ្រាមប្រជាជនរបស់បក្សៈ

យើងមានមាគ៌ាសង្គ្រាមប្រជាជនមួយច្បាស់លាស់របស់យើង ដើម្បីធ្វើសង្គ្រាមប្រជាជនសម្រាប់យកជ័យជម្នះ យើងយកចិត្តទុកដាក់បញ្ហាមួយចំនួនដូចតទៅៈ

១) ត្រូវមានបក្សរឹងប៉ឹងខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង ។ បើមានតែបក្ស តែបក្សមិនខ្លាំង មិនរឹង ដឹកនាំសង្គ្រាមប្រជាជនមិនបានទេ បរាជ័យ ។

កន្លងមក ហេតុម៉េចបានជាយើងដណ្តើមបានជ័យជម្នះ ។ មកពីបក្សមានមាគ៌ាត្រឹមត្រូវ មានសតិអារម្មណ៍ដាច់ខាត ហើយមានការចាត់តាំងត្រឹមត្រូវ ។ បញ្ហានេះមិនបាច់អធិប្បាយច្រើនទេ ។ ការចាត់តាំងត្រឹមត្រូវ មិនមែនបញ្ហាចំនួនទេ គឺបញ្ហាគុណភាព ។ ក្នុងពេលដែលយើងរៀបចំវាយផ្តាច់ព្រ័ត្រ កណ្តាលឆ្នាំ៧៤ ត្រៀមរៀបចំ៧៥ យើងសុខចិត្តបិទទ្វារបក្ស មិនពង្រីកបក្សទេ កុំឲ្យខ្មាំងវាចូល ។ បើខ្មាំងចូល កងទ័ពយើងវាយមិនខ្លាំងទេ ដូច្នេះ ចំនួនតិចមែន ប៉ុន្តែខ្លាំងណាស់ ។ នេះចង់និយាយថា ចាត់តាំងត្រឹមត្រូវ ស្អាតស្អំ ។ នេះជាបក្សខ្លាំងទី១ ។

២) ត្រូវមានប្រជាជនខ្លាំង ។ រណសិរ្សធំទូលាយ ហើយផ្អែកលើកម្មករ កសិករ មានកម្លាំងកម្មករ កសិករបង្អែក ។ កន្លងមកយើងប្រមូលកម្លាំងបានទាំងអស់ ។ យើងមានរណសិរ្សរួបរួមជាតិមួយ ប៉ុន្តែស្អីជាមូលដ្ឋាន? កម្មករ កសិករ ក្រោមការដឹកនាំរបស់បក្ស ។ កងទ័ពរបស់បក្ស កម្លាំងមូលដ្ឋានរបស់បក្ស ។ សហករណ៍ជាកម្លាំងសម្ព័ន្ធភាពកម្មករ កសិកររបស់បក្ស ។ កងទ័ពជាឧបករណ៍របស់បក្ស ជាកម្លាំងរបស់បក្ស ។ ដូច្នោះ រណសិរ្សរបស់យើងខ្លាំងណាស់ កម្លាំងធំទូលាយក៏យើងប្រមូលបាន ប៉ុន្តែកម្លាំងស្នូលក៏យើងកសាងពង្រឹងពង្រីកបាន ។ នៅក្នុងនេះ សហករណ៍ដើរតួណាស់ ។ គ្មានសហករណ៍ យើងដណ្តើមជ័យជម្នះមិនបានទេ ។ ដូច្នោះ ប្រជាជនយើងខ្លាំង ខ្លាំងទាំងបម្រើសមរភូមិមុខ ខ្លាំងទាំងបម្រើសមរភូមិក្រោយ ។ សុំលើកបញ្ហានេះឡើង ដើម្បីបច្ចុប្បន្នក្តីតទៅអនាគតក្តី យើងត្រូវយកចិត្តទុកដាក់ធ្វើការងារនយោបាយ

ការផ្សារសតិអារម្មណ៍ ការផ្សារចាត់តាំងបំប៉នកម្លាំង ប្រជាជនយើងយកចិត្តទុកដាក់ប្រជាជនយើង កុំឲ្យប៉ះពាល់ប្រជាជន ធ្វើម៉េចដណ្តើមកម្លាំងប្រជាជន ឲ្យបានជាអតិបរមា ព្រោះកងទ័ពយើងកើតពីប្រជាជន កូនចៅប្រជាជន ។ ឥឡូវក៏អ៊ីចឹង ទៅអនាគតក៏អ៊ីចឹង ហើយបើប្រជាជនល្អហើយ កងទ័ពល្អហើយ ល្អដាច់ខាត ប៉ុន្តែប្រជាជនមួយ នៅក្នុងប្រភេទ កម្មករ កសិករ ។ ប្រជាជនមួយជាកម្លាំងជំនួយ ។ ក្នុងរយៈកាលមួយៗអ៊ីចឹង យើងផ្អែកលើមាគ៌ាវណ្ណៈ ។ ប៉ុន្តែ យើងខំប្រមូលទាំងអស់ កម្លាំងណាដែលអាចប្រមូលបាន ប៉ុន្តែ យើងផ្អែកលើវណ្ណៈ ផ្អែកលើកម្មករ កសិករសមូហភាព តាមមាគ៌ាវណ្ណៈរបស់បក្ស ។

៣) ធ្វើសង្គ្រាមប្រជាជន ត្រូវមានកងទ័ពខ្លាំង ។ បើគ្មានកងទ័ពខ្លាំងទេ នោះធ្វើសង្គ្រាមមិនបានទេ ត្រូវមានកងទ័ពខ្លាំង ។

៤) ដើម្បីធ្វើសង្គ្រាមប្រជាជនយកជ័យជម្នះបាន លុះត្រាតែមានសេដ្ឋកិច្ចឧបត្ថម្ភខ្លួន ។ គ្មានសេដ្ឋកិច្ចឧបត្ថម្ភខ្លួន ធ្វើសង្គ្រាមមិនបានទេ ។ យើងដោះស្រាយបញ្ហាសេដ្ឋកិច្ចបាន ។ ក្នុងសង្គ្រាមយើងដោះស្រាយបាន ក្រោយសង្គ្រាមក៏យើងដោះស្រាយបាន ។ មានការលំបាកមែន តែយើងដោះស្រាយបាន ។ ក្នុងសង្គ្រាមយើងមិនដែលដឹកអង្ករពីបរទេសមកទេ ។ មិនចាំនិយាយមួយបាវទេ និយាយមួយគ្រាប់ក៏យើងគ្មានដឹកមកពីក្រៅដែរ ។ ក្នុងសង្គ្រាមយើងឧបត្ថម្ភខ្លួនបាន ។ នេះទី១ ។ ទី២ យើងលក់ទៅបរទេសទៀត ។ នេះសង្គ្រាម ។ យើងដោះស្រាយសេដ្ឋកិច្ចបាន ។ ក្រោយសង្គ្រាមយើងមានការលំបាកដែរ ប៉ុន្តែ ប្រៀបធៀបយើងដោះស្រាយបាន ។ ឥឡូវយើងដោះស្រាយបានទេ? អនុវត្តរបបរបស់បក្សបានទេ? រាយការណ៍ក្នុងដើមខែនេះ ហើយយើងខ្ញុំទៅមើលគ្រប់មូលដ្ឋានឃើញថា អនុវត្តគ្រប់របបបានទាំងអស់ ។ ដូចបានជម្រាបពេលមុនក្នុងសាលារៀន សមមិត្តជ្រាប ហើយនិយាយមួយម៉ាត់ទៅ យើងហូបបាន៣១២គីឡូក្រាម ក្នុង១ឆ្នាំ ក្នុង១នាក់ ។ ដូច្នោះកម្រិតនេះខ្ពស់ណាស់ ហើយយើងបម្រុង២ថាំង ក្នុង១នាក់ ក្នុងឆ្នាំ៧៧នេះ ។ ទន្ទឹមនេះ យើងនៅសល់នាំចេញពី១សែន៥ម៉ឺនតោនទៅ២សែនតោនអង្ករទៀត ។ ដូច្នេះ ខ្លាំងណាស់ ។

កសិកម្មរបស់យើង យើងធ្វើដោយខ្លួនយើងមួយរយភាគរយ ។ ក្នុងសង្គ្រាមក៏ដូច្នេះ ។ យើងត្រូវរក្សាប្រពៃណីនេះត្រូវរក្សាជំហរនេះ ពង្រឹងពង្រីកជំហរនេះ ដើម្បីកសាងប្រទេសក៏ខ្លាំង ហើយក្នុងកាលៈទេសៈសង្គ្រាម សេដ្ឋកិច្ចក៏ត្រូវតែខ្លាំង ហើយរឹតតែខ្លាំងទៅទៀត ពីព្រោះ យើងកាន់តែមានពិសោធន៍ យើងកាន់តែមានកម្លាំងថែម ។

៥) ត្រូវមានមិត្តលើសកលលោក ។ ដើម្បីធ្វើសង្គ្រាមប្រជាជនបញ្ហាមួយទៀត ក៏ត្រូវមានមិត្តលើសកលលោក ។ ត្រូវមានមិត្តជួយឧបត្ថម្ភក្នុងសកលលោក ជាមិត្តឧបត្ថម្ភខាងស្មារតីខាងនយោបាយ ខាងទូត កុំឲ្យខ្មាំងវាឯកោយើងបាន ។ គេឧបត្ថម្ភយ៉ាងម៉េច គឺឧបត្ថម្ភគាំទ្រការតស៊ូរបស់យើង ហើយបើមានខ្មាំងមកឈ្លានពានអី គេឧបត្ថម្ភយើង គេថ្កោលទោសខ្មាំង ។ យើងត្រូវមានមិត្តដែរ ។ ដូច្នោះបានជានៅក្នុងសង្គ្រាមកន្លងមក យើងមានមិត្តច្រើនណាស់ ហើយឥឡូវនេះ ក៏យើងមានមិត្តច្រើន ពីព្រោះឥឡូវពិតមែនតែពួកចក្រពត្តិវាជេរយើង ម្នាក់២នាក់ ប៉ុន្តែក្នុងសកលលោកទាំងមូលទទួលស្គាល់យើងចង់អស់ ។ យើងខំដណ្តើមមិត្តតទៅទៀត ដើម្បីដណ្តើមមិត្តឲ្យបានច្រើន មិនមែនការផ្សារទូតមិនមែនសកម្មភាពទូតជាសំខាន់ទេ ។ សំខាន់ កត្តាអត្តនោម័តិ កត្តាបដិវត្តន៍នៅក្នុងប្រទេស យើងការពារប្រទេសបានល្អ កសាងប្រទេសបានល្អ អ្នកណាក៏ចង់ស្គាល់ ចង់ដឹង ចង់ទាក់ទង ។

នេះជាកត្តាកំណត់ នាំឲ្យដណ្តើមមិត្តភក្តិក្នុងសកលលោកកាន់តែបានច្រើន មកពីការពារប្រទេសបានល្អ មកពីកសាងប្រទេសបានល្អ ។ ឲ្យតែធ្វើយ៉ាងនេះបាន ក្រសួងការបរទេសទៅកន្លែងណាក៏ងាយស្រួលដែរ ពីព្រោះឥទ្ធិពលអង្គភាពបដិវត្តន៍ វាកាន់តែរីកលូតលាស់ ។ យើងខំតទៅទៀត ។

ក្នុងសង្គ្រាមប្រជាជន ដែលយើងរៀបរាប់ទាំងអម្បាលម៉ាននេះ ជាទិដ្ឋភាពរួមដែលបក្សទាំងមូលត្រូវក្តាប់ ហើយអនុវត្តវាឲ្យបានល្អ ។ ដូច្នេះ យើងធ្វើសង្គ្រាមប្រជាជនមិនមែនកសាងតែកងទ័ពទទេទេ គឺកសាងកម្លាំងបក្ស កសាងកម្លាំងប្រជាជន កសាងកម្លាំងកងទ័ព កសាងកម្លាំងសេដ្ឋកិច្ច និងកសាងកម្លាំងមិត្តលើសកលលោកផ្សេងទៀតផង ។ នេះជាសម្ភារនិយមបដិច្ចសមុប្បាទ ព្រោះវាទាក់ទងគ្នា ។

◆ រំពុកមាគ៌ាប្រយុទ្ធមួយចំនួនៈ

ទី១ វាយខ្មាំងខាងយោធា វាយខ្មាំងខាងនយោបាយ វាយ

ខ្មាំងខាងសេដ្ឋកិច្ច វាយខ្មាំងខាងចលនាទាហានខ្មាំង និងវាយខ្មាំង ដោយកម្លាត់សង្គ្រាមចារកម្ម សង្គ្រាមចិត្តសាស្ត្រ និងសន្តិសម្ព័ន្ធរបស់វា ។

យើងរំពុកបញ្ហានេះឡើង ដើម្បីក្តាប់វា និងអនុវត្តវាឲ្យបានត្រឹមត្រូវ ។ យើងដណ្តើមបានជ័យជម្នះ ដោយយើងអនុវត្តមាគ៌ាប្រយុទ្ធនេះបានត្រឹមត្រូវណាស់ ។

**ក) វាយខ្មាំងខាងនយោបាយ** : យកឧទាហរណ៍តែមួយ គឺដណ្តើមប្រជាជន ។ នៅក្នុងសកលលោក គេមិនដែលដណ្តើមប្រជាជនទេ ។ មាគ៌ាយើង គឺដណ្តើមប្រជាជន ម្នាក់ក៏យក ២នាក់ក៏យក ១រយនាក់ក៏យក ១ពាន់នាក់ក៏យក រហូតដល់ដណ្តើមប្រជាជនពីភ្នំពេញទៀត ។ មាគ៌ាពង្រឹងប្រជាជនពីខ្មាំងរបស់បក្ស គឺត្រឹមត្រូវណាស់ ។ ក្នុងសកលលោកគ្មានយ៉ាងនេះទេ ។ បើខ្មាំងមានប្រជាជន ខ្មាំងមានយោធា ខ្មាំងមានសេដ្ឋកិច្ច ។ បើខ្មាំងគ្មានប្រជាជន វាគ្មានកម្លាំងយោធា គ្មានកម្លាំងសេដ្ឋកិច្ច ។ ហេតុផលយើងត្រឹមត្រូវ ។ ដូច្នេះ មាគ៌ាយើងត្រឹមត្រូវណាស់ ។ កន្លែងណា ក៏យើងវាយដណ្តើមប្រជាជនដែរ ។

ឧទាហរណ៍ វាយខាងបាណាមនៅឆ្នាំ៧៣ ។ យកទាំងអស់ក្នុងក្រុងបាណាម បញ្ចេញទាំងអាណិកជនវៀតណាម អាណិកជនចិន ទាំងទាហាន ទាំងប៉ូលីស យកទាំងអស់ ពង្រឹងស្មារតីខ្មាំង ។

ឧទាហរណ៍ វាយផ្លូវលេខ៦ ចេនឡាទី២ ឆ្នាំ៧១ ។ ខ្មាំងវាយបម្រុងយកពីតាំងគោកទៅដល់កំពង់ធំ ។ វាកាត់ពីកំពង់ធំ មកត្រើងយកត្រីកោណនេះ ដើម្បីចាប់ប្រជាជន ប្រមូលប្រជាជនយកកម្លាំងនយោបាយ ប្រមូលប្រជាជនយកកម្លាំងសេដ្ឋកិច្ច ដណ្តើមភូមិភាគឧត្តរទៅទល់នឹងក្រចេះ ដើម្បីពួកអាធីវគីវាយពីខាងត្បូងមកយកក្រចេះ ។ តែវាវាយមិនឈ្នះ ដោយសារអី? ដោយសារយើងដកប្រជាជន ។ ដល់ដកប្រជាជនអស់ វាគ្មានកម្លាំងបន្ថែម ។ គ្មានកម្លាំងបន្ថែមជាសេដ្ឋកិច្ច គ្មានកម្លាំងបន្ថែមជាកម្លាំងមនុស្ស ។ វាកាន់តែខ្សោយទៅ ។ យើងវាយកាត់ជាកង់ៗ ធ្វើឲ្យកងស្រួចវាដាច់ក្បាល ដាច់កន្ទុយ បង្កបង្កើតលក្ខណៈសម្បត្តិ ដើម្បីវាយផ្តាច់ ។ កត្តានៃជ័យជម្នះ គឺយើងដកប្រជាជន ។

ឧទាហរណ៍ យើងរំដោះឧត្តុង្គ ក្នុងឆ្នាំ៧៤ ។ យើងដកប្រជាជនទាំងអស់ ។ ដល់វាដណ្តើមវិញ វាគ្មានកម្លាំង គ្មានកម្លាំងប្រជាជន គ្មានកម្លាំងសេដ្ឋកិច្ច គ្មានកម្លាំងយោធា ។ យើងវាយវាបាន ហើយមិនបាច់វាយផង ។ ដល់យើងវាយផ្តាច់ភ្នំពេញ យើងទុកចោល យើងវាយមកខាងមុខវិញ ។

នេះជាមាគ៌ាយុទ្ធសាស្ត្រមួយមានសារសំខាន់ណាស់ ។ ក្តាប់ប្រជាជន ដណ្តើមប្រជាជន ។ ដូច្នេះ បានជាបក្ខជនយើង យុទ្ធជនយើង យុទ្ធនារីយើង រដ្ឋអំណាចនៅមូលដ្ឋាន ធ្វើអ្វីដែលប៉ះពាល់ប្រជាជន ត្រូវយល់ន័យជាយុទ្ធសាស្ត្រនៃប្រជាជនយ៉ាងនេះ គឺប្រជាជននៅខាងណា ខាងនោះឈ្នះហើយ ។ ទោះជាប្រជាជនយុទ្ធសាស្ត្រក្តី ជាប្រជាជនយុទ្ធវិធីក្តី ។ ប្រជាជនយុទ្ធវិធី នៅជាមួយយើងក៏ជួយយើងដែរ ។ តែបើប្រជាជនយុទ្ធវិធីនៅជាមួយខ្មាំង គឺជួយខ្មាំង ។

ដូច្នោះ ក្នុងកិច្ចការពារប្រទេស បច្ចុប្បន្នក៏ដូចថ្ងៃក្រោយ គឺត្រូវក្តាប់ប្រជាជនឲ្យបាន ។ ដូច្នោះ បានជាបក្សយកចិត្តទុកដាក់ក្តាប់សហករណ៍ ។ ការងារស្នូល នៅឆ្នាំ៧៧នេះ គឺពង្រឹងពង្រីកសហករណ៍ឲ្យខ្លាំងក្លា ដោយកសាងសហករណ៍ ដោយកសាងសាខាបក្សក្នុងសហករណ៍ឲ្យបានគ្រប់១០០ភាគរយ ក្នុងឆ្នាំ៧៧នេះ ឲ្យសហករណ៍ទៅជាកំពែងដែកទូទាំងប្រទេស ។ សហករណ៍ទៅជាកំពែងដែក បានន័យថា ប្រជាជនយើងខ្លាំង ហើយស៊ីក៏ចូលមិនចុះដែរ នេះក្នុងន័យថា ក្តាប់ប្រជាជន ន័យនយោបាយ គឺ យ៉ាងនេះ ។

**ខ) វាយខ្មាំងខាងសេដ្ឋកិច្ច** : ពាក្យស្លោករបស់យើង វាយខ្មាំងខាងសេដ្ឋកិច្ច ហ៊ុមព័ទ្ធសេដ្ឋកិច្ចខ្មាំង ផ្តាច់សេដ្ឋកិច្ចខ្មាំង ផ្តាច់ស្បៀងខ្មាំង ។ ពេលសង្គ្រាម យើងក្តាប់សេដ្ឋកិច្ចបានក្នុងដៃ មិនលក់ស្បៀងឲ្យខ្មាំងទេ ។ ដូច្នេះ ខ្មាំងអត់អង្ករ អត់បាយ ។ ទាហានខ្មាំងវាក៏អត់បាយ ប្រជាជននៅក្នុងតំបន់ខ្មាំងក៏អត់បាយ ។ អាមេរិកត្រូវដឹកអង្ករពីស្រុកវាមកដើម្បីចិញ្ចឹមពួកអាក្បត់ ។ បក្សសន្និដ្ឋានថា ចក្រពត្តិអាមេរិកច្បាំងនៅកម្ពុជា ដឹកអង្ករពីអាមេរិកមក វាច្បាំងមិនឈ្នះយើងទេ ។ ដល់ផ្លូវយុទ្ធសាស្ត្រដាច់អស់ ផ្លូវមេគង្គដាច់អស់ គឺវាចាញ់ច្បាស់ ។ គ្រាប់យើងតិចមែន កម្លាំងយើងតិចមែន តែយើងវាយឈ្នះ ព្រោះយើងវាយខ្មាំងគ្រប់ផ្នែក វាយទាំងខាងយោធា វាយទាំងខាងនយោបាយ វាយទាំងផ្តាច់សេដ្ឋកិច្ចខ្មាំង ។

**គ) បញ្ហាបន្តទៅទៀតនេះ សុំជម្រាបអំពីបញ្ហាចលនាទាហានខ្មាំង** : ដែលយើងធ្វើនៅក្នុងសង្គ្រាមប្រជាជនរបស់យើងដែរ ។

បញ្ហាចលនាទាហានខ្មាំង ជាបញ្ហាយុទ្ធវិធីមួយដើម្បីធ្វើឲ្យខ្មាំងខ្សោយខាងស្មារតី បំបាក់បំបែកជួរខ្មាំង កុំឲ្យខ្មាំងមានកម្លាំងខ្លាំងក្លាមកទប់ទល់នឹងយើង មកវាយយើង ។ នេះជាសំណួមពរនៃចលនាទាហានខ្មាំង ។ របៀបចលនាទាហានខ្មាំងមានច្រើនយ៉ាង ។ ប៉ុន្តែក្នុងឱកាសនេះ ខ្ញុំសុំជម្រាបតែវិធីខ្លះដែលយើងធ្លាប់ធ្វើ ហើយមានសភាពស័ក្តិសិទ្ធិ ។ ដើម្បីចលនាទាហានខ្មាំងបានខសំខាន់គឺត្រូវវាយខ្មាំង ។ វាយខ្មាំងឲ្យខ្លាំង ឲ្យវាបរាជ័យ ឲ្យវាទាល់ច្រក រកផ្លូវចេញមិនរួច បានយើងចលនាវាមានប្រសិទ្ធភាព ហើយតាមពិសោធន៍របស់យើងមក យើងមិនដែលបានចលនាទាហានខ្មាំងបានទាំង អនុសេនាតូច អនុសេនាធំ ឬអង្គភាពទីតាំងវាបានម្តងទេ បើប្រសិនណា ជាយើងគ្មានវាយវា ។ ទាល់តែវាយវាឲ្យខ្លាំងបានដណ្តើមបានជ័យជម្នះ ហើយបានជ័យជម្នះជាបន្តបន្ទាប់ បានចលនាទាហានខ្មាំងបាន ក្នុងពេលដែលវាទាល់ច្រកហើយ ។ នេះជាវិធីដែលស័ក្តិសិទ្ធិជាងគេ ។ដូច្នោះ កុំសង្ឃឹមទៅអង្វរកវា ទៅធ្វើនយោបាយអីធម្មតា គឺទាល់តែវាយបានចលនាបាន ។ វាយហើយចលនា វាយហើយចលនាឲ្យចេញមក ដើម្បីរួចខ្លួនមករស់នៅជាមួយប្រជាជនធម្មតាវិញ ។ដូចជាភ័ស្តុតាង នៅកោះពាមរាំងនៅទន្លេមេគង្គ ។ កោះពាមរាំងឆ្នាំ៧៥ យើងវាយខ្ទេចខ្ទីហើយ វានៅលើកោះនេះ កប៉ាល់ហោះក៏ជួយមិនបាន ដើងទឹកក៏ជួយមិនបាន ថ្មើរជើងរបស់វាក៏ជួយមិនបាន វាត្រូវតែចុះចូលយើង ។ នេះជាឧទាហរណ៍មួយ ។

ឧទាហរណ៍មួយទៀត នៅខាងពាយ័ព្យភ្នំពេញ តាមយើងខ្ញុំចាំគឺនៅឈូកវ៉ា ។ មេទ័ពឈូកវ៉ា នេះ ឈ្មោះ អាខាន់ ។ វាក្បាលរឹងណាស់ ជាដៃស្តាំរបស់ អាចន្ទរង្សី ។ យើងវាយជុំវិញអស់ហើយ វាទាល់ច្រកហើយ យើងអំពាវនាវ វាសុខចិត្តចុះចូលយើង ។ យើងដណ្តើមទាហានខ្មាំងនេះបាន ដោយសារយើងវាយខ្លាំង ។ នៅតាំងគោក ក៏ដូចគ្នាដែរ ។ នៅឆ្នាំ៧៣ យើងវាយតាំងគោក ។ វាយផ្លូវលេខ៧ វាយផ្លូវលេខ៦ ដណ្តើមបានជ័យជម្នះជាបន្តបន្ទាប់ ហើយឯកោទីតាំងតាំងគោក ។ មួយកងពលតូចនៅតាំងគោក យើងចលនាវាឲ្យចុះចូលយើងបាន ។

នេះជាឧទាហរណ៍ខ្លះ បញ្ជាក់ថា ដើម្បីចលនាទាហានខ្មាំងបាន លុះត្រាតែវាយខ្មាំងឲ្យខ្លាំងក្លា ឯកោវាឲ្យទាល់ច្រកបាន វាចុះចូលយើង ។ វិធីទី២ នៃចលនាទាហានខ្មាំង គឺចលនាតាមគ្រួសារជាប្រពន្ធ ជាកូន ជាឪពុក ជាម្តាយ ជាមិត្តភក្តិរបស់វា ។ ធ្វើការងារឃោសនាអប់រំ ចលនាប្រពន្ធកូនឪពុកម្តាយទាហានខ្មាំងនោះ ដើម្បីអូសទាញទាហានខ្មាំង ។ បំផុសគ្រួសារទាហានខ្មាំង ដើម្បីទាមទារប្តីសី ឪពុកម្តាយរបស់ខ្លួន ដែលធ្វើទាហានខ្មាំងនោះ កុំឲ្យទៅច្បាំងឲ្យមករស់នៅក្នុងគ្រួសារធម្មតា ធ្វើជាប្រជាជនធម្មតា ។ នេះជាចលនាទាហានខ្មាំងមួយទៀត ដែលនាំឲ្យទាញខ្មាំង ឲ្យដណ្តើមខ្មាំងចេញពីសមរភូមិបាន ។ ក្រៅពីនេះ វិធីផ្សេងទៀត មិនសូវសក្តិសិទ្ធិប៉ុន្មានទេពីព្រោះខ្មាំងក្នុងការប្រយុទ្ធស្លាប់រស់ វាមិនងាយមកចូលយើងទេ ។ ដូច្នេះ យើងមិនយកចលនាទាហានខ្មាំងជាយុទ្ធសាស្ត្រទេ យើងយកការងារ ចលនាទាហាន ខ្មាំង ដើម្បីរួមផ្សំ ធ្វើឲ្យខ្មាំងវាខ្សោយមួយកម្រិតណាដែរ រួមផ្សំនឹងការវាយរបស់យើង ។ នេះសុំជម្រាបពីការងារចលនាទាហានខ្មាំង ហើយក៏យើងទទួលបានផលមួយចំនួនដែរ ។ **(នៅមានត)**



កងយោធាខ្មែរក្រហមនៅពហុកីឡដ្ឋានអូឡាំពិកក្នុងពិធីដ៏ធំមួយ ក្រោយពេលខ្មែរក្រហមទទួលបានជ័យជម្នះ

# ចម្លើយសារភាពរបស់ នួន រឿន ហៅ ទៀង អនុលេខាតំបន់៤២ ក្តាប់លេខាស្រុកចម្ការលើ

នួន រឿន ហៅ ទៀង អាយុ៣០ឆ្នាំ កើតនៅភូមិកន្ទែងរមាស ឃុំសំបួរមាស ស្រុកកំពង់សៀម តំបន់៤១ ។ ប្រពន្ធ ឈ្មោះ អ៊ិន ហេង ហៅ ផុន ធ្វើការនៅពេទ្យស្រុកចម្ការលើ ។ រឿន មានបងប្អូនពីរនាក់ ម្នាក់ឈ្មោះ អឿន បច្ចុប្បន្នប្រធានសហករណ៍ស្វាយទាប ស្រុកចម្ការលើ ។ ឪពុកឈ្មោះ នួន អេង អតីតឥស្សរៈ បច្ចុប្បន្ននៅចម្ការចេក កងពល១៧៤ ភាគកណ្តាល និងម្តាយឈ្មោះ កាក់ (ស្លាប់) ។ រឿន ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៧ ដោយចោទប្រកាន់ថា ជាខ្មែរ សេ.អ៊ី.អា បង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍ ។ នៅក្នុងនោះ រឿន ក៏បានរៀបរាប់ពីសកម្មភាពក្បត់របស់ខ្លួនជាមួយនឹងខ្មែរសន្ធាក់ចំនួន៤៣នាក់ ។ ចម្លើយសារភាពរបស់ នួន រឿន ហៅ ទៀង ត្រូវសួរបញ្ចប់នៅថ្ងៃ២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ដោយមានស្នាមផ្តិតមេដៃរបស់ រឿន ផ្ទាល់ និងមានឈ្មោះ ខន ជាអ្នកចម្លងសរុបចំនួនម្ភៃប្រាំបួនទំព័រ ។ ខាងក្រោមនេះ ជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ នួន រឿន ហៅ ទៀងៈ

ពីតូចមកនៅជាមួយឪពុកម្តាយរហូតដល់អាយុ១៨ឆ្នាំ ក្រោយពីម្តាយស្លាប់ ខ្ញុំក៏ទៅរស់នៅជាមួយឪពុកមា ។ គាត់ក៏យកខ្ញុំទៅឲ្យនៅវត្ត និងបួសនៅក្នុងវត្តអង្គ ក្នុងខេត្តកំពង់ចាម បានបួនឆ្នាំទើបសឹកមកនៅជាមួយគាត់វិញ ។

***សកម្មភាពមុនឆ្នាំ១៩៧០***

ឆ្នាំ១៩៦៤ ឈ្មោះ សាត ប្រធានចម្ការកៅស៊ូ (រត់ចូលព្រៃហើយ) ចូលមកអប់រំខ្ញុំនៅក្នុងភូមិពីបដិវត្តន៍ដោយយកឯកសារតស៊ូវណ្ណៈមកអប់រំ ហើយក៏ចាត់តាំងខ្ញុំធ្វើជានីរសាររបស់គាត់ និងធ្វើការនៅក្នុងភូមិ ។ ឆ្នាំ១៩៦៧ សាត បានបញ្ចូលខ្ញុំជាយុវកក ។ ឆ្នាំ១៩៦៨ បានចូលព្រៃនៅព្រៃស្រក ខ្ញុំមានជំងឺគ្រុនចាញ់ក៏បានសុំសាត មកព្យាបាលជំងឺនៅក្នុងភូមិវិញ ។ ឆ្នាំ១៩៦៩ ពេលខ្ញុំស្នាក់នៅវត្តកងតាណឹង (កំពង់ចាម) ខ្មាំងចាប់ខ្ញុំដាក់នៅគុកបេអេស ភូមិភាគបានមួយខែក៏បញ្ជូនខ្ញុំមកដាក់នៅគុកព្រៃសរ ។ កន្លះខែក្រោយមក ក៏ឃើញឈ្មោះ លីន អនុលេខាស្រុកបារាយណ៍ (បច្ចុប្បន្នអង្គការចាប់ហើយ) និង គូ កូនសិស្សនៅកំពង់ចាម (បច្ចុប្បន្នក្តាប់មិនបាន) ដែលនៅភូមិស្រុកជិតគ្នាទៅជាប់គុកជាមួយខ្ញុំដែរ ។

ខ្ញុំ និង គូ តាមរយៈ លីន ក៏មានការជិតស្និទ្ធគ្នា ព្រោះនៅក្នុងគុកមិនមានស្គាល់គេ ក្រោយមកក៏អ្នកយាមគុកបញ្ចេញអ្នកទោសឲ្យធ្វើស្មៅជុំវិញគុក ។ ខ្ញុំ, លីន និងគូ ធ្វើការនៅជុំគ្នា ពេលនោះក៏មានឈ្មោះ ម៉ន ពាក់ដោយ៣ជាន់ បានហៅខ្ញុំទាំងបីទៅអង្គុយលេងនៅសំយាបផ្ទះគាត់នៅខាងកើតបរិវេណគុក ។ គាត់សួរនាំ ខ្ញុំទាំងបីមកស្រុកភូមិនៅឯណា? រឿងអីបានជាមកជាប់គុក? ខ្ញុំទាំងបីប្រាប់ពីភូមិស្រុក និងរឿងដែលជាប់គុកមកពីការប្រឆាំងរាជការ ។ ម៉ន ថាអីចឹងហើយឯងចូលព្រៃធ្វើក្រហមចង់ដូចចិន យួន មិនជឿរាជការ? ខ្ញុំអាណិតណាស់ សុទ្ធតែក្មេងដូចប្អូនហ្នឹង បើប្អូនឯងទាំងអស់ចូលបម្រើជាតិវិញនោះពិតជាខ្លាំងណាស់ ដូច្នេះប្អូនឯងទាំងអស់ចង់តស៊ូអី? បើកម្លាំងខាងរាជការច្រើនយ៉ាងនេះ មាននៅគ្រប់ទីកន្លែងទាំងអស់ ។ គាត់និយាយ ប៉ុណ្ណឹងក៏ឲ្យខ្ញុំទៅធ្វើការវិញ ។ ប្រាំថ្ងៃក្រោយមក គាត់ហៅខ្ញុំទៅជួបគាត់នៅកន្លែងដដែលទៀត ត្រូវជាថ្ងៃអាទិត្យផង ការអប់រំ គាត់ដូចមុនដែរ តែបន្ថែមថា របបគ្រប់គ្រងរបស់សង្គមរាស្ត្រនិយម មានការសប្បាយហ៊ឺហារតាមចិត្ត ឯខាងបដិវត្តន៍ដូចប្អូនៗឯងធ្វើនោះវាគ្មានទៅមុខរួចទេ ។ ម៉ន ក៏ចាត់តាំងឲ្យខ្ញុំទាំងបីធ្វើជាគិញ និងប្រាប់ទៀតថា បើអាចពិនិត្យទៅឃើញអ្នកណាកសាងចាត់តាំងជាគិញបានត្រូវចាត់តាំងឲ្យជួយធ្វើបន្តទៀត ។ ម៉ន តែងតែជួយផ្តល់ការស៊ីចុកឲ្យខ្ញុំទាំងបី ។ ម៉ន ក៏សួរបញ្ជាក់ខ្ញុំទាំងបីថា បើប្អូនទាំងបីនាក់ស្ម័គ្រចិត្តចង់បម្រើប្រទេសជាតិខាងយោធាក៏បាន តាមក្រសួងណាក៏បាន តាមសមាសភាពខ្លួន ។

ចុងឆ្នាំ១៩៦៩ ឈ្មោះ ម៉ន បានហៅខ្ញុំទាំងបីទៅផ្ទះគាត់ ពេលនោះខ្ញុំឃើញមានឈ្មោះ ភា សក្តិ៣ គុកព្រៃសរ និងស្បោង វ៉ា សក្តិ៤ គុកព្រៃសរ និងមានរៀបចំពិធីបញ្ចូលខ្ញុំទាំងបីជា សេ.អ៊ី.អា

ដោយមានទង់មួយពណ៌ក្រហមលឿង មានសញ្ញាបេះដូងនៅចំពាក់កណ្តាលពណ៌លឿង ផ្កាយ៣ពីលើផង ។ ដំបូងសក្តិ៣ ភា ឡើងខទ្រុសនាមបញ្ចូលខ្ញុំទាំងបីជាសមាជិក សេ.អ៊ី.អា និងស្បោង វ៉ា ឡើងទទួលស្គាល់ខ្ញុំទាំងបីនាក់ ។ ស្បោង វ៉ា ប្រគល់ភារកិច្ចឲ្យអនុវត្តមានៈ

១) កសាងកម្លាំង សេ.អ៊ី.អា ។

២) បន្តពិនិត្យតាមដានខ្មែរក្រហម ។

៣) ឃោសនាពីរបបលោកសេរីនៅតាមកន្លែងរស់នៅ ។

## សកម្មភាពក្រោយរដ្ឋប្រហារឆ្នាំ១៩៧០

បន្ទាប់មកប្រកាសឲ្យខ្ញុំទាំងបីធ្វើការទាក់ទងជាមួយគាត់ ។ ខ្ញុំទាំងបីនាក់គោរពទង់ សេ.អ៊ី.អា ប្តេជ្ញាចិត្ត ។ ខែមីនា ឆ្នាំ១៩៧០ អ្នកទោស៤០០នាក់ត្រូវបានរួចទៅផ្ទះវិញ ។ ដោយឡែកខ្ញុំទាំងបីត្រូវ ស្បោង វ៉ាង ហៅទៅណែនាំថា ទាំងបីនាក់ទៅផ្ទះវិញត្រូវធ្វើការទាក់ទងគ្នាឲ្យបានជាប់ ហើយត្រូវរាវរកខ្សែ សេ.អ៊ី.អា នៅកន្លែងនោះតទៅទៀត ព្រោះកម្លាំង សេ.អ៊ី.អា យើងបានចេញទៅបង្កប់នៅតាមជនបទច្រើនដែរហើយ ។

ខែកក្កដា ឆ្នាំ១៩៧០ ខ្ញុំទាំងបីក៏បានបបួលគ្នាចូលទៅបង្កប់ខ្លួននៅក្នុងបដិវត្តន៍ទៀត តាមរយៈឈ្មោះ ឈឿន បញ្ជូនខ្ញុំឲ្យមកនៅមន្ទីរ ក-២៥ នៅជាមួយឈ្មោះ ឌឿន ពាណិជ្ជកម្មរដ្ឋ (អង្គការចាប់ហើយ) ។ ឌឿន ណែនាំថា សភាពការណ៍ឥឡូវនេះ តាមមូលដ្ឋានក៏យុវជន យុវនារី កំពុងតែចូលបដិវត្តន៍ច្រើនណាស់ ។ ឯកម្លាំងយើងវិញក៏បានចូលបង្កប់ក្នុងជួរបដិវត្តន៍រហូតដល់មាននាទីដឹកនាំក្នុងបដិវត្តន៍ ខ្លះ ឯបដិវត្តន៍ក៏ មិនដឹងថាមានកម្លាំងចូលបង្កប់ដែរ ។ ដូច្នេះកម្លាំងយើងដែលបានមកជួបគ្នានេះ ឥឡូវយើងត្រូវចុះទៅតាមមូលដ្ឋាន តាមភូមិវិញដើម្បីយើងធ្វើការកសាងកម្លាំងសេ.អ៊ី.អា បន្តទៅទៀត ។ ណែនាំរួចហើយក៏ចាត់តាំងឲ្យ លីន ចុះទៅនៅភូមិកំណើតរបស់គាត់នៅភូមិវិហារធំវិញ គូ ទៅភូមិសូភាព ហើយខ្ញុំគាត់ចាត់តាំងឲ្យនៅក្រុមនីសាររបស់គាត់សម្រាប់នាំសំបុត្រ ។ ឯការទាក់ទង គាត់ឲ្យទាក់ទងគ្នាជាប់មកនឹងគាត់ផ្ទាល់ ចំពោះកម្លាំងដែលនៅជាមួយគាត់ឲ្យខ្ញុំទាក់ទងជាមួយនឹងឈ្មោះ បេង ។

ចុងឆ្នាំ១៩៧១ ឌឿន ចាត់តាំងឲ្យខ្ញុំក្តាប់ក្រុមនីសារដប់ពីរនាក់ ព្រមជាមួយនោះខ្ញុំកសាងកម្លាំងបានម្នាក់ឈ្មោះ ដេង (បច្ចុប្បន្នស្លាប់) ។ ឌឿន ចុះមកសមរភូមិកំពង់ធំ ខ្ញុំនៅមន្ទីរស្រែវាល ស៊ីងត្រង់តែមានភារៈទំនាក់ទំនងមកគាត់ផ្ទាល់ ។ ខែមីនា ឆ្នាំ១៩៧១ ឌឿន ហៅខ្ញុំទៅជួបនៅសមរភូមិកំពង់ធំ គាត់សួរខ្ញុំថា ការងាររកសាងកម្លាំងកន្លងមកបានយ៉ាងណាហើយ? ខ្ញុំរាយការណ៍ថា សព្វថ្ងៃកសាងបានឈ្មោះ ដេង ម្នាក់ ហើយក្រៅពីហ្នឹងខ្ញុំកំពុងតែតាមដានបន្តទៀត ។

ឌឿន ណែនាំថា ឥឡូវខំជំរុញការកសាងបន្តទៀត ព្រោះលទ្ធភាពមានច្រើនណាស់ ។ ឯសមមិត្ត ហូ នៅមន្ទីរបិតផ្លូវ និងលីន ក៏រៀងយកចិត្តទុកដាក់ទៅទាក់ទងឲ្យគេខំកសាងកម្លាំងឲ្យបាន ហើយឲ្យបញ្ជូនមកឲ្យខ្ញុំនៅ ខាងមុខ ។

ខ្ញុំក្តាប់បានបញ្ហានេះក៏មកប្រាប់ ហូ ឲ្យទៅជួប ឌឿន នៅសមរភូមិកំពង់ធំ ឯការទាក់ទងគ្នានេះមាន រហូតដល់ឆ្នាំ១៩៧២ ។ ឆ្នាំ១៩៧២ ឌឿន ដកខ្ញុំពីក្រុមនីសារឲ្យមកនៅមូលដ្ឋានវិញជាផ្លូវការឲ្យខ្ញុំមកទាក់ទងជាមួយនឹងឈ្មោះ យី ស៊ុន ជាលេខាស្រុកស្ទឹងត្រង់ ។ ការទាក់ទង ឌឿន ណែនាំឲ្យ ខ្ញុំទាក់ទងមក លីន នឹងគាត់ផ្ទាល់តែម្តង ហើយក៏គាត់សរសេរសំបុត្រឲ្យទៅ យី ស៊ុន ចាត់តាំងខ្ញុំឲ្យមកនៅធ្វើប្រធានភូមិស្តង់ក្រញ៉ាង ។ ការដកខ្ញុំចុះមកមូលដ្ឋានភារកិច្ចសំខាន់កសាងកម្លាំង ។

ពេលខ្ញុំមក យី ស៊ុន បានចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានភូមិស្តង់ក្រញ៉ាង តាមសំបុត្រ ឌឿន ។ តែខ្ញុំមិនមានការទាក់ទងរឿងក្បត់ជាមួយគាត់ទេគឺធ្វើការងារបដិវត្តន៍ជាមួយគ្នាធម្មតា ។

រយៈពេលដែលខ្ញុំនៅធ្វើជាប្រធានភូមិ ដោយមានផែនការពីឌឿន ខ្ញុំកសាងកម្លាំងពីរនាក់មានឈ្មោះ ញឹម អតីតកម្មករចម្ការកៅស៊ូបារាំងចម្ការអណ្តូង បច្ចុប្បន្នប្រជាជននៅភូមិស្តង់ក្រញ៉ាងស្រុកចម្ការលើ តំបន់៤២ និងអឿន អតីតធ្វើការនៅចម្ការកៅស៊ូបឹងកេតរបស់បារាំង បច្ចុប្បន្នជាប្រជាជននៅភូមិស្តង់ក្រញ៉ាង ។

ការអប់រំសំខាន់របស់ខ្ញុំលើកយករបបសេរីបំពាក់ឲ្យគេយល់ ដោយរស់ជាឯកជន មិនចង់ធ្វើការពីរបីថ្ងៃក៏មិនជាអ្វីដែរ ។ បើធ្វើបដិវត្តន៍វិញសុទ្ធតែគេបង្ខំទាំងអស់ ។ ការអប់រំនេះអស់រយៈពេលជាច្រើនដង ទើបទាំង ពីរនាក់យល់ព្រម ។ ខ្ញុំក៏ទៅរាយការណ៍ឲ្យបង ឌឿន នៅសមរភូមិកំពង់ធំដឹង បងឌឿន ណែនាំថា ឲ្យខ្ញុំតាមដានបន្តទៀតទៅកុំអាលឃើញគេសកម្មមួយភ្លែតៗ ចេះតែចាត់តាំងប្រយ័ត្នបែកការ ។ ពេលខ្ញុំត្រឡប់មកវិញក៏ ខ្ញុំទៅជួប លីន នៅវិហារធំដើម្បី

សួរតើខាង លីន អនុវត្តយ៉ាងណាហើយ ការងារកសាងកម្លាំងមានពិសោធន៍យ៉ាងណា? និងយកការណែនាំពី ឌឿន ទៅណែនាំប្រាប់ខ្លះគឺជំរុញការកសាងកម្លាំងឲ្យបានខ្លាំង ព្រោះលទ្ធភាពនៅកន្លែងនោះអាចកសាងបានច្រើនទៀត ។ ជាមួយការងារបដិវត្តន៍នោះ ខ្ញុំក៏តែងតែហៅឈ្មោះ ញឹម និងអឿន មកពង្រឹងឲ្យជាប់ដែរ ។

ឆ្នាំ១៩៧៣ យី ស៊ុន ក៏ត្រូវផ្លាស់ចេញពីស្រុកស្ទឹងត្រង់ទៅឯ ឌឿន នៅសមរភូមិកំពង់ធំ ។ គាត់ក៏នាំឈ្មោះ សាត មកឲ្យទទួលខុសត្រូវលេខាស្រុកនេះ គាត់បានរៀបចំឲ្យមកបង្កប់នៅតាមស្រុកនីមួយៗដើម្បីធ្វើសកម្មភាព ព្រោះ សាត បានទទួលតាំងពីនៅសមរភូមិកំពង់ធំមកម្ល៉េះ ដូច្នេះនៅក្នុងស្រុកនេះធ្វើសកម្មភាពទាក់ទងជាមួយនឹង សាត ចុះ ។

បន្ទាប់មក សាត ក៏ដកខ្ញុំឲ្យធ្វើប្រធានកសិកម្មស្រុកស្ទឹងត្រង់ ដោយណែនាំថា ទៅកន្លែងនោះត្រូវយកចិត្តទុកដាក់កសាងកម្លាំងឯគាត់ក៏បោះមន្ទីរនៅអណ្តូងស្វាយ និងខំកសាងកម្លាំងដែរ ។

ពេលខ្ញុំធ្វើជាកសិកម្មនៅស្រែសង្កែ មានកម្លាំងសាមសិបនាក់ទាំងនារី ទាំងបុរស ។ ការងារខ្ញុំនៅពេលនោះសំខាន់យកចិត្តទុកដាក់កសាងតាមការណែនាំពី សាត ។ កម្លាំងដែលកសាងបានពីរនាក់មាន រុង អតីតប្រជាជន អ្នកដាំបន្លែ បច្ចុប្បន្នប្រធានក្រុមកសិកម្មស្រុកស្ទឹងត្រង់ និងយាន ឆ្នាំ១៩៧០ ជាប្រធានភូមិព្រះអណ្តូង ដោយស៊ីសំណូក បញ្ចេញសេដ្ឋកិច្ចឲ្យខ្មាំង ក៏ត្រូវប្រជាជនទម្លាក់ ។ ក្រោយមក ក៏មកនៅកសិកម្មស្រុកស្ទឹងត្រង់ (បច្ចុប្បន្ននៅដដែល) ។ ខ្ញុំតែងតែលើកយករបបខាងសេរី ការរស់នៅស្រួល កសិកម្មនៅប្រទេសសេរីមានការជឿនលឿនយកមកប្រៀបធៀបនឹងការធ្វើបដិវត្តន៍ មានចាត់តាំងជាសហករណ៍តូចៗ ធ្វើការរួមពិបាក សត្វពាហនៈការប្រមូលមកដាក់រួម បុណ្យទានក៏មិនឲ្យធ្វើ ។ ការអប់រំនេះមានរយៈពេលយូរទើបពីរនាក់នេះមានជំនឿលើខ្ញុំ ។ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៣ ទើបខ្ញុំប្រគល់ភារកិច្ចឲ្យធ្វើសកម្មភាពបំផ្លាញផលកសិកម្ម ។ ខែមីនា ឆ្នាំ១៩៧៣ ចំពោះនៅក្នុងប្រជាជន ខ្ញុំកសាងបានកម្លាំងពីរនាក់ដែលនៅជិតមន្ទីរខ្ញុំ គឺ យស់ ឆ្នាំ១៩៧០ ចូលធ្វើយោធាភូមិភាគ២០៣ បូពា៌ ខូចរឿងសីលធម៌រត់មកនៅផ្ទះវិញ បច្ចុប្បន្នប្រធានមុខព្រួញភ្ជួរស្រែនៅសហករណ៍សង្កែ ស្រុកស្ទឹងត្រង់ តំបន់៤២ និងធន អតីតធ្វើស្រែ បច្ចុប្បន្នអនុប្រធានកងចល័តសហករណ៍សង្កែ ។ ការអប់រំនេះ សំខាន់ខ្ញុំលើកយករបបសេរីមកធ្វើការប្រៀបធៀបនឹងការធ្វើបដិវត្តន៍សព្វថ្ងៃ ។ ដូច យាន និងរុងគឺខ្វឹមសារប្រហាក់ប្រហែលគ្នា ។ ខ្ញុំប្រគល់ភារកិច្ចឲ្យយកចិត្តទុកដាក់កសាងកម្លាំងយុទ្ធជននៅក្នុងមូលដ្ឋាន ដោយប្រើរូបភាពជិតស្និទ្ធជាមួយគ្នាដើម្បីដណ្តើមរដ្ឋអំណាចពីបដិវត្តន៍វិញ ។

ខែឧសភា ឆ្នាំ១៩៧៣ ខ្ញុំឡើងទៅរាយការណ៍ឲ្យ សាត នៅមន្ទីរអណ្តូងស្វាយអំពីកម្លាំងកសាងបានមានឈ្មោះដូចខាងលើ ។ សាត ជួយជាមតិមកខ្ញុំថា កម្លាំងនេះយើងអប់រំបន្តទៀត ចាំទៅថ្ងៃមុខចាំបញ្ចូលជា សេ.អ៊ី.អា ព្រោះឥឡូវនេះធ្វើថ្មីណាស់ តាមដានមួយរយៈសិន ។ បន្ទាប់មកទៀត សាត ថាគាត់កសាងបានតែ បីនាក់ទេមានឈ្មោះ ធឿន អតីតអ្នកបើកលុយកម្មករចម្ការកៅស៊ូបារាំងបឹងកេត បច្ចុប្បន្នជាសមាជិកគណៈកម្មាធិការមន្ទីរស្រុកស្ទឹងត្រង់ តំបន់៤២, សឿ អតីតក្តាប់មិនបានទេ បច្ចុប្បន្នធ្វើឆ្មោះចាប់ត្រីនៅខ្ពបតាងួន ស្រុកស្ទឹងត្រង់ និងផាត អតីតក្តាប់មិនបាន បច្ចុប្បន្នលេខាសហករណ៍ពាមកោះស្នា ស្រុកស្ទឹងត្រង់ ។

ពេលលើកទំនប់នៅស្រែសង្កែជាមួយប្រជាជន ខ្ញុំបានណែនាំ យស់ និងធន ឲ្យនាំកម្លាំងទៅធ្វើការនៅចម្ការដីខាងលើរហូតដល់ពេលធ្លាក់ភ្លៀង បានខ្ញុំឲ្យនាំកម្លាំងមកលើកទំនប់វិញ ជាលទ្ធផលចម្ការក៏មិនបានធ្វើទំនប់ក៏មិនបានធ្វើឯនៅក្នុងសហករណ៍ ។ ខ្ញុំបំផុសកម្លាំងយុវជន យុវនារីឲ្យទាមទាររៀបគ្រួសារតាំងពីអាយុ១៨ឆ្នាំដើម្បីកុំឲ្យចូលធ្វើកងទ័ពបដិវត្តន៍ ។ ធឿន, សឿ និង ផាត ខ្ញុំក៏មកទាក់ទងតាមការផ្តាំផ្ញើពី សាត តែការទាក់ទងសំខាន់សួរថាតើធ្វើសកម្មភាពយ៉ាងម៉េចកន្លងមក និងជួយរំពុកកសាងកម្លាំង ។ ចំពោះ លីន គិតតែធ្វើសកម្មភាពខ្ញុំជាមួយ យស់ ក៏ស្នើ សាត ឲ្យ លីន ទៅជួបនៅស្រុកកំពង់សៀម ហើយ សាត ក៏សម្រេចឲ្យទៅ ។ ក្រោយខ្ញុំក៏នាំ លីន មកជួប សាត ដើម្បីឲ្យ សាត ជួយណែនាំបន្ថែមទៀត ។ ខែសីហា ឆ្នាំ១៩៧៣ សាត ខ្ញុំ និងអឿន នៅស្ពង់ក្រញ៉ាង បានរៀបបញ្ចូល យស់, យាន, រុង និងធន ជាសេ.អ៊ី.អា នៅនឹងមន្ទីររបស់ខ្ញុំ ។ ឆ្នាំ១៩៧៤ សាត ផ្លាស់ចេញពីស្រុកស្ទឹងត្រង់ទៅនៅចម្ការកៅស៊ូចម្ការអណ្តូងវិញ ហើយឈ្មោះ ឈឿន ក្រោយរំដោះនៅពាណិជ្ជកម្មភ្នំពេញ (អន្តការចាប់ហើយ) មកទទួលនាទីលេខាស្រុកស្ទឹងត្រង់លេខាតំបន់៣៣ ផង ។

សាត បានប្រាប់ឲ្យខ្ញុំទាក់ទងនឹង ឈឿន ព្រោះកម្លាំងនោះក៏បង ឡឿនចាត់តាំងឲ្យមកដូចគាត់ដែរ ឥឡូវ ទៀងឯងធ្វើការជាមួយ ឈឿន ទៅ មិនបាច់ទៅទាក់ទងគាត់ទៀតទេ ។ បងឈឿន មានមតិថា យើងរស់នៅពីសង្គម យើងមានសិទ្ធិសេរីភាពគ្រប់គ្រាន់ ឯនៅសង្គមបដិវត្តន៍វិញ មិត្តមើលចុះ គាបតៀ្យតណាស់ គ្មានសិទ្ធិសេរីភាពអីទេ ។ ដូច្នេះបំណងដែលយើងធ្វើនេះដើម្បីវាយបដិវត្តន៍ទៅថ្ងៃមុខ ជាចាំបាច់ត្រូវកសាងកម្លាំងឲ្យបានច្រើន ។ ខែកុម្ភៈ ឆ្នាំ១៩៧៨ បងឈឿនដកខ្ញុំពីកសិកម្មឲ្យមកទទួលជាលេខាសង្កាត់ឧបតាដួន ។ ខែមីនា ឆ្នាំ១៩៧៨ ឈឿន បានទៅពិភាក្សាជាមួយខ្ញុំអំពីគម្រោងផែនការ គឺបង្កើតកងទ័ពចោរព្រៃមួយកងឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍នៅសមរភូមិក្រោយ ដើម្បីបន្ធូរកម្លាំងបដិវត្តន៍វាយខ្មាំងនៅសមរភូមិមុខ ។ តាមការពិភាក្សាសម្រេចថា រៀបចំធ្វើដោយប្រមូលកម្លាំងយុទ្ធជននៅតាមមូលដ្ឋានមកបំពាក់អប់រំជាកម្លាំង ។

រហូតដល់ខែមេសា ឆ្នាំ១៩៧៨ ប្រមូលកម្លាំងបានយុទ្ធជននៅតាមមូលដ្ឋានបានមួយកងអនុសេនាតូច តែការប្រមូលតាមមូលដ្ឋានមិនជាផ្លូវការទេ មកដល់កន្លែង ឈឿន ក៏អប់រំឲ្យទៅជាកម្លាំងប្រឆាំងនឹងបដិវត្តន៍ តែសំខាន់ ឈឿន និងខ្ញុំអប់រំបីនាក់ឲ្យក្តាប់មានឈ្មោះ រិន (ស្លាប់) , ហៃ (ស្លាប់) , និងធឿន (ស្លាប់) ដែលជាអ្នកនៅក្នុងមន្ទីររបស់ ឈឿន ។ បីនាក់នេះ ដឹកនាំកងទ័ពឲ្យទៅវាយខ្មាំងនៅសមរភូមិមុខសិន ដើម្បីឲ្យបានកាន់កាំភ្លើងសិន ។ ពេលនោះក៏ចាត់តាំងឲ្យបីនាក់នោះនាំកម្លាំងទៅវាយខ្មាំងនៅសមរភូមិកំពង់ធំ ឈឿន ក៏ចាត់តាំងឲ្យ បេង យកកាំភ្លើងបើកឲ្យកាន់គ្រប់ៗគ្នា ហើយ រិន, ហៃ និងធឿន ជាអ្នកបំផុសឲ្យរត់ពីមុខមកខាងក្រោយវិញ ។

ដល់ក្រោយមកក៏មានកម្លាំងនោះរត់មកសមរភូមិក្រោយជាបន្តបន្ទាប់ ខ្ញុំបានប្រមូលមកអប់រំបានម្ភៃប្រាំនាក់ ហើយឲ្យ រិន, ហៃ និង ធឿន មកក្តាប់រួចក៏បញ្ជូនឲ្យទៅនៅក្នុងព្រៃឈើទើ ក្នុងស្រុកស្ទឹងត្រង់ ហើយជាអ្នកផ្តល់ស្បៀង ។ ក្រោយមក ឈឿន និង ខ្ញុំក៏ចូលទៅចាត់តាំងឲ្យ ហៃ, ធឿន និង រិន នាំកម្លាំងមកធ្វើសកម្មភាពបាញ់នៅមន្ទីរតំបន់៤២ចាស់ នៅម្តុំបែកអន្លង់ ។ ពេលនោះក៏ទៅបាញ់បណ្តាលឲ្យស្លាប់អ្នកយាមពីរនាក់ និងចាត់តាំងឲ្យស្ទាក់បាញ់កង់ ម៉ូតូនៅតាមផ្លូវកែងបិតធ្លូ ដែលមានកម្មាភិបាលបដិវត្តន៍ធ្វើដំណើរតាមផ្លូវ ហើយក៏បានបាញ់ស្លាប់នីរសារម្នាក់ ។ ក្រោយមកទៀត ខ្ញុំបានទៅជាមួយគ្នា ហៃ, រិន និងធឿន នាំកម្លាំងទៅវាយឈ្លបនៅមន្ទីរសង្កាត់អូរម្លូ គឺបានមកឈ្លបបាញ់ពីរដង ដោយសកម្មភាពញឹកញាប់ពេកក៏ត្រូវយោធាតំបន់ ៤២ ឡើងទៅវាតត្បាត ។ សកម្មភាពនេះត្រូវស្ងាត់មួយរយៈរហូតដល់ខែមិថុនា ឆ្នាំ១៩៧៨ ខ្ញុំនាំកម្លាំង ទៅបាញ់មន្ទីរសង្កាត់អូរម្លូម្តងទៀត គឺព័ទ្ធចាប់បានប្រធានសង្កាត់ម្នាក់ឈ្មោះ មិត យកទៅកម្ទេច ។ ឯកម្លាំងធ្វើសកម្មភាពនេះសព្វថ្ងៃនៅសល់តែឈ្មោះ ផល បច្ចុប្បន្នចូលមកសារភាពប្រធានភូមិនៅឃុំឈើទើ ស្រុកស្ទឹងត្រង់ តំបន់៤២ និង ឆាន បច្ចុប្បន្នចូលមកសារភាពប្រធានភូមិនៅឃុំឈើទើ ស្រុកស្ទឹងត្រង់ តំបន់៤២ ។

អំពីការងាររបស់ខ្ញុំនៅក្នុងសង្កាត់ឧបតាដួន ខ្ញុំកសាងបានឈ្មោះ រ៉េន អតីតសិស្សថ្នាក់ទី៧ បច្ចុប្បន្នប្រធានពាណិជ្ជកម្មសហករណ៍ឧបតាដួន ស្ទឹងត្រង់ និង នុន អតីតធ្វើចម្ការ បច្ចុប្បន្នប្រធានសហករណ៍ឧបតាដួន ស្រុកស្ទឹងត្រង់ តំបន់៤២ ដោយខ្ញុំតែងតែយកចិត្តទុកដាក់ ស្និទ្ធស្នាលខាងមនោសញ្ចេតនា និងអប់រំតាមដានអស់រយៈប្រាំមួយខែទើបអប់រំបាន ។ រហូតដល់ចុងឆ្នាំ១៩៧៨ ខ្ញុំបានរាយការណ៍ឲ្យ ឈឿន ហើយគាត់ក៏ណែនាំមកវិញឲ្យរៀបចំបញ្ចូលជា សេ.អ៊ី.អា ដែលមាន ឈឿន, ខ្ញុំ និងអឿន ជាអ្នកបញ្ចូលពីរនាក់នេះ ហើយក៏ប្រគល់ភារកិច្ចឲ្យដូចអ្នកមុនៗ ។

ឈឿន ណែនាំឲ្យខ្ញុំខំពិនិត្យមើលសមាសភាពអ្នករកស៊ីលក់ដូរ និងពាក់ព័ន្ធផ្នែកនយោបាយថែមទៀត ដើម្បីអប់រំជាកម្លាំង ។ ក្រោយមកកម្លាំងដែលនៅក្នុងព្រៃក៏មានឈ្មោះ ឆេង រត់ចេញមករាយការណ៍ឲ្យប្រធានភូមិ ប្រធានភូមិក៏រាយការណ៍ឲ្យទៅយោធាតំបន់៤២ យោធាតំបន់ទៅព័ទ្ធបាញ់រត់បែកគ្នារហូតសព្វថ្ងៃ ។ ខ្ញុំឃើញបញ្ហាដូច្នេះក៏ទៅរាយការណ៍ឲ្យ ឈឿន ដឹង ។ បញ្ហានេះទុកមួយកន្លែងសិនចុះ ឥឡូវយើងធ្វើសកម្មភាព ខាងសហករណ៍ម្តង ។ ជាទិសអនុវត្តឲ្យធ្វើសហករណ៍តែត្រឹមដប់ប្រាំគ្រួសារសិនទេ ។ ជាសកម្មភាពរបស់យើង ត្រូវរៀបចំចាត់តាំងជាសហករណ៍មួយភូមិតែម្តង ប្រមូលទាំងមនុស្ស ទាំងសត្វ ដាក់រួមឲ្យអស់ នៅតាមមាត់ទន្លេ យើងកុំចាត់តាំងជាសហករណ៍ គឺចាត់តាំងជាក្រុមប្រវាស់ដៃបានហើយ ដើម្បីប្រឆាំងមាគ៌ារបស់បក្ស ។ ក្រោយពីមានការណែនាំមក ខ្ញុំក៏យកបញ្ហាទៅអនុវត្តក្នុងសង្កាត់ទាំងមូល ដោយគ្មាន

ការបាត់តាំងដឹកនាំត្រឹមត្រូវ ធ្វើឲ្យច្របូកច្របល់ក្នុងសហករណ៍ ។ ខែសីហា ឆ្នាំ១៩៧៤ ឈឿន ណែនាំថា ឥឡូវបើការបាត់តាំងសហករណ៍មានការច្របូកច្របល់ហើយ យើងត្រូវរំសាយឲ្យទៅជាឯកជនវិញទៅ ។

ក្រោយពីគាត់ណែនាំមក ខ្ញុំក៏រំសាយសហករណ៍ភូមិបឹងទាំងមូលឲ្យទៅជាឯកជនវិញ តែក្រៅពីនោះខ្ញុំមិនទាន់ហ៊ានរំសាយទេ ។ ខ្ញុំរាយការណ៍ឲ្យ ឈឿន ថារំសាយបានមួយភូមិហើយ ឈឿន បានណែនាំថា យើងធ្វើនេះក្នុងគោលបំណងប្រឆាំងមាគ៌ាបក្ស កុំឲ្យសហករណ៍របស់បដិវត្តន៍ទៅមុខរួច ។ បន្ទាប់ពីនោះ ខ្ញុំណែនាំ នុន ឲ្យយកស្រូវធ្វូន់ទៅស្ទូងនៅដីទួលឲ្យខូចអស់ម្ដៅហិកតា និង រ៉ែន ខ្ញុំណែនាំឲ្យស្ដុកទុកសម្ភារ ដូចជា ក្រណាត់ទុកឲ្យខូចអស់ដប់គីអំបិលដប់បាវ ដោយបណ្ដោយឲ្យត្រូវទឹកភ្លៀងខូច ហើយសម្ភារដែលមានគឺណែនាំមិនឲ្យយកទៅចែកឲ្យប្រជាជនទេ ។

ដើមឆ្នាំ១៩៧៥ ឈឿន ផ្លាស់មកមន្ទីរ១៣០ របស់ភាគឧត្ដរចាស់ ហើយចូលឈ្មោះ អឿន ជាលេខាតំបន់៤២វិញ មកក្ដាប់លេខាស្រុកស៊ីងត្រង់វិញ ។ ពេលនោះ ឈឿន បានប្រាប់ខ្ញុំថា អឿន មិនដឹងយ៉ាងណាទេ គាត់ក្ដាប់មិនបានដែរ ។ ឯការទាក់ទងទៀង ឯងត្រូវធ្វើការទាក់ទងជាមួយឈ្មោះ ឌុល ជា សមាជិកស្រុកស៊ីងត្រង់ខាងលើ បច្ចុប្បន្នលេខាសង្កាត់ ហើយកម្លាំងចាស់ក៏ត្រូវពង្រឹងថែមទៀត ទោះអ្នកក្រៅចូលមកក្ដាប់នៅស្រុកនេះក៏ដោយ ។

ខែមីនា ឆ្នាំ១៩៧៥ អឿន ដកខ្ញុំមកឲ្យទទួលលេខាសង្កាត់អារក្សត្នោតវិញ ក្នុងស្រុកស៊ីងត្រង់ដដែល ។ ក្នុងឱកាសនេះ ខ្ញុំបានទៅពិភាក្សាការងាររកសាងកម្លាំងតើយ៉ាងម៉េចនៅមន្ទីររបស់ ឌុល តើឲ្យខ្ញុំកសាងកម្លាំងទៀត ឬមិនឲ្យកសាង ព្រោះខ្ញុំត្រូវផ្លាស់ចេញពីខ្ពបតាដួនហើយមកនៅសង្កាត់អារក្សត្នោតវិញហើយ ។ ឌុល មានមតិថា កម្លាំងកសាងទៀតចុះ តែត្រូវប្រុងប្រយ័ត្នឲ្យបានខ្ពស់ប្រយ័ត្នបែកការណ៍សម្ងាត់យើង ។ បន្ទាប់ពីនេះ ឌុល ខទ្មេសនាមខ្សែដែលកម្លាំងគាត់ទើបកសាងបានដើម្បីឲ្យខ្ញុំធ្វើការទាក់ទងមាន លី អតីតប្រជាជន បច្ចុប្បន្នប្រធានកងធំសហករណ៍ស្រែវាល ស្រុកស៊ីងត្រង់, ស្រ៊ាង អតីតប្រជាជន បច្ចុប្បន្នគណៈកម្មាធិការសង្កាត់ស្រែវាល និង ស៊ីម អតីតប្រជាជន បច្ចុប្បន្នជាអនុកម្មាធិការសង្កាត់ស្រែវាល ។

## សកម្មភាពក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥

ក្រោយរំដោះភ្លាម ឌុល និយាយប្រាប់ខ្ញុំថា កន្លងមកកសាងកម្លាំង គាត់បានទទួលផែនការពីឈ្មោះ គុល ហើយគាត់ទទួលខុសត្រូវលើយើងទៀត ។ ពេលនោះ ក៏នាំខ្ញុំ និងស៊ីម ទៅជួប គុល នៅមន្ទីរថ្នល់បំបែក ស្រុកចម្ការលើ ។ ឌុល ខទ្មេសនាមខ្ញុំ និង ស៊ីម ឲ្យ គុល ស្គាល់ ។ គុល ណែនាំពីសភាពការណ៍ថា បដិវត្តន៍ បានរំដោះទូទាំងប្រទេសហើយ តែកម្លាំងរបស់យើង ឥឡូវនេះបានចូលក្ដាប់មន្ទីរក្រសួងបានចង់អស់ហើយដែរ ដូច្នេះយើងឥឡូវត្រូវសម្រុកកសាងកម្លាំងឲ្យបានរហ័សដើម្បីតស៊ូប្រឆាំងបដិវត្តន៍ កុំឲ្យជិះជាន់ប្រជាជនតទៅទៀត ព្រោះបដិវត្តន៍បំបាត់ប្រពៃណីអស់ហើយ គ្មានសិទ្ធិសេរីភាពទេ ។ ខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំ និង ឌុល បានពិភាក្សាគ្នារៀបចំផែនការពង្រីកកម្លាំងដែលមានហើយឲ្យកសាងកម្លាំងថ្មីទៀតចំពោះកិច្ចការផ្សេងៗ ខ្ញុំ និង ឌុល ត្រូវឡើងទៅជួប គុល ផ្ទាល់ ។ ក្រោយពីពិនិត្យពិភាក្សាមក ខ្ញុំបានហៅ ធាន, រុង, យាន, រ៉ែន, អឿន, ធឿន និង ផាត មកប្រជុំនៅមន្ទីរកសិកម្មចាស់ខ្ញុំមុន ។ ចំពោះខ្លឹមសារខ្ញុំបានណែនាំទៅតាមអ្វីដែល គុល ដែលប្រាប់ខ្ញុំកាលពីលើកមុន ។

ខែកក្កដា ឆ្នាំ១៩៧៥ ឌុល, ខ្ញុំ, ស្រ៊ាង, លី និងស៊ីម បានទៅជួប គុល នៅកន្លែងដដែលទៀត ។ ខ្លឹមសារទៅជួបនេះ ខ្ញុំទាំងអស់គ្នាទៅរាយការណ៍ឲ្យ គុល ដឹងថាកម្លាំងរៀបចំកសាងហើយស្រេច ។ គុល មានមតិអប់រំប្រហាក់ប្រហែលមុនទៀត ណែនាំរក្សាការសម្ងាត់ឲ្យបានខ្ពស់មែនទែន ។ មួយរយៈក្រោយមក ខ្ញុំផ្លាស់មកនៅប្រធានពាណិជ្ជកម្មតំបន់៤២វិញ គឺទាក់ទង គុល ផ្ទាល់ ។ ឯកម្លាំងនៅមូលដ្ឋាន ខ្ញុំប្រគល់ឲ្យទៅ ឌុល គ្រប់គ្រងទាំងអស់ ។ ខ្ញុំនៅក្នុងពាណិជ្ជកម្ម គុល រៀបចំការងារឲ្យខ្ញុំធ្វើដោយណែនាំខ្ញុំយកចិត្តទុកដាក់កសាងកម្លាំងនៅក្នុងពាណិជ្ជកម្ម និងប្រជាជនដែលនៅជាប់ពាណិជ្ជកម្មផង ។ នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្មរបស់ខ្ញុំ ដែលមាន ៖ ជុន អតីតប្រធានសហករណ៍សង្កមចាស់ បច្ចុប្បន្នសមាជិកពាណិជ្ជកម្មតំបន់៤២ និង យ៉េត អតីតក្ដាប់មិនបាន បច្ចុប្បន្ននាទីអនុពាណិជ្ជកម្មតំបន់៤២ ។ ខ្ញុំស្នើ គុល ថាតើសមាសភាពពីរនាក់នេះយ៉ាងម៉េចដែរ? គុល ថាពីរនាក់នេះគាត់បានអប់រំខ្លះហើយ ឥឡូវមិត្តត្រូវអប់រំបន្តទៀត ។

ដល់ដើមឆ្នាំ១៩៧៦ ទើបខ្ញុំកសាងពីរនាក់នេះបាន និង យ៉ុន

អតីតសិស្សថ្នាក់ទី៥ បច្ចុប្បន្នធ្វើបញ្ជីពាណិជ្ជកម្ម តំបន់៤២ ។ រហូតដល់ខែ មេសា ឆ្នាំ១៩៧៦ តុល ក៏សម្រេចឲ្យចាត់តាំងបីនាក់ នេះជា សេ.អ៊ី.អា ដែលមានឈ្មោះ តុល, ខ្ញុំ និង ព្រាប ជាអ្នកបញ្ជូល ។ ខែកក្កដា ឆ្នាំ១៩៧៦ តុល ដកខ្ញុំឲ្យមកទទួលជាលេខាស្រុកចម្ការលើវិញ ឯកម្លាំងនៅពាណិជ្ជកម្ម ខ្ញុំប្រគល់ឲ្យ យ៉េត គ្រប់គ្រង ។ តុល ណែនាំឲ្យខ្ញុំធ្វើការទាក់ទងជាមួយ ជាវ លេខាស្រុកតាំងគោក (អង្គការចាប់ហើយ) និងបញ្ជាក់ទៀតថា ត្រូវកសាងកម្លាំងនៅមូលដ្ឋានចម្ការលើ ព្រោះស្រុកនោះប្រហែលមិនទាន់មានកម្លាំងយើងចូលដល់ទេ ។ ខ្ញុំចុះទៅស្រុកចម្ការលើតាមការណែនាំរបស់ តុល ។ ខ្ញុំយកចិត្តទុកដាក់ចុះទៅសង្កាត់ តាប្រុក និងចម្ការអណ្ដូង ព្រោះកន្លែងនេះច្រើនជាសាច់ឈាមរបស់ តុល និងភាគច្រើនកម្មករចម្ការកៅស៊ូបារាំងទាំងពីរសង្កាត់ ។ ខ្ញុំកសាងកម្លាំងបានមួយចំនួនមានៈ ហ៊ាង អតីតគ្រូបង្រៀន បច្ចុប្បន្នប្រធានសហករណ៍ តាប្រុក ស្រុកចម្ការលើ, វន អតីតកម្មករចម្ការកៅស៊ូចម្ការអណ្ដូង បច្ចុប្បន្នប្រធានសហករណ៍ភូមិដូនបុស, ម៉ន អតីតគ្រូបង្រៀនបច្ចុប្បន្នប្រធានសហករណ៍ភូមិចម្ការអណ្ដូង និង សៀម អតីតកម្មករចម្ការកៅស៊ូបារាំង បច្ចុប្បន្នប្រធានក្រុមសហករណ៍ប្រើសមាស ។

ដោយម្នាក់ៗសេរី ធ្លាប់មានប្រាក់ខែ មុខមាត់ បុណ្យសក្តិ ខ្ញុំយកបញ្ហានេះទៅបំផុស បើពីសង្គមចាស់ មានការរស់នៅស៊ីចាយហ៊ុហារ បានតាមចិត្ត ដូចសព្វថ្ងៃ បើបានធ្វើប្រធានក្រុម ប្រធានសហករណ៍ប៉ុណ្ណឹង បើពីសង្គមចាស់វិញមានប្រាក់ខែចាយយ៉ាងសប្បាយចិត្ត ។ ឥឡូវនេះធ្វើបដិវត្តន៍រកតែខោអាវ ស្លៀកមិនចង់បានផង ។ ការអប់រំជាញឹកញាប់ទាំងអស់សុទ្ធតែយល់ស្របតាមការអប់រំខ្ញុំទាំងអស់ ។ តែមិនទាន់ប្រគល់ភារកិច្ចឲ្យទេ ។ ក្រោយមកខ្ញុំរាយការណ៍ឲ្យ តុល ដឹងពីបញ្ហានេះ ។ តុល ជំរុញឲ្យខ្ញុំសម្រុកកសាងឲ្យមែនទែន នៅខាងតាប្រុក ។

ខែកញ្ញា ឆ្នាំ១៩៧៦ ខ្ញុំណែនាំឲ្យ ហ៊ាង ធ្វើសកម្មភាពបំផ្លាញសន្ទូង ដោយបំផុសឲ្យប្រជាជនស្ទូងបត់ដើម ទុកសំណាបឲ្យចាស់ខូចចោល ភ្ជួរកុំឲ្យសព្វដី និងលាយស្រូវពូជដាក់ស្រូវធ្ងន់លាយស្រូវស្រាល ។ ខែធ្នូ ឆ្នាំ១៩៧៦ តុល មកប្រជុំនៅកន្លែងម៉ោង៧យប់ ហើយអ្នកចូលរួមប្រជុំមាន ព្រាប, ជាវ និង ឌុល ។ ខ្លឹមសារ តុល លើកថា ផែនការរបស់យើងពីលើរហូតក្រោម មានផែនការធ្វើរដ្ឋប្រហាររំលំបក្សនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ ដើម្បីរំលំបក្សកុម្មុយនីស្តចេញ ហើយកម្លាំង សេ.អ៊ី.អា យើងកាន់អំណាចវិញ ។ រៀបចំចាត់តាំងគណៈកម្មាធិការទទួលធ្វើរដ្ឋប្រហារមានៈ

ក) តុល ទទួលរួមដឹកនាំខាងនយោបាយ ។

ខ) ឌុល ទទួលខាងចាប់ចង ពេលរដ្ឋប្រហារអ្នកមិនព្រមចុះចូល ។

គ) ខ្ញុំទទួលខាងឃោសនា អប់រំប្រជាជនកុំឲ្យមានការរំជើបរំជួលក្នុងពេលធ្វើរដ្ឋប្រហារ ។

ឃ) ព្រាប និង ជាវ ទទួលភារកិច្ចនីសារទាក់ទង ស្រេងពីកំពង់ចាមមក តុល តាមការកំណត់ផ្ទះនៅក្រុងកំពង់ចាមទៅជនបទ តែការធ្វើនេះមិនឲ្យផ្ទុះអាវុធទេ គឺកម្លាំងរបស់យើងអប់រំកន្ទុងមកត្រូវបំផុសឲ្យចាប់កម្មាភិបាលបដិវត្តន៍ណាដែលមិនព្រមដើរតាមយើងចាប់កម្ទេចចោលតែម្ដង ដូចជា (ពក ជាដើម) ។ បើអ្នកសារភាពយើងជាកម្លាំងអព្យាក្រឹត្យទេ យើងទុកតទៅទៀត ។

ដើមខែមករា ឆ្នាំ១៩៧៧ តាមដែលខ្ញុំបានស្នើសុំ តុល សម្រេចបញ្ចូល វន, ម៉ន, ហ៊ាង និង សៀម ជា សេ.អ៊ី.អា ដោយមាន តុល, ព្រាប និង ខ្ញុំជាអ្នកបញ្ចូល ។ ចាប់ពីឆ្នាំ១៩៧៧ អង្គការចេះតែមានវិធានការជាបន្តបន្ទាប់ខាងយោធា១៧៤ ភូមិភាគកណ្ដាល (មុនយោធាកងពល១១៧) ។ ខ្ញុំទៅជួប តុល ម្ដងទៀត ហើយ តុល ណែនាំថា ផែនការយើងដែលត្រូវធ្វើរដ្ឋប្រហារត្រូវផ្អាកសិន ព្រោះឥឡូវបដិវត្តន៍កំពុងមានវិធានការជាបន្តបន្ទាប់ ។ យើងចាំមើលសភាពការណ៍នៅខាងមុខទៀតសិន តើយ៉ាងណា? ឯសកម្មភាពរបស់យើងចេះតែធ្វើបណ្ដើរទៅខាងការបំផ្លិចបំផ្លាញ ។ តុល ណែនាំខ្ញុំឲ្យយកចិត្តទុកដាក់ទាក់ទងជាមួយ មន អតីតសិស្សថ្នាក់ទី៣ បច្ចុប្បន្នលេខាឃុំស្វាយទាប ចុះទៅអប់រំកសាងកម្លាំងនោះផង ព្រោះឥឡូវខ្ញុំចាត់តាំងឲ្យ មន ទៅអប់រំនិងចាត់តាំងកម្លាំងឲ្យមានជាក្រុម ជាកងឲ្យហើយស្រេច ដល់ព្រឹត្តិការណ៍កើតឡើងយើងត្រូវបំពាក់កម្លាំងឲ្យធ្វើសកម្មភាពតែម្ដង ។

ខ្ញុំបានទាក់ទង មន នៅសង្កាត់ស្វាយទាប ឲ្យហៅសមាសភាពទាហានប្រុសទាំងអស់មកប្រជុំ សូមបញ្ជាក់ទាហានទាំងអស់នេះគ្មាននៅលាយឡំជាមួយប្រជាជនទេ ដាក់តែទាហានសុទ្ធសាធតែម្ដង ហើយភូមិ នោះនៅក្នុងព្រៃដាច់ស្រយាលពីគេ) ខ្លឹមសារអប់រំ គឺ

◆ ឲ្យខំសម្របខ្លួននៅក្នុងសហករណ៍កុំឲ្យអង្គការដឹងថា ក្នុងភូមិមានតែទាហានសុទ្ធសាធ ។

◆ យើងពីមុនសុទ្ធតែធ្លាប់មានបណ្ដាសក្តិ ប្រាក់ខែចាយ ប៉ុន្តែឥឡូវនេះមកនៅក្នុងនេះដឹងស្រាប់ហើយ ដូច្នេះយើងត្រូវពុះពារទ្រាំទ្រការលំបាកបន្តិច ព្រោះយើងទ្រាំការលំបាកតែមួយរយៈសិនបន្តិចទៀត យើងបាននៅស្រួលដូចមុនវិញហើយ ។ ការអប់រំមានច្រើនតទៀត តែពេលនោះក៏ឲ្យត្រឡប់ទៅកន្លែងវិញសិន គឺទុកតែឆេង អតីតសក្តិ២យន្តហោះ បច្ចុប្បន្ននៅភូមិកាយគរ និង ផ្លូន ស្រេង អតីតសក្តិ១ បច្ចុប្បន្ននៅភូមិកាយគរ ។ ពីរនាក់នេះ ខ្ញុំ និង មន ចាត់តាំង ឲ្យឈ្មោះ ឆេង ប្រធានកងធំ និងផ្លូន ស្រេង អនុកងធំ ឲ្យក្តាប់សមាសភាពទាហាននោះទាំងអស់ ហើយណែនាំឲ្យរៀបចំកម្លាំងទាំងអស់ ជាក្រុម ជាកង ឲ្យហើយស្រេច តែកុំជំពាក់ជំពិននឹងប្រពន្ធកូនឲ្យសោះ ដើម្បីពេលមានព្រឹត្តិការណ៍កើតឡើង យើងត្រូវទៅជួយធ្វើអន្តរាគមន៍តែម្តង ។ ព្រមជាមួយគ្នានេះ ខ្ញុំនិង មន ណែនាំឲ្យ ផ្លូន ស្រេង និងឆេង ចាត់តាំងឈ្មោះ ខ្លាក្រហឹម ហៅ មាន ពាក់សក្តិ៣ ឲ្យបង្កើតចោរព្រៃដប់ពីរនាក់ដើរលួចគោ ។ កន្លងមកគឺបានលួចគោនៅភូមិបុសខ្មោរបានប្រាំក្បាល និងភូមិជីយោ បួនក្បាលដែលគោលែងទាំងហ្វូង ៗ ។

ខែកុម្ភៈ និងខែមីនា អង្គការបានចាប់ខ្លួន តុល និងមនុស្សជាច្រើនទៀត ។ ពេលនោះ ខ្ញុំមានការព្រួយបារម្ភច្រើនបាត់ម្ចាស់ការមួយរយៈ ។ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៧ គណៈភូមិភាគបានចាត់តាំងខ្ញុំឲ្យធ្វើជាអនុលេខាតំបន់៤២ ទទួលលេខាស្រុកចម្ការលើផង ។ ខ្ញុំគិតថា ប្រហែលបក្សមិនដឹងរឿងខ្ញុំទេ បានជាហានចាត់តាំងយ៉ាងនេះ ។

ពេលនោះខ្ញុំក៏ចាប់បន្តសកម្មភាពបន្តទៀត គឺទៅណែនាំឲ្យ ហ៊ាង, មន, វន និង សៀម ធ្វើសកម្មភាពបំផ្លាញផលស្រូវវស្សា ឲ្យយកសំណាបស្រូវធ្ងន់ស្ទូងដីទួល ស្រូវស្រាលស្ទូងដីទំនាប ទំលាយទឹកក្នុងស្រែចោលឲ្យស្កកស្រូវ និងទឹកក្នុងប្រឡាយខ្ញុំណែនាំឲ្យបើកចោលមិនបាច់បិទទេ ។ ជាលទ្ធផល ក្រោយពីមានការណែនាំមក ហ៊ាង បានយកស្រូវធ្ងន់ទៅស្ទូងដីទួលឲ្យខូចអស់៥០ហិចតា ។ ឯម៉ន, វន និង សៀម បំផ្លាញស្រូវវស្សាអស់១៥ហិចតា ដោយយកស្រូវស្រាលទៅស្ទូងដីជម្រៅ ។

ក្រោយមកទៀត ខ្ញុំបានហៅម៉ន, សៀម និង ហ៊ាង មកប្រជុំនៅផ្ទះ វន ពេលម៉ោង៨ព្រឹក ដោយ មានខ្លឹមសារៈ

◆ បំផ្លាញផលស្រូវ១ហិចតា៣តោន ដោយបំផុសប្រជាជនឲ្យស្ទូងបត់ដើម ទុកសំណាបឲ្យចាស់ដើម និងលួចបង្ហូរទឹកក្នុងស្រែចោល ។

◆ បំផុសប្រជាជនកុំឲ្យធ្វើការខំពេក ប្រយ័ត្នឈឺ គ្មានថ្នាំមើលទេ ឲ្យធ្វើការល្មមៗបានហើយ ។

◆ ដល់រដូវប្រាំងខាងមុខ ផែនការអង្គការឲ្យជីកប្រឡាយពីស្ទឹងជីនិតមកស្រុកតាំងគោក ផែនការរបស់យើងដើម្បីបន្ថុចបង្អាក់ផែនការជីកប្រឡាយមានៈ

១) ពេលទៅជីក បំផុសកម្លាំងឲ្យធ្វើពុតជាឈឺច្រើន ។

២) កុំឲ្យកម្លាំងប្រជាជនទៅជីកដោយយកលេសថា ជាប់ធ្វើត្រង់នេះត្រង់នោះ ។

៣) បំផុសយុវជន យុវនារី ឲ្យទាមទាររៀបគ្រួសារឲ្យស្នើមកលេងផ្ទះដើម្បីកុំឲ្យផែនការជីកប្រឡាយរបស់អង្គការបានសម្រេច ។

ខែសីហា ឆ្នាំ១៩៧៧ ខ្ញុំទៅជួប ឌុល នៅមន្ទីរសង្កាត់ស្រែវាលការជួបខ្ញុំពិភាក្សាពីផែនការអង្គការចាប់កម្លាំងក្បត់ជាបន្តបន្ទាប់ក្នុងតំបន់៤២ មិនដឹងគិតយ៉ាងណាឲ្យផុតពីកណ្តាប់ដៃបដិវត្តន៍ទេ ។ តាមការពិភាក្សាមក បានសម្រេចថានឹងពង្រីកកម្លាំងដែលនៅសល់ឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍តទៅទៀត តែការចេញចូលទាក់ទងគ្នាមិនឲ្យញឹកញាប់ពេក ប្រយ័ត្នខ្លាចបែកការ ។

ខ្ញុំត្រឡប់មកវិញក៏ខិតខំយកចិត្តទុកដាក់ពង្រីងកម្លាំងឲ្យធ្វើសកម្មភាពតទៅទៀត ។ រហូតដល់ថ្ងៃទី១ ខែ តុលា ឆ្នាំ១៩៧៧ ក៏ត្រូវអង្គការចាប់ខ្លួនតែម្តង ។

នៅបួនទំព័រចុងក្រោយនៃចម្លើយសារភាពគឺជាសេចក្តីសង្ខេបចម្លើយរបស់ នួន រឿន ហៅ ទៀង ដែលបានសង្ខេបឡើងវិញ ដោយឈ្មោះ ប៊ុន នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨ ។ ប៊ុន បានធ្វើសេចក្តីសង្កេត និងដាក់ជូនទៅអង្គការលើថា ការរៀបរាប់ពីសកម្មភាពក្បត់ដែល រឿន ឆ្លើយគឺខ្លីតែមានលក្ខណៈជាខ្សែសង្វាក់ច្បាស់គួរសមដែរ តែពុំទាន់លម្អិតនៅឡើយ ។ ហេតុដូចនេះ ប៊ុន ស្នើទៅអង្គការលើពិនិត្យតាមការជាក់ស្តែង ដោយអនុគ្រោះ ។

**ឆាយ សារៈមុនិន្ទ**

# ទំនាក់ទំនងផ្នែកនយោបាយរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋប្រជាមានិតចិន

កម្ពុជា និងចិនមានទំនាក់ទំនងគ្នាជាយូរអង្វែងមកហើយ ។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨ ព្រះរាជាណាចក្រកម្ពុជាទីមួយក្រោមការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ចាប់ផ្តើមសាងទំនាក់ទំនងជាផ្លូវការជាមួយសាធារណរដ្ឋប្រជាមានិតចិន ក្រោមការដឹកនាំរបស់ប្រធានរដ្ឋ ម៉ៅ សេទុង ។ ក្រោយពីមានទំនាក់ទំនងជាផ្លូវការហើយ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរមានការផ្លាស់ប្តូរទស្សនកិច្ចគ្នាទៅវិញទៅមកចាប់ពីមន្ត្រីជាន់ខ្ពស់ដល់ថ្នាក់ប្រមុខរដ្ឋ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមាន ប៉ុល ពត ជាលេខាបក្សនិងជានាយករដ្ឋមន្ត្រី បានបង្កើតទំនាក់ទំនងជាមួយប្រទេសចិនរិតតែល្អប្រសើរជាងមុនទៅទៀត ។ ក្រៅអំពីទំនាក់ទំនងផ្នែកយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ សុខាភិបាល ប្រទេសទាំងពីរក៏មានទំនាក់ទំនងយោធាដ៏សំខាន់មួយដែរ ។ ចិនបានជួយកម្ពុជាប្រជាធិបតេយ្យផ្នែកយោធាដោយផ្តល់ជាគ្រឿងសព្វាវុធ អ្នកជំនាញការយោធា និងចុងក្រោយបានប្រើកម្លាំងទ័ពដើម្បីបង្ខំឲ្យប្រទេសវៀតណាមដកទ័ពចេញពីប្រទេសកម្ពុជា ។

## ទំនាក់ទំនងផ្នែកនយោបាយ

### ១) ថ្នាក់ដឹកនាំនៃសាធារណរដ្ឋប្រជាមានិតចិនមកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ

ចាប់ពីបក្សកុម្មុយនីស្តកម្ពុជាទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក រដ្ឋាភិបាលប្រទេសទាំងពីរចាប់ផ្តើមផ្លាស់ប្តូរដំណើរទស្សនកិច្ចទៅវិញទៅមក ។ ចាប់ពីថ្ងៃទី៥ ដល់



ប៉ុល ពត (ឆ្វេង) កំពុងទទួលជួបពិភាក្សានៅទីក្រុងភ្នំពេញជាមួយ ស៊ូ ហាវ អគ្គរដ្ឋទូតចិនប្រចាំរបបកម្ពុជាប្រជាធិបតេយ្យ

ទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៨ លោក វ៉ាង ដុងស៊ីង អនុប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិនបានមកទស្សនកិច្ចនៅកម្ពុជា ។ ពេលមកដល់ព្រលានយន្តហោះពោធិ៍ចិនតុង វ៉ាង ដុងស៊ីង ទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅសំណាក់លេខាបក្សកុម្មុយនីស្តកម្ពុជា ប៉ុល ពត, គណៈប្រធានរដ្ឋ ខៀវ សំផន, ប្រធានរដ្ឋសភា នួន ជា ព្រមទាំងមានកម្មាភិបាលប្រុសស្រីរាប់ពាន់នាក់ក្នុងសម្លៀកបំពាក់អាវពណ៌សលើកគ្រវីបាច់ផ្កាចម្រុះពណ៌ និងកាន់បដារដែលសរសេរថា "ជយោមិត្តភាពកម្ពុជា ចិន និងកម្លាំងប្រយុទ្ធសាមគ្គីភាពដ៏អស្ចារ្យ" ដើម្បីទទួលអបអរសាទរ ការមកដល់របស់គណៈប្រតិភូចិន ។ គណៈប្រតិភូចិនអមដំណើរដោយ ប៉ុល ពត, ខៀវ សំផន និងនួន ជា ធ្វើដំណើរដល់សណ្ឋាគាររដ្ឋមួយជិតទន្លេមេគង្គ ដោយនៅទីនោះមានយុវជនប្រុសស្រីស្លៀកពាក់យ៉ាងសមរម្យលើកផ្កាគ្រវីជាង១.០០០នាក់ទទួលស្វាគមគណៈប្រតិភូមកដល់ ។

នៅពេលជំនួបទទួលទានអាហារ លោក វ៉ាង ដុងស៊ីង បានថ្លែងកោតសរសើរបក្សកុម្មុយនីស្តកម្ពុជាថា "រដ្ឋាភិបាលនិងប្រជាជនចិនគាំទ្រយ៉ាងពេញទំហឹងចំពោះប្រជាជនកម្ពុជាក្នុងការការពារទឹកដី ឯករាជ្យម្ចាស់ការលើទឹកដីកម្ពុជាទាំងមូល ។ កងទ័ពកម្ពុជានិងប្រជាជនកម្ពុជាសុទ្ធតែជាអ្នកអង់អាចនិងក្លាហាន" ។ ប៉ុល ពតក៏បានលើកសរសើរទំនាក់ទំនងរបស់ប្រទេសទាំងពីរដោយមានប្រសាសន៍ថា "ទំនាក់ទំនងរវាងប្រទេសកម្ពុជានិងចិនស្របទៅតាមបំណងប្រជាជននៃប្រទេសទាំងពីរ ក៏ស្របទៅតាមតំបន់អាស៊ានអាស៊ី និងស្របទៅតាមផលប្រយោជន៍ប្រជាជនគ្រប់ប្រទេសលើពិភពលោក ។ នៅថ្ងៃអនាគត កម្ពុជានឹងប្រឹងឲ្យអស់ពីសមត្ថភាពពង្រឹងនិងពង្រីកទំនាក់ទំនងជាមិត្តភាពប្រទេសទាំងពីរឲ្យរឹតតែរឹងមាំ និងខ្លាំងក្លាថែមទៀត" ។

ដំណើរទស្សនកិច្ចរបស់ វ៉ាង ដុងស៊ីង នៅរបបកម្ពុជាប្រជាធិបតេយ្យនៅពេលនេះ ចំពេលដែលជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមឡើងដល់កម្រិតកំពូល ។ គឺមួយខែក្រោយពីដំណើរទស្សនិច្ចនេះ នៅខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយចូលប្រទេសកម្ពុជាពីព្រំដែនខាងកើតនៃប្រទេសកម្ពុជា ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលបានរៀបចំឲ្យមេដឹកនាំចិនមកទស្សនកិច្ចនៅកម្ពុជានៅពេលនេះ ក៏ចង់បង្ហាញឲ្យមេដឹកនាំប្រទេស



គណៈប្រតិភូចិនដឹកនាំដោយ វ៉ាង ដុងស៊ីង (ឆ្វេង) ទស្សនកិច្ចប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ទទួលស្វាគមន៍ និងអមដំណើរពីព្រលានយន្តហោះដោយ ប៉ុល ពត, នួន ជា (ស្តាំខាងក្រោយ) និង ខៀវ សំផន ។ គណៈប្រតិភូចិនត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ថ្នាក់ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។

វៀតណាមឃើញថា កម្ពុជាប្រជាធិបតេយ្យមានប្រទេសចិនជាខ្នងបង្អែក ។ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យអមដំណើរ វ៉ាង ដុងស៊ីង ដើរទស្សនកិច្ចតំបន់ផ្សេងៗក្នុងប្រទេស ក៏បានអត្ថាធិប្បាយអំពីជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមដែរ ។

ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៧ លោក ចេន យ៉ុងហ្គុយ សមាជិកនយោបាយបក្សកុម្មុយនីស្ត និងជាឧបនាយករដ្ឋមន្ត្រីចិន ទទួលបានការអញ្ជើញពីបក្សកុម្មុយនីស្តកម្ពុជាមកបំពេញទស្សនកិច្ចជាផ្លូវការនៅកម្ពុជា ។ ប៉ុល ពត បានអមដំណើរលោក ចេន យ៉ុងហ្គុយ ទៅទស្សនកិច្ចនៅភូមិភាគបូព៌ានៃប្រទេសកម្ពុជា ដោយនៅទី នោះមាន កម្មករ កសិករ និងកងទ័ពបដិវត្តន៍ខ្មែរក្រហមរាប់ម៉ឺននាក់ទទួលស្វាគមន៍យ៉ាងកក់ក្តៅ ។ នៅក្នុងជំនួបពិភាក្សារវាងអ្នកទាំងពីរ ប៉ុល ពត បានមានសង្កត់ធ្ងន់លើទំនាក់ទំនងមិត្តភាពកងទ័ពនៃប្រទេសទាំងពីរ ។ ប៉ុល ពត ក៏បានរំឭកព្រឹត្តិការណ៍កាលពីឆ្នាំ១៩៥៦ នៅពេលដែលគាត់ទៅទទួល ជូ អេនឡាយ មកទស្សនកិច្ចលើកដំបូងនៅកម្ពុជា ។ ចំណែកឯលោក ចេន យ៉ុងហ្គុយ បានកោតសរសើរកងទ័ពបដិវត្តន៍ខ្មែរក្រហមថា “ចាប់ពីចលនាតស៊ូរហូតដល់ទទួលបានជ័យជម្នះរបស់ប្រជាជនកម្ពុជា គឺជាការបញ្ជាក់ពីការគ្រាំទ្រយ៉ាងពេញទំហឹងចំពោះប្រជាជនចិន ។ កម្ពុជាក្រោយថ្ងៃរំដោះ ចំណាយពេលតែពីរឆ្នាំប៉ុណ្ណោះអាចទទួលបានលទ្ធផលយ៉ាងត្រចះត្រចង់ ។ យើងខ្ញុំត្រូវតែខិតខំស្វែងយល់ និងរៀនសូត្រតាមបក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនកម្ពុជា” ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨ លោកស្រី តេង គៀនចាវ អនុប្រធានសភាប្រជាជនចិនបានមកបំពេញទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ។ នៅព្រលានយន្តហោះពោធិ៍ចិនតុង ប៉ុល ពត នាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ និង នួន ជា ប្រធានសភាប្រជាជនកម្ពុជាប្រជាធិបតេយ្យ ទទួលស្វាគមន៍យ៉ាងកក់ក្តៅលោកស្រី តេង គៀនចាវ និងគណៈប្រតិភូអមដំណើរផ្សេងទៀត ។ នៅក្នុងជំនួបសវនាការ ប៉ុល ពត បានមានប្រសាសន៍ថា “ការមកទស្សនកិច្ចរបស់លោកស្រីនេះ យើងខ្ញុំមានការត្រេកអរយ៉ាងអនេកប្បការ ការទស្សនកិច្ចនេះ បើនិយាយចំពោះកម្ពុជាគឺជាការលើកទឹកចិត្តយ៉ាងខ្លាំងក្លាចំពោះកម្ពុជា ។ តាមពិត ខ្ញុំបាទ និងលោកស្រីអនុប្រធានសភាជាមិត្តតាំងពីយូរមកហើយ ពីព្រោះនៅពេលដែលខ្ញុំបាទទៅទស្សនានៅប្រទេសចិន ខ្ញុំនិងលោកស្រីបានធ្វើការជាមួយគ្នាយ៉ាងសកម្ម ។ លោកស្រីមិនគ្រាន់តែជាប្រេសិតពិសេសរបស់បក្សកុម្មុយនីស្ត និងប្រជាជនចិនតែប៉ុណ្ណោះទេ ថែមទាំងជាមហាមិត្តរបស់ប្រជាជនកម្ពុជាថែមទៀតផង ។ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ជាយុទ្ធមិត្តរបស់កម្ពុជា ចំណែកការមកទស្សនកិច្ចរបស់លោកស្រី បាននាំមកជាមួយនូវមិត្តភាពយ៉ាងជ្រាលជ្រៅរបស់បក្សកុម្មុយនីស្ត និងប្រជាជនចិន” ។ នៅក្នុងជំនួបពិភាក្សានោះ នួន ជា ក៏បានមានប្រសាសន៍ដែរថា “តាំងពីក្រោយថ្ងៃរំដោះមក កម្ពុជាចង់អញ្ជើញលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ មកទស្សនកិច្ចនៅកម្ពុជា ដោយសង្ឃឹមថា លោកនាយករដ្ឋមន្ត្រីនឹងបានឃើញផ្ទាល់នឹងភ្នែកចំពោះបដិវត្តន៍យ៉ាងស្អិតរមួតរវាងប្រជាជនកម្ពុជានិងប្រជាជនចិន ។ មិនតែប៉ុណ្ណោះ ប្រជាជនកម្ពុជាមានការគោរព ស្រលាញ់ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះគុណបំណាច់យ៉ាងធំធេង ចំពោះលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ” ។ លោកស្រី តេង គៀនចាវ បានមានប្រសាសន៍តបវិញថា “លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ក្នុងនាមជាយុទ្ធជន បដិវត្តន៍វណ្ណៈអធន គាត់បានគោរពតាមការចង្អុលបង្ហាញរបស់លោកប្រធាន ម៉ៅ សេងទុង ចំពោះកិច្ចការបដិវត្តន៍កម្ពុជា និងទំនាក់ទំនងមិត្តភាពរវាងចិន-កម្ពុជាតែព្រោះនេះជាភារកិច្ចដែលគាត់ចាំបាច់ត្រូវតែធ្វើ” ។ ដំណើរទស្សនកិច្ចនៅក្នុងប្រទេសរបស់លោកស្រីប្រធានគណៈប្រតិភូចិន អមដំណើរដោយ នួន ជា, ខៀវ ប៉ុណ្ណារី និងអៀង ធីរិទ្ធ ។

នៅដើមឆ្នាំ១៩៧៦ គណៈប្រតិភូពាណិជ្ជកម្ម និងសេដ្ឋកិច្ចចិន បានមកបំពេញទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ។

ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៧ គណៈប្រតិភូសេដ្ឋកិច្ច ពាណិជ្ជកម្មចិន ដឹកនាំដោយលោក ហ្វាង យី បានមកបំពេញទស្សនកិច្ចនៅកម្ពុជា ។ គណៈប្រតិភូនេះជាតំណាងឲ្យរដ្ឋាភិបាលចិន ក្នុងការចុះកិច្ចព្រមព្រៀងផ្នែកសេដ្ឋកិច្ចរវាងរដ្ឋាភិបាលចិន និងកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយពីចុះហត្ថលេខាទំនាក់ទំនងផ្នែកសេដ្ឋកិច្ច គណៈប្រតិភូ ក៏បានផ្តល់ជំនួយឥតសំណងផ្នែកសេដ្ឋកិច្ច និងបាននាំយកសម្ភារផ្នែកកសិកម្មមួយចំនួនដែរ ។

ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៦ លោក មូ គីង អនុប្រធានសារព័ត៌មានចិន ស៊ីនហួរ ប្រធានគណៈប្រតិភូ និងលោក លូ ដេយូន អគ្គនាយករងព័ត៌មានភាពយន្តមជ្ឈិមបក្សបានមកបំពេញទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ។ ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូចិននេះ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា និង អៀង សារី បានផ្លាស់ប្តូរវេនគ្នាដើម្បីអមដំណើរគណៈប្រតិភូធ្វើទស្សនកិច្ច និងជំនួបពិភាក្សាគ្នានៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងជំនួបពិភាក្សាមួយ ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងព័ត៌កម្ពុជាប្រជាធិបតេយ្យបានមានប្រសាសន៏ទៅកាន់គណប្រតិភូចិនថា ប្រជាជនចិន ក្រោមការដឹកនាំរបស់លោកប្រធាន ហួ ក្កុហ្វេង បានកម្ចាត់យ៉ាងមានប្រសិទ្ធភាពចំពោះក្រុមប្រឆាំងបដិវត្តន៍ទាំងបួននាក់ ។ គណៈប្រតិភូចិននៅក្នុងអំឡុងពេលបំពេញទស្សនកិច្ចនៅកម្ពុជាមានអារម្មណ៍រំភើប និងកក់ក្តៅយ៉ាងក្រៃលែង ពីព្រោះពេលទៅដល់ទីកន្លែងទស្សនកិច្ច ឬយកព័ត៌មាន មានមនុស្សជាច្រើនរង់ចាំទទួលស្វាគមន៍នៅទីនោះ ។

ទិដ្ឋភាពទទួលស្វាគមន៍ចំពោះមេដឹកនាំចិនមកទស្សនកិច្ចនៅកម្ពុជាបែបនេះ គឺជាទិដ្ឋភាពដែលកម្រជួបប្រទះ ពីព្រោះចាប់ថ្ងៃជ័យជំនះនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥មក ខ្មែរក្រហមបានចេញបញ្ជាឲ្យបណ្តេញប្រជាជនដែលរស់នៅទីក្រុងភ្នំពេញទាំងអស់ចេញពីទីក្រុងភ្នំពេញ និងក្រោយមកមិនយូរប៉ុន្មាន ក៏បានបណ្តេញប្រជាជនពីទីប្រជុំជនផ្សេងទៀត និងដាក់បញ្ជាឲ្យប្រជាជនទូទាំងប្រទេស ព្រមទាំងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ។ អ្នកដែលអាចរស់នៅភ្នំពេញបានមានតែកម្មាភិបាលបក្សជាន់ខ្ពស់ កងការពារ យោធា បុគ្គលិករោងចក្រ និងបុគ្គលិកកសិដ្ឋានរដ្ឋមួយចំនួនប៉ុណ្ណោះ ។ ពិតមែនតែអ្នកទាំងនោះអាចរស់នៅក្នុងក្រុងភ្នំពេញក៏ពិតមែន តែក៏មិនអាចដើរទៅមកដោយសេរីក្នុងទីក្រុង ដោយគ្មានបញ្ជាពីថ្នាក់ដឹកនាំរបស់ខ្លួនបានដែរ អ្នកដែលមិនគោរពវិន័យត្រូវទទួលទោសយ៉ាងធ្ងន់ធ្ងរ គឺសេចក្តីស្លាប់ ។

ដូច្នេះការរៀបចំប្រជាជនមកទទួលគណៈប្រតិភូត្រូវរៀបចំឡើងដោយប្រុងប្រយ័ត្នបំផុត និងមានលក្ខខណ្ឌចាំបាច់ដោយខានមិនបាន ។ នៅក្នុងទំនាក់ទំនងអន្តរជាតិ ការរៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់ ជាទង្វើមួយដែលបញ្ជាក់ពីកម្រិតនៃចំណង



សុន សេន (កណ្តាល) កំពុងនាំគណៈប្រតិភូចិនទៅពិនិត្យមើលសព្វាវុធនៅភូមិភាគបូព៌ា ។ អមដំណើរនៅពេលនោះដោយ ស៊ូ ហាវ (ទីពីររាប់ពីឆ្វេង) អគ្គរដ្ឋទូតចិនប្រចាំរបបកម្ពុជាប្រជាធិបតេយ្យ និងប្រធានក្រុមទីប្រឹក្សាចិនប្រចាំរបបកម្ពុជាប្រជាធិបតេយ្យ (ទីពីររាប់ពីស្តាំ) ។

មិត្តភាពរវាងប្រទេស និងប្រទេស ប្រសិនបើការរៀបចំទទួលបដិសណ្ឋារកិច្ចមានលក្ខណៈសាមញ្ញ និងមន្ត្រីដែលមកទទួលភ្ញៀវបរទេសនោះ មិនមែនជាមន្ត្រីជាន់ខ្ពស់ នោះបញ្ជាក់ថា គណៈប្រតិភូដែលចូលមកទស្សនកិច្ច ជាមនុស្សមានឋានៈមិនសូវខ្ពង់ខ្ពស់ ឬទំនាក់ទំនងនៃប្រទេសទាំងមិនសូវជាល្អនឹងគ្នា ។

**១.២) ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យទៅទស្សនកិច្ចនៅប្រទេសចិន**

ចាប់តាំងពីប្រទេសចិនជួយជ្រោមជ្រែងដល់ចលនាតស៊ូរបស់ចលនាខ្មែរក្រហម ថ្នាក់ដឹកនាំចលនានេះតែងតែទៅទស្សនកិច្ចជារឿយៗនៅប្រទេសចិន ។ នៅខែមេសា ឆ្នាំ១៩៧៤ ខៀវ សំផន និង អៀង សារី តំណាងរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានទៅបំពេញទស្សនកិច្ចនៅប្រទេសចិន ។ ថ្ងៃទី២ ខែមេសា សម្តេចព្រះនរោត្តម សីហនុ ខៀវ សំផន និង អៀង សារី បានទទួលជួបពិភាក្សាការងារស្តីពីកម្ពុជាក្រោយថ្ងៃរំដោះ ជាមួយប្រធាន ម៉ៅ សេងទុង ។ ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូខ្មែរក្រហមទទួលបានការទទួលស្វាគមន៍អធឹកអធមពីសំណាក់រដ្ឋាភិបាលចិន ប្រៀបដូចជាការទទួលដំណើរទស្សនកិច្ចរបស់សម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៦៥ ដូច្នេះដែរ ។

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៥ ប៉ុល ពត បានទៅទស្សនកិច្ចនៅប្រទេសចិន ។ នេះជាលើកទីមួយរបស់កម្មាភិបាលជាន់ខ្ពស់របបកម្ពុជាប្រជាធិបតេយ្យទៅទស្សនកិច្ចនៅក្រៅប្រទេសបន្ទាប់ពីទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ នៅក្នុងដំណើរទស្សនកិច្ចនេះ ប៉ុល ពត បានទទួលជួបសវនាការជាមួយប្រធានរដ្ឋ ម៉ៅ សេងទុង ។ នៅក្នុងពេលជំនួបសវនាការនោះ ប៉ុល ពត មានប្រសាសន៍ថា «ថ្ងៃនេះ យើងខ្ញុំបានមានសេចក្តីរំភើបរីករាយជាអនេកប្បការ ដោយបានមកជួបមហាបុរស ម៉ៅ សេងទុង» ។ ម៉ៅ សេងទុង បានមានប្រសាសន៍គាំទ្រដល់ចលនាខ្មែរក្រហមថា «យើងខ្ញុំគាំទ្រទាំងស្រុងចំពោះអស់លោក ហើយបទពិសោធន៍របស់សមមិត្តច្រើនជាងបទពិសោធន៍របស់យើងខ្ញុំទៅទៀត ។ យើងខ្ញុំមិនមានសមត្ថភាពស្តីបន្ទោសអស់លោកទេក្នុងរយៈពេល៥០ឆ្នាំកន្លងមក ប្រទេសចិនដើរលើផ្លូវខុសជាច្រើនលើកច្រើនសា កំហុសខ្លះកើតឡើងទូទាំងប្រទេស និងកំហុសខ្លះកើតឡើងនៅក្នុងតំបន់មួយចំនួន ។ ចំពោះការងាររបស់អស់លោកគឺសុទ្ធតែត្រឹមត្រូវ» ។ ប៉ុន្តែលោកប្រធាន ម៉ៅ សេងទុង ក៏បានរំឭកដល់មេដឹកនាំ ខ្មែរក្រហមដែរថា កុំចម្លងទាំងស្រុងពីប្រទេសចិន ។ ប៉ុល ពត បានមានប្រសាសន៍ ចំពោះមាគ៌ាដែលលោកប្រធានបានលើកឡើងថា «វាមានសារសំខាន់ណាស់ចំពោះនយោបាយជាយុទ្ធសាស្ត្រ ។ ពីនេះតទៅ យើងខ្ញុំនិងធ្វើតាមការណែនាំរបស់លោក ។ ចាប់តាំងពីពេញវ័យមក ខ្ញុំបាទបានសិក្សាស្នាដៃជាច្រើនរបស់លោកប្រធាន ជាពិសេសស្នាដៃដែលពិភាក្សាអំពីយុទ្ធសាស្ត្រសង្គ្រាម ស្នាដៃនិពន្ធរបស់លោកប្រធានជាមាគ៌ាបង្ហាញផ្លូវបក្សកុម្មុយនីស្តកម្ពុជា» ។ ក្រោយពីនោះ ប៉ុល ពត និងលោកប្រធាន ម៉ៅ បានពិភាក្សាយ៉ាងច្រើនអំពីមាគ៌ាដែលត្រូវជ្រើសរើសក្រោយជ័យជម្នះ និងបទពិសោធន៍មួយចំនួនក្រោយជ័យជម្នះ ។ នៅពេលបញ្ចប់ជំនួបសវនាការ លោកប្រធាន ម៉ៅ បានប្រគល់សៀវភៅដែលសរសេរដោយលោក កាល់ម៉ាក់ អង់ហ្គែល លេនីន និងស្តាលីន ចំនួន៣០ក្បាល ដោយមានប្រសាសន៍ថា «ពួកគាត់និយាយល្អជាងខ្ញុំ» ។ ប៉ុល ពត មានសេចក្តីរីករាយយ៉ាងខ្លាំងនៅពេលទទួលបានសៀវភៅពីលោកប្រធាន ម៉ៅ ។ ក្នុងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យក៏បានចូលជួបចំនួនពីរដងជាមួយលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ នៅមន្ទីរពេទ្យ ។

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៧ ប៉ុល ពត ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ ទទួលបានការអញ្ជើញពីរដ្ឋាភិបាលចិនបានទៅធ្វើទស្សនកិច្ចជាថ្មីម្តងទៀតនៅប្រទេសចិនរយៈពេលប្រាំមួយថ្ងៃ ។ ពេលទៅដល់ព្រលានយន្តហោះទីក្រុងប៉េកាំង លោកប្រធានាធិបតី ហួ ក្វុហ្វេង, លោក តេង ស៊ាវពីង អនុប្រធានាធិបតី, លោកអនុប្រធានាធិបតី លី ស៊ាននៀន បានទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងមានមនុស្សរាប់ពាន់នាក់ លើកគ្រវីផ្កាស្រស់ចម្រុះពណ៌ មានក្រុមខ្លះច្រៀងផង រាំផង អបអរសាទរគណៈប្រតិភូកម្ពុជាប្រជាធិតេយ្យដែលបានមកទស្សនកិច្ចប្រទេសចិន ។

ចាប់ពីព្រលានយន្តហោះក្រុងប៉េកាំង ប៉ុល ពត បានជិះរថយន្តជាមួយលោក ហួ ក្វុហ្វេង ឆ្លងកាត់ពីមុខព្រះរាជវាំង ធានអានមេន ដែលនៅទីនោះមានមនុស្សរាប់ពាន់នាក់ ឈរអមទទួលស្វាគមន៍ការមកដល់របស់គណៈប្រតិភូកម្ពុជាប្រជាធិបតយ្យ ។ នៅពេលជំនួប

សវនាការ លោកប្រធានាធិបតី ហ៊្វូ ហ្គូហ្វេង បានមានប្រសាសន៍ថា “ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា បានប្រយុទ្ធយ៉ាងក្លាហាន ប្រើយុទ្ធសាស្ត្រប្រជាជនបានវាយកម្ទេចយ៉ាងដោគជ័យលើក្រុមបក្សសម្ព័ន្ធ និងរដ្ឋាភិបាលរបស់ លន់ នល់ និងបានវាយបណ្តេញពួកចក្រពត្តិនិយមចេញពីប្រទេសកម្ពុជា ។ ប្រទេសកម្ពុជាបានបង្កើតប្រវត្តិសាស្ត្រថ្មីមួយដែលប្រជាជនបានធ្វើជាម្ចាស់លើប្រទេសខ្លួនឯង និងដឹកនាំដោយវណ្ណៈអធន បានរំដោះប្រទេសចេញពីនឹមត្រួតត្រារបស់ចក្រពត្តិនិយម ។ បដិវត្តន៍របស់កម្ពុជាមិនត្រឹមតែជំរុញឲ្យមានប្រវត្តិសាស្ត្រថ្មីប៉ុណ្ណោះទេ ថែមទាំងបានលើកទឹកចិត្តដល់កម្លាំងប្រជាជនបដិវត្តន៍ទូទាំងពិភពលោក ដែលកំពុងទទួលរងការគៀបសង្កត់ពីសំណាក់ចក្រពត្តិនិយមឲ្យមានស្មារតីកាន់តែខ្លាំងក្លាឡើង ។ មូលហេតុដែលប្រជាជនកម្ពុជាទទួលបានជ័យជម្នះទាំងនេះ មកអំពីមូលហេតុពីរគឺ ទ្រឹស្តីបក្សលេនីន និងយុទ្ធសាស្ត្រដ៏ច្បាស់លាស់មួយ ។ ការទទួលជោគជ័យរបស់កងកម្លាំងបដិវត្តន៍កម្ពុជា បានឲ្យឃើញថា មិនថាជាប្រទេសតូច ឬធំ ឲ្យតែពឹងផ្អែកលើកម្លាំងប្រជាជន ព្យាយាមធ្វើម្ចាស់លើខ្លួនឯង ឯករាជ្យម្ចាស់ការ កងទ័ពប្រយុទ្ធស្មារតៀកស្មា សរុប និងពិភាក្សាអំពីបទពិសោធន៍ និងមានជំហ៊ានឈានទៅមុខ ប្រាកដជាអាចកសាងប្រទេសរបស់ខ្លួនបានយ៉ាងល្អ ។ មហាបុរស ម៉ៅ សេងទុង និងលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ កាលនៅមានជីវិតមានការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះកងកម្លាំងបដិវត្តន៍កម្ពុជា និងមិត្តភាពរវាងប្រទេសចិន និងកម្ពុជា ។ យើងខ្ញុំជឿជាក់ថា ការមកទស្សនកិច្ចរបស់អស់លោក ពិតជាបង្កើនទំនាក់ទំនងរវាងបក្សនឹងបក្ស និងប្រទេសយើងទាំងពីរ ឲ្យឈានទៅរកការសហការ និងការអភិវឌ្ឍថ្មីមួយទៀត ។ ចំពោះមិត្តភាពនៃបដិវត្តន៍ និងកម្លាំងរួមប្រយុទ្ធរវាងប្រទេសយើងទាំងពីរ នឹងធ្វើឲ្យរឹតតែរឹងមាំ និងកាន់តែល្អពីមួយថ្ងៃទៅមួយថ្ងៃ» ។

ប៉ុល ពត យល់ស្របយ៉ាងខ្លាំងអំពីគំនិតបដិវត្តន៍ និងទ្រឹស្តីកុម្មុយនីស្តរបស់លោកប្រធាន ម៉ៅ សេងទុង ហើយទទួលស្គាល់ថា ជ័យជម្នះរបស់បដិវត្តន៍កម្ពុជាមានប្រភពមកពីទ្រឹស្តីរបស់លោកប្រធាន ម៉ៅ ។ ដោយសង្កត់ធ្ងន់ថា “បដិវត្តន៍របស់ប្រទេសចិនដែលទទួលបានជ័យជម្នះពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត សុទ្ធតែជាស្នាដៃរបស់អគ្គមគ្គុទ្ទេសក៍ ម៉ៅ សេទុង ។ ទទួលបន្តពីស្នាដៃរបស់លោក កាល់ម៉ាក់, អង់ហ្គែល លេនីន និងស្តាលីន ប្តូករួមការគិតពិចារណារបស់លោកប្រធាន ម៉ៅ ព្រមទាំងបទពិសោធន៍អាប់អួរនៃបដិវត្តន៍ដ៏សែនគ្រោះថ្នាក់ ពេលនេះបានក្លាយទៅជាពន្លឺបំភ្លឺផ្លូវគ្រប់បដិវត្តន៍រំដោះជាតិ ដល់ប្រជាជនទូទាំងពិភពលោក ។ អាចនិយាយបានម្យ៉ាងទៀតថា វាជាពន្លឺបំភ្លឺផ្លូវ ជាអាវុធមុតស្រួច និងនយោបាយដ៏មានប្រសិទ្ធភាព ដែលនាំឲ្យចលនាបដិវត្តន៍របស់យើងខ្ញុំដណ្តើមបានជ័យជម្នះ ។ ដំណើរការចលនាបដិវត្តន៍របស់យើងខ្ញុំ បានអនុវត្តទ្រឹស្តីរបស់លោកប្រធាន ម៉ៅ ដោយចាប់ផ្តើមពីបាតដៃទទេ រហូតដល់ទទួលបានជ័យជម្នះនៅថ្ងៃទី១៧ មេសា ១៩៧៥ លើពួកឆ្កែបម្រើចក្រក្រពត្តិនិយម រំដោះបានទាំងស្រុងប្រជាជនទូទាំងប្រទេស ធ្វើឲ្យកម្មករ កសិករមានវាសនាដឹកនាំនយោបាយទាំងស្រុងទូទាំងប្រទេស ។ ប្រជាជនយើងខ្ញុំ និងជនបដិវត្តន៍ទាំងអស់លើពិភពលោក ជឿជាក់ទាំងស្រុងលើទ្រឹស្តី ម៉ៅ សេងទុង ដោយហេតុថា ការពិភាក្សាអំពីក្បាលម៉ាស៊ីនថ្នាក់ដឹកនាំបក្សត្រូវតែរឹងមាំ អំពីការបង្កើតចលនាវណសិរ្សជាតិមួយរឹងមាំ អំពីការបង្កើតភាពរឹងមាំ និងក្លាហានរបស់កងទ័ពបដិវត្តន៍ អំពីការបែងចែកវណ្ណៈសង្គម អំពីភាពជាទំនាស់ អំពីការអនុវត្ត អំពីការបង្កើតមូលដ្ឋានភូមិបដិវត្តន៍ អំពីការទាញយកផលប្រយោជយ៍ពីជនបទ និងទីក្រុង អំពីដំណើរការបដិវត្តន៍ អំពីបដិវត្តន៍ហិង្សា អំពីយុទ្ធសាស្ត្របច្ចេកទេសនៃសង្គ្រាមប្រជាជន អំពីបដិវត្តន៍របស់វប្បធម៌ សិល្បៈ អក្សរសាស្ត្រ នៅតែមានប្រសិទ្ធិភាពមានភាពមុតស្រួច និងជាអាវុធដែលធ្វើសង្គ្រាមមិនចេះចាញ់

លោកប្រធាន ម៉ៅ បានធ្វើឲ្យចលនាបដិវត្តន៍សង្គមនិយម មានដំណើរការឡើងនៅក្នុងចលនាអប់រំ សង្គមនិយម ជាពិសេសវណ្ណៈអធននៅក្នុងបដិវត្តន៍វប្បធម៌ លោកប្រធាន ម៉ៅ បានសង្កត់ធ្ងន់ និងលើកកម្ពស់ទង់បដិវត្តន៍ ដំណើរការទំនាស់វណ្ណៈនៅក្នុងការផ្លាស់ប្តូរអំណាចរបស់វណ្ណៈអធន និងនៅតែបន្តដំណើរការបដិវត្តន៍សង្គមនិយមតទៅទៀត ។ ការចង្អុលបង្ហាញនេះបញ្ជាក់ឲ្យឃើញថា ក្នុងដំណាក់កាលប្រវត្តិសាស្ត្រសង្គមនិយម សុទ្ធតែបន្សល់ទុកនូវទំនាស់នៃវណ្ណៈ និងការប្រកួតប្រជែងវណ្ណៈ ។ ចាំបាច់ត្រូវតែព្យាយាម



យោធាខ្មែរក្រហម និងក្រុមជំនាញការចិននៅប្រាសាទអង្គរវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ប្រឆាំងនិងវណ្ណៈអភិជន របស់វណ្ណៈអធន់ ព្យាយាមផ្លាស់ប្តូរអំណាចពីវណ្ណៈអភិជនមកវណ្ណៈអធនព្យាយាមបន្តការបដិវត្តន៍នៅក្នុងអំណាចវណ្ណៈអធន ។ នៅក្នុងមាគ៌ានេះ ចំពោះអ្វីដែលវណ្ណៈអធនបានកាន់អំណាច នេះជាភាពត្រឹមត្រូវ និងវៃយឆ្លាត» ។ ប៉ុល ពត ក៏បានបង្ហាញឲ្យថ្នាក់ដឹកនាំចិន អំពីស្ថានភាពកម្ពុជាដូចជាៈ ព្រំប្រទល់ សេដ្ឋកិច្ច ការអប់រំនិងវប្បធម៌ វិទ្យាសាស្ត្រ សុខាភិបាល និងវិស័យកសិកម្ម មានការកសាងទំនប់ទឹកតូច ធំ និងមធ្យម ។ គាត់បានវាយតម្លៃអំពីទំនាក់ទំនងប្រទេសទាំងពីរថា «បក្សនិងប្រជាជនរបស់ប្រទេសទាំងពីរ បានកសាងឡើងក្នុងលទ្ធិ កាល់ម៉ាក, លទ្ធិ លេនីន និងទ្រឹស្ដី ម៉ៅ សេទុង ដ៏ត្រចះត្រចង់ និងបដិវត្តន៍ជាមិត្តភាពដែលមិនអាចបំបែកបាន» ។

នៅដើមខែមេសា ឆ្នាំ១៩៧៨ សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ បានទៅទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន គោលដៅពង្រឹងទំនាក់ទំនងផ្នែកយោធា និងសុំជំនួយយោធាពីរដ្ឋាភិបាលចិន ដើម្បីទប់ទល់ជាមួយកងទ័ពវៀតណាម ។

## ២) ទំនាក់ទំនងផ្នែកមនោគមវិជ្ជា និងជំនួយ

### ២.១) សម្ព័ន្ធភាពរវាងប្រទេសកុម្មុយនីស្ត

ទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋចិន បានឡើងដល់ចំណុចកំពូលលើគ្រប់វិស័យ ។ ប្រទេសចិន មិនត្រឹមផ្ដល់ជំនួយដល់កម្ពុជាប្រជាធិបតេយ្យគ្រប់វិស័យប៉ុណ្ណោះទេ ថែមទាំងបានសម្រេចផ្ញើសង្គ្រាមទៅលើប្រទេសមួយទៀត ដើម្បីជួយសង្គ្រោះប្រទេសជាមិត្តរបស់ខ្លួនទៀតផង ។ សម្ព័ន្ធភាពរវាងប្រទេសទាំងពីរបានក្លាយទៅជាសម្ព័ន្ធភាពរឹងមាំដោយមានមូលហេតុធំៗបីយ៉ាងគឺ ទីមួយសុទ្ធតែជាប្រទេសប្រកាន់លទ្ធិកុម្មុយនីស្ដដូចគ្នា ហើយ ប៉ុល ពត បានឈ្ងក់វង្វេងជាខ្លាំងចំពោះទ្រឹស្ដីកុម្មុយនីស្ដ ម៉ាក, លេនីនស្ដាលីននិយម និងជាពិសេសលើទ្រឹស្ដី ម៉ៅនិយម ។ ទីពីរ តួនាទីយ៉ាងសំខាន់របស់សម្ដេចព្រះ នរោត្តម សីហនុ និងទីបី របបទាំងពីរមានសត្រូវរួម គឺសហភាពសូវៀត និងវៀតណាម ។

ជាការពិតណាស់ ប្រទេសចិន សម្រេចចិត្តវាយលុកចូលប្រទេសវៀតណាម មិនមែនតែលើមូលហេតុជួយរំដោះកម្ពុជាប្រជាធិបតេយ្យតែមួយមុខប៉ុណ្ណោះទេ គឺនៅមានមូលហេតុជាច្រើនទៀត ។

### ២.២) សាធារណរដ្ឋប្រជាមានិតចិនជំនួយផ្នែកយោធាដល់កម្ពុជាប្រជាធិបតេយ្យ

ក្រោយពីទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ កម្ពុជាប្រជាធិបតេយ្យនៅតែត្រូវការជំនួយយ៉ាងច្រើនពីប្រទេសចិន នោះក៏ដោយសារតែរបបនេះមានជម្លោះយ៉ាងខ្លាំងក្លាជាមួយប្រទេសវៀតណាមលើបញ្ហាព្រំដែន ។ មេដឹកនាំខ្មែរក្រហមបានដឹងយ៉ាងច្បាស់ថា ទាំងកងទ័ព និងសព្វាវុធយោធា សុទ្ធតែមិនអាចវាយឈ្នះលើកងទ័ពវៀតណាមបានទេ តែដោយសម្អាងលើប្រទេសចិនដែលជាខ្នងបង្អែក មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជារឿយៗបានបញ្ជូនកងទ័ពរបស់ខ្លួនឲ្យចូលវាយប្រហារលើទឹកដីប្រទេសវៀតណាមដែលមានព្រំប្រទល់ជាប់នឹងព្រំដែនរបស់ប្រទេសកម្ពុជា ។

ដោយផ្អែកលើចំណងមិត្តភាពរវាងប្រទេសទាំងពីរ ប្រទេស

ចិនតែងតែផ្តល់ជំនួយជាបន្តបន្ទាប់ដល់របបកម្ពុជាប្រជាធិបតេយ្យ ។ ចាប់ពីខ្មែរក្រហមទទួលជ័យជម្នះមក ប្រទេសចិនបានបញ្ជូនអ្នកជំនាញខាងកងទ័ពមកសិក្សាស្រាវជ្រាវ និងបានបញ្ជូនអ្នកជំនាញការយោធាមកហ្វឹកហ្វឺនផ្នែកយោធាដល់យោធារបស់ខ្មែរក្រហម ។ ឆ្នាំ១៩៧៦ ប្រទេសទាំងពីរបានចុះកិច្ចព្រមព្រៀងទៅលើវិស័យយោធា ប្រទេសចិនបានយល់ព្រមផ្តល់ជំនួយឥតសំណងផ្នែកយោធាដល់របបកម្ពុជាប្រជាធិបតេយ្យ ។ ផ្អែកលើកិច្ចព្រមព្រៀងនោះ ចិនត្រូវជួយឧបត្ថម្ភដល់របបខ្មែរក្រហមទាំងផ្នែកកងទ័ពជើងគោក ជើងទឹក និងទ័ពអាកាស ។ ក្រោយមក ប្រទេសចិនបានផ្តល់ឲ្យកម្ពុជាប្រជាធិបតេយ្យនូវឧបករណ៍ផ្សាយសំឡេង វិទ្យុទាក់ទង និងយន្តហោះប្រដេញ ។ នៅដើមឆ្នាំ១៩៧៧ ចិនបានផ្តល់ឲ្យរបបខ្មែរក្រហមនូវទឹកប្រាក់ចំនួន១.៤០០លានយេន រថក្រោះ៣០គ្រឿង និងរថពាសដែកចំនួនដប់គ្រឿង ។ ដល់ឆ្នាំ១៩៧៨ ទីក្រុងប៉េកាំងបានប្រគល់ឧទ្ធម្ភាគចក្រប្រយុទ្ធចំណុះជាង៨០០តោនចំនួន២គ្រឿង និងនាវាល្បាតចំនួន បួនគ្រឿង ក្នុងនោះមានបន្ថែមរថក្រោះ២០០គ្រឿង រថពាសដែក៣០០គ្រឿង គ្រាប់រំសេវ៣០.០០០តោន យន្តហោះប្រដេញប្រាំមួយគ្រឿង និងយន្តហោះទម្លាក់គ្រាប់បែកពីរគ្រឿង ។ ចិនបានចាប់ផ្តើមកសាងផ្លូវដែកថ្មីមួយ ដែលភ្ជាប់ក្រុងភ្នំពេញទៅកំពង់សោម និងចំណតអាកាសយានដ្ឋានថ្មីមួយនៅកំពង់ឆ្នាំង ។ នៅមានជំនួយជាច្រើនទៀត ដែលចិនបានប្រគល់ឲ្យរបបខ្មែរក្រហមដូចជាប្រេងឥន្ធនៈ និងសម្ភារយោធាមួយចំនួនធំទៀត ។

ជំនួយផ្នែកយោធារបស់ប្រទេសចិន បានធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យធ្វើទំនើបកម្មលើវិស័យកងទ័ព ទីមួយអាចពង្រឹងវិស័យយោធាទាំងសម្ភារសព្វាវុធ និងលើទឹកចិត្តឲ្យកងទ័ពកាន់តែមានកម្លាំងប្រយុទ្ធ ។ ទីពីគឺ ថែរក្សាសន្តិសុខ សុវត្ថិភាពក្នុងប្រទេស និងសន្តិសុខក្នុងតំបន់ និងទីបីគឺ ពង្រឹងទំនាក់ទំនងផ្នែកយោធារវាងចិន និងកម្ពុជាឲ្យរឹតតែរឹងមាំឡើង ។

**ធី លីកួ**



ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់សមាជិករដ្ឋាភិបាលរួបរួមជាតិនៅប្រទេសចិន អំឡុងឆ្នាំ១៩៧៤ ឬ១៩៧៥ ៖ (១) ម៉ុក សូវង់, (២) បាន យ៉ាន, (៣) ប៉ែន សាផន, (៤) សមមិត្ត ឈុន, (៥) គាត រស្មី, (៦) រឿង ម៉ាច, (៧) ផៅ្វក សាផាន, (៨) ឡូវ៉ង់ ពិក, (៩) ប្រពន្ធ ឌួង សំអុល, (១០) ឌួង សំអុល, (១១) គាត បុប្ផា, (១២) ប្រពន្ធ បាន យ៉ាន, (១៣) សេង លី, (១៤) សុ ផានីតា, (១៥) ឡាយ នារី, (១៦) ទុន ជោតស៊ីរិន, (១៧) ពុំមិកា, (១៨) ចាន់ សារ៉ុត និង (១៩) សមមិត្ត ស៊ា ។

# អតីតកងជីវពលខ្មែរក្រហមចង់ឱ្យតុលាការ បន្តការកាត់ទោស

ក្នុងដំណើរទស្សនកិច្ចនៅសាលាក្តីខ្មែរក្រហមដែលបើកសវនាការពិភាក្សា និងសួរដេញដោលក្នុងសំណុំរឿង០០២ វគ្គមួយ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ធន់ ភួង ជាអតីតកងជីវពល និងជាកងចល័តក្នុងសម័យខ្មែរក្រហមបានមានប្រសាសន៍ថា “ខ្ញុំចង់ឲ្យតុលាការធ្វើការកាត់ទោសជនជាប់ចោទដែលនៅរស់រានមានជីវិតឲ្យបានចប់ចុងចប់ដើម ដើម្បីកុំឲ្យរបបនេះកើតឡើងម្តងទៀត ទោះខ្ញុំទទួលដំណឹងថា បច្ចុប្បន្ន តុលាការកំពុងខ្វះខាតថវិកា និងត្រូវចំណាយពេលវេលាច្រើនទៀតក៏ដោយ” ។

ធន់ ភួង មានអាយុ៦៧ឆ្នាំ មានស្រុកកំណើតនៅឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ភួង មានបងប្អូនប្រាំមួយនាក់ និងមានឪពុកម្តាយជាកសិករ ។ នៅឆ្នាំ១៩៥៩ ភួង បានចូលរៀននៅសាលា បឋមសិក្សាវត្តពុទ្រា ស្ថិតក្នុងភូមិអូរ ។ រៀនដល់ថ្នាក់ទី១០ ភួង ក៏ឈប់រៀនដោយសារតែគាត់មិនមានកង់ជិះទៅរៀនបន្តនៅអនុវិទ្យាល័យមួយស្ថិតនៅទីប្រជុំជនត្រពាំងក្រឡឹង ដែលមានចម្ងាយប្រមាណ១៦ គីឡូម៉ែត្រពីផ្ទះរបស់គាត់ ។

ភួង បានរស់នៅជាមួយឪពុកម្តាយរហូតដល់ឆ្នាំ១៩៦៦ ទើបគាត់បួសជាព្រះសង្ឃនៅវត្តពុទ្រា ក្នុងឃុំអូរ ។ ក្រោយពីបួសបានពីរវស្សា ភួង បានសឹក រួចរៀបការប្រពន្ធ ។

ក្រោយថ្ងៃរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ភួង បានចូលធ្វើជាកងជីវពលភូមិខាងកងទ័ពរំដោះខ្មែរក្រហម ។ នៅ



ធន់ ភួង ពេលផ្តល់បទសម្ភាសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ភួង ពិការដៃស្តាំដោយសារត្រូវគ្រាប់កាំភ្លើង ។

ពេលនោះ ភួង ត្រូវចេញទៅរស់នៅព្រៃជាមួយប្រជាជន ដែលជឿជាក់លើចលនារំដោះនោះ ហើយគាត់មានភារកិច្ចស៊ើបការពីទាហាន លន់ នល់ យកមកប្រាប់ប្រជាជនដើម្បីឲ្យគេចខ្លួនពីការវាយប្រហារ ។

នៅពេលកងទ័ពរំដោះខ្មែរក្រហមទទួលជ័យជម្នះនៅខែមេសា ឆ្នាំ១៩៧៥ អង្គការបានដក ភួង ពីកងជីវពលភូមិឲ្យទៅនៅកងចល័តស្រុកជាំសង្កែ ភូមិភាគនិរតី ក្រោមការដឹកនាំរបស់ឈ្មោះ អុន (ក្រោយមក ឈ្មោះ សុខ មកដឹកនាំជំនួស) រួមជាមួយយុវជនដែលប្រមូលមកពីខេត្តកោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងខេត្តតាកែវ ។ នៅទីនោះ អង្គការបានចាត់តាំង ភួង ឲ្យលើកទំនប់ព្រៃក្មេង ជាំសង្កែ ដោយផ្តល់ អាហារឲ្យហូបឆ្អែត ។

នៅខែសីហា ឆ្នាំ១៩៧៨ អង្គការបានផ្លាស់ ភួង ពីកងចល័តស្រុកជាំសង្កែ ឲ្យទៅនៅកងចល័តតំបន់៣២ ដែលមានទីតាំងនៅព្រែកបារាំង ភូមិកំពង់ហ្លួង ស្រុកខ្សាច់កណ្តាល ។ នៅទីនោះ អង្គការបានចាត់តាំង ភួង ឲ្យធ្វើការជាទម្ងន់ ដូចជា លីបាវស្រូវ កាប់ពង្រាបដីស្រែ និងភ្ជួររាស់ដោយផ្តល់អាហារឲ្យហូបបន្តិចបន្តួចប៉ុណ្ណោះ ។ ភួង ធ្វើការនៅទីនោះបានមួយរយៈប៉ុណ្ណោះ ក៏ទឹកជំនន់ជន់ឡើងលិចលង់ស្រូវ ដំណាំ និង កន្លែងស្នាក់នៅ ។ ឃើញដូច្នេះហើយ ទើបអង្គការរំសាយ ភួង និងក្រុមរបស់គាត់ឲ្យមករស់នៅផ្ទះជាមួយប្រពន្ធ និងកូនពីរនាក់ មួយរយៈ ។

ក្រោយពេលទឹកស្រក អង្គការបានចាត់តាំង ភួង ឲ្យទៅធ្វើការនៅក្នុងកងចល័តតំបន់៣២ ដដែល រហូតដល់កងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជា នៅឆ្នាំ១៩៧៩ ។ នៅក្នុងឆ្នាំដដែល ភួង បានរត់គេចចេញពីខ្មែរក្រហមទៅចូលរួមជាមួយចលនារំដោះ (ទើបបង្កើតថ្មី) ដែលមានការបែងចែកចេញជាកងរយ និងកងវរៈ ក្រោមការគ្រប់គ្រងរបស់មេបញ្ជាការឈ្មោះ សាត់ (ត្រូវខ្មែរក្រហមបាញ់សម្លាប់) ។ ក្រោយមក ដោយសារខ្វះខាតស្បៀងអាហារ ភួង និងកងរបស់គាត់ប្រមាណដប់នាក់ទៀត បានចេញទៅយកស្រូវដែលយោធាខ្មែរក្រហមយកទៅលាក់ទុកនៅក្នុងព្រៃដើម្បីកុំឲ្យកងទ័ពវៀតណាមរកឃើញ ។ ប៉ុន្តែស្រាប់តែពេលនោះ ប្រជាជនដែលស្នាក់នៅយាមការពារស្រូវបានបាញ់គាត់ ត្រូវចំដៃខាងស្តាំបណ្តាលឲ្យពិការដៃរហូតមកដល់សព្វថ្ងៃ ។

ភួង ត្រូវស្នាក់នៅព្យាបាលនៅក្នុងព្រៃរយៈពេលមួយខែ ទើបគាត់ត្រឡប់មករស់នៅជួបជុំជាមួយប្រពន្ធ និងកូននៅស្រុកកំណើតវិញ ។

ក្រោយមក ភួង ត្រូវកងទ័ពរណសិរ្សសាមគ្គីរំដោះជាតិកម្ពុជាចាត់តាំងឲ្យធ្វើជាប្រធានក្រុមសាមគ្គីប្រវាស់ដៃ ហើយនៅឆ្នាំ១៩៨៥ គាត់ត្រូវរដ្ឋអំណាចជ្រើសរើសឲ្យធ្វើជាប្រធានភូមិអូរល្ហុរហូតមកដល់សព្វថ្ងៃ ។

**សោម ប៊ុនថន**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី “សំឡេងអំពើប្រល័យពូជសាសន៍ៈ យុត្តិធម៌ និងការអត់ឃ្មាន” ដែលចាក់ផ្សាយតាមស្ថានីយ៍វិទ្យុដូចខាងក្រោមរៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ៖

◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង១ រសៀល និងម៉ោង៧និង៣០ នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ ព្រឹក និងម៉ោង៨រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៨រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ០៩២ ១៦៨ ៥៤៣ ។

◆ និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា

◆ រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍

# ទិម យ៉ុង : ជីវិតមិនអាចដូចដើមក្រោយរបបខ្មែរក្រហម

ដោយអង្គុយផ្អែកខ្នងទៅនឹងរបងក្នុងបរិវេណសាលាក្ដីខ្មែរក្រហម បុរសវ័យ៥២ឆ្នាំ មានសក់ពណ៌ល្បាយអាចម៍ខ្លា មានស្រុកកំណើតនៅនិរតីនៃប្រទេសកម្ពុជា និងចម្ងាយប្រហែលជាង ១០០គីឡូម៉ែត្រពីក្រុងភ្នំពេញ មានទឹកមុខសប្បាយរីករាយនៅពេលដែលគាត់បានមកដល់សាលាក្ដីខ្មែរក្រហមជាលើកដំបូង ។ គាត់មានឈ្មោះ ទិម យ៉ុង ។

យ៉ុង បានចងចាំយ៉ាងច្បាស់ ចំពោះអតីតកាលដ៏សោកសៅក្នុងរបបខ្មែរក្រហម ដែលបានឆក់យកជីវិតមនុស្សរាប់លាននាក់ និងបានបំផ្លាញដល់សរសៃឈាមសង្គមស្ទើរទាំងស្រុង ។ យ៉ុង ជាកូនពៅក្នុងចំណោមបងប្អូនប្រាំមួយនាក់ ។ បច្ចុប្បន្ន យ៉ុង ជាមេគ្រួសារ មានភរិយាឈ្មោះ ម៉េត គា ហើយក៏ជាឪពុករបស់កូនបួននាក់ ។ អ្នកទាំងពីរប្រកបមុខរបរធ្វើស្រែចម្ការ និងចិញ្ចឹមសត្វពាហនៈ ។



ទិម យ៉ុង ពេលផ្ដល់បទសម្ភាសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងខែតុលា

រឿងហេតុដំបូងដែលនៅជិតដាម និងស្ថិតនៅក្នុងការចងចាំរបស់ យ៉ុង គឺរដ្ឋប្រហារថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ដែលបានទម្លាក់សម្ដេច នរោត្ដម សីហនុ ចេញពីអំណាច ។ កាលនោះ កងទ័ពរំដោះខ្មែរក្រហមបានចូលកាន់កាប់ស្រុកភូមិរបស់គាត់ ហើយទាហាន លន់ នល់ បានបាញ់ផ្លោងជាញឹកញាប់បណ្ដាលឲ្យឆេះផ្ទះប្រជាជន និងសម្លាប់មនុស្ស ។ ខ្មែរក្រហមទាំងនោះ សុទ្ធតែជាយោធាធ្វើការតស៊ូប្រយុទ្ធនៅបន្ទាយលង្វែក រួចហើយទៅបោះទីតាំងនៅក្នុងស្រុកភូមិរបស់ យ៉ុង ស្ថិតក្នុងភូមិត្រពាំងព្រីង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ជាទីដែលខ្មែរក្រហមទាំងនោះ អាចលាក់ខ្លួន គេចពីការចាប់ខ្លួន និងការតាមសម្លាប់ ។ ខ្មែរក្រហមទាំងនោះមានច្រើនក្រុម ពាក់សម្លៀកបំពាក់ពណ៌ខ្មៅ ជាមួយនឹងស្បែកជើងកង់ឡាន ។ យោធានោះបោះទីតាំងនៅក្នុងភូមិពេលថ្ងៃ ហើយចាកចេញនៅពេលយប់ ឬក្នុងអំឡុងពេលយន្តហោះទម្លាក់គ្រាប់បែក ។ យ៉ុង បានស្គាល់ខ្មែរក្រហមដោយសារតែសម្លៀកបំពាក់ពណ៌ខ្មៅ ។

ទាហាន លន់ នល់ បានធ្វើការវាយប្រហារតាមផ្លូវអាកាសមកលើស្រុកភូមិរបស់ យ៉ុង យ៉ាងដំណំ ដោយសម្លាប់ខ្មែរក្រហម និងអ្នកភូមិយ៉ាងច្រើនដែលមិនបានរត់ចូលក្នុងលេណដ្ឋានទាន់ពេល ។ យ៉ុង បាននិយាយថា គ្រាប់បែកដែលទម្លាក់មកលើស្រុកភូមិរបស់គាត់ បានផ្ទុះបំបែកសាច់មនុស្សជាចម្រៀកៗ ហើយពោះវៀនបានខ្ទាតទៅទើរលើចុងឈើ ។ ឪពុកម្ដាយរបស់គាត់ តែងតែហៅកូនៗទាំងអស់លាក់ខ្លួននៅក្នុងលេណដ្ឋាន នៅពេលដែលគាត់សង្ស័យថា មានការទម្លាក់គ្រាប់បែក ។ ស្រុកភូមិត្រូវរងការបំផ្លាញ និងភាពវឹកវររហូតដល់របបខ្មែរក្រហមចូលត្រួតត្រាប្រទេសកម្ពុជាពេញលេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

អ្នកភូមិទាំងអស់ត្រូវបានអង្គការចាត់តាំងតាមអាយុឲ្យធ្វើការងារក្នុងសហករណ៍ ។ យ៉ុង ត្រូវអង្គការបំបែកចេញពីគ្រួសារ ប៉ុន្តែមិនបានទៅណាឆ្ងាយពីស្រុកភូមិរបស់ខ្លួនទេ ។ គាត់ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងកងហា មានចំនួនមនុស្សប្រុសស្រីស្មើគ្នា ។ ការងាររបស់គាត់ត្រូវរែកដីមួយម៉ែត្រគូប ក្នុងមួយថ្ងៃ ដើម្បីលើកទំនប់តាបៅ ចម្ងាយកន្លះគីឡូម៉ែត្រពីភូមិ ។ យ៉ុង ត្រូវរែកដី

បីវេន ក្នុងមួយថ្ងៃ ចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង១១ព្រឹក, ពីម៉ោងមួយរសៀលដល់ម៉ោង៤រសៀល និងពីម៉ោង៥ល្ងាច ដល់ម៉ោង៧យប់ ។

ទោះបីជាត្រូវធ្វើការងារហួសកម្លាំង យ៉ុង ទទួលបានបបររាវៗ ហើយជួនកាលបានបាយម្តងម្កាល ។ ក្រៅពីនេះ កងហាររបស់ យ៉ុង ទទួលបានសម្លម្ជូរព្រលឹតរលួយដូចទឹក ។ យ៉ុងបានឆ្លៀតទៅរកត្រីដើម្បីបំពេញក្រពះដែរ ប៉ុន្តែគាត់ត្រូវប្រយ័ត្នប្រយែងបំផុត ពីព្រោះអង្គការប្រឆាំងដាច់ខាត ទៅនឹងការដាក់ដាទ្រព្យឯកជន សូម្បីតែនេសាទត្រីក៏ដោយ ។ បុគ្គលណាត្រូវអង្គការរកឃើញថា ធ្វើនេសាទជាលក្ខណៈឯកជននោះ បុគ្គលនោះនឹងត្រូវដាក់ទណ្ឌកម្ម ឬធ្វើបាបរហូតដល់ស្លាប់ក៏មាន ។

យ៉ុង បានចងចាំថា គណៈស្រុកសាមគ្គីមានជ័យឈ្មោះ យាយ ភឿន អ្នកស្រុកផ្សារត្រាច ជាមេដឹកនាំចិត្តកំណាច ដែលមិនគ្រាន់តែមានរូបរាងស្គមចម្លែកប៉ុណ្ណោះទេ ប៉ុន្តែជាងនេះទៅទៀតគាត់ជាស្ត្រីចិត្តដែកគ្មានមេត្តា រាល់លើកដែលគាត់អនុវត្តលើសផែនការអង្គការ ។ គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យត្អូញត្អែរចំពោះការហូបចុកនោះឡើយ ។

មានគ្រាមួយនោះ យ៉ុង បានឃើញមិត្តម្នាក់ក្នុងកងរបស់ខ្លួន ត្រូវអង្គការធ្វើបាបយ៉ាងព្រៃផ្សៃ ដោយសារគាត់ត្រូវបានចោទប្រកាន់ថា ជាជនសេរី មិនព្រមធ្វើការងារអង្គការ ។ បុរសម្នាក់នោះ ត្រូវឈ្លបខ្មែរក្រហមបួននាក់ដាក់ខ្នោះជើង និងខ្នោះដៃ ។ ក្រោយមក គាត់ត្រូវបានបណ្តើរទៅមន្ទីរ ។ ចាប់តាំងពីពេលនោះមក យ៉ុង បាត់ដំណឹងពីមិត្តម្នាក់នោះ ។

បន្ទាប់មក កងហាររបស់ យ៉ុង ត្រូវបានចាត់តាំងឲ្យដឹកប្រឡាយត្រពាំងព្រីង មានទីតាំងនៅក្នុងស្រុកភូមិដដែល ។ យ៉ុង នៅតែទទួលរងលក្ខខណ្ឌការងារលំបាកៗដដែល ។ កាលនោះ ស្ត្រីចំណាស់ម្នាក់ឈ្មោះ ឡេង ដែលជាសមាជិកចុងភៅសហករណ៍ ត្រូវបានអង្គការដាក់ទណ្ឌកម្មដោយសារតែគាត់ជាប់សាច់ឈាមជាជនជាតិវៀតណាម ។ ក្នុងរបបខ្មែរក្រហម វៀតណាម ជាពូជសាសន៍មួយដែលខ្មែរក្រហមដោកម្មេចឲ្យខាងតែបាន ។ គណៈស្រុកឈ្មោះ យាយ ភឿន បានបញ្ជាយោធាខ្មែរក្រហមឲ្យចាប់ស្ត្រីនោះដាក់ខ្នោះជើង ខ្នោះ ដៃ រួចបណ្តើរទៅមន្ទីរដើម្បីទទួលទណ្ឌកម្ម ។ យ៉ុង និយាយថា នេះគឺជាព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់សម្រាប់គាត់ ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្រូពេទ្យគ្មានជំនាញវិជ្ជាជីវៈភាគច្រើនជាអ្នកស្រែចម្ការ ត្រូវបានតែងតាំងឲ្យបំពេញមុខងារខាងគាំពារសុខភាព ។ កាលនោះ យ៉ុង ធ្លាក់ខ្លួនឈឺ ប៉ុន្តែគាត់ទទួលបានតែថ្នាំអាចម៍ទន្សាយតែប៉ុណ្ណោះ ។ គាត់ត្រូវស៊ូទ្រាំនឹងជំងឺរបស់ខ្លួន ទោះបីជាត្រូវពុះពារយ៉ាងណាក៏ដោយ ។

មានគ្រាមួយ យ៉ុង ទទួលបានត្រីមួយចំនួនពីបងប្រុសរបស់ខ្លួន ឈ្មោះ ទិម តុន ដែលជាកងសេដ្ឋកិច្ចត្រូវនេសាទត្រីនៅទន្លេលង្វែក ។ យ៉ុង ចម្អិនត្រីនោះ រួចហូបដោយលួចលាក់ ។ ការហូបឯកជន គឺជាការប្រឆាំងគោលនយោបាយរបស់ខ្មែរក្រហម ។

នៅចុងឆ្នាំ១៩៧៨ យ៉ុង ត្រូវបានចាត់តាំងឲ្យធ្វើជាចុងភៅកងចល័ត ។ ពេលនោះ ជីវិតរបស់គាត់បានប្រសើរជាងមុន ។ គាត់ទទួលបានអាហារច្រើនជាងមុន ។ ទោះបីជាយ៉ាងណាក៏ដោយ ការងារនេះ មានរយៈពេលតែមួយខែតែប៉ុណ្ណោះ ក្រោយមកវៀតណាមបានវាយសម្រុកចូលស្រុកភូមិរបស់គាត់ ។ គណៈស្រុកចិត្តកំណាចឈ្មោះ យាយ ភឿន បានបញ្ជាឲ្យកងហាររបស់ យ៉ុង រត់ឡើងភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ ជាមួយគាត់ ។ មុនពេលរត់គេចខ្មែរក្រហមបានឲ្យកាំភ្លើងមួយដើមទៅ យ៉ុង ដើម្បីបាញ់ទាហានវៀតណាមតាមផ្លូវ ។ ប៉ុន្តែគាត់មិនបានបាញ់យួននៅពេលរត់គេចនោះឡើយ ។ ដោយសារតែកង្វះអាហារ យ៉ុង បានចាកចេញពីស្រុកទឹកផុស ដើម្បីគេចត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួនវិញ ។ យ៉ុង បានធ្វើដំណើរកាត់ព្រៃក្រាស់ នាពេលយប់ដើម្បីគេចពីការតាមដាន ហើយត្រូវដេកនៅកន្លែងផ្សេងៗជាច្រើន ។ គាត់ត្រូវចំណាយពេលពីរថ្ងៃដើម្បីទៅដល់ភូមិកំណើត ។ ប៉ុន្តែនេះជាការរត់គេចដ៏ប្រថុយប្រថានបំផុត ពីព្រោះគាត់ទទួលដំណឹងពីអ្នករត់គេចដទៃថា គាត់ត្រូវបានប្រកាសឲ្យចាប់ខ្លួន និងបាញ់សម្លាប់នៅហ្នឹងកន្លែង ។

យ៉ុង បានមកដល់ភូមិកំណើតដោយសុវត្ថិភាព ។ អកុសលជីវិតរបស់ យ៉ុង នៅតែត្រូវញាំញីដោយទុក្ខព្រួយ ដែលបាត់បង់បងប្អូន និងឪពុកម្តាយ ។ ទោះបីជាមានជីវិតរស់នៅក៏ដោយ ជីវិតមួយនេះនៅតែមិនដូចដើមនោះឡើយ ។

**ភួង ច័ន្ទប្រណិត**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬកា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ ទីកន្លែង ៖ អាគារ "ក" ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# សំណុំរឿងពាក់ព័ន្ធនឹង ហាន់ ហ្វ្រែង និងព័ត៌មានថ្មីៗ ទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម អំពីការបែងចែកស្រូវនៅក្នុងរបបខ្មែរក្រហម

## សំឡេងយុត្តិធម៌ ៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

***កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី៨)***

*ការផ្សាយនៅក្នុងវគ្គទី៨នេះ ផ្តោតសំខាន់ទៅលើការកាត់ទោសលោក ហាន់ ហ្វ្រែង (Hans Frank) ដែលជាអតីតសមាជិករបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ ដោយតុលាការយោធាអន្តរជាតិ (International Military Tribunal) បន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់ និងការបកស្រាយរបស់តុលាការទាក់ទងនឹងការអត់ឃ្លាន ។ នៅក្នុងការផ្សាយក្នុងវគ្គទី៨នេះ យើងខ្ញុំក៏លើកយកព័ត៌មានថ្មីៗទាក់ទងនឹងភ័ស្តុតាងបន្ថែមទៀត ដែលនិយាយអំពីការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដោយយោងទៅលើសក្ខីកម្មរបស់ រស់ ស៊ុយ ដែលធ្វើឡើងនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកាលពី ខែមេសា ឆ្នាំ២០១៣ ។*

***សេចក្តីផ្តើម ៖ ការអត់ឃ្លានក្នុងការចូលកាន់កាប់ប្រទេសប៉ូឡូញក្នុងអំឡុងសង្គ្រាមលោកលើកទី២***



*កម្មាភិបាលខ្មែរក្រហមកំពុងបោកបែនស្រូវក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

បន្ទាប់ពីសង្គ្រាមលោកលើកទី២បានបញ្ចប់ ប្រទេសសម្ព័ន្ធមិត្តដែលទទួលបានជ័យជំនះ រួមមាន ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងរុស្ស៊ី បានបង្កើតតុលាការមួយ នៅទីក្រុងនូរឹមប៊ឺក *(Nuremberg)* ក្នុងប្រទេសអាល្លឺម៉ង់ ដែលបាននាំយកសមាជិកជាន់ខ្ពស់មួយចំនួនរបស់បក្សណាហ្ស៊ី អាល្លឺម៉ង់ មកធ្វើការជំនុំជម្រះពីបទឧក្រិដ្ឋកម្មអន្តរជាតិ ។ ក្នុងនោះលោក ហាន់ ហ្វ្រែង ដែលមានមុខតំណែងជាប្រធានរដ្ឋបាលស៊ីវិល និងក្រោយមកទៀត ជាអ្នកគ្រប់គ្រងទូទៅដែលកាន់កាប់ប្រទេសប៉ូឡូញ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ត្រូវបានតុលាការយោធាអន្តរជាតិធ្វើការជំនុំជម្រះទោស ។ លោក ហ្វ្រែង គឺជាអ្នកទទួលបន្ទុកលើកិច្ចការផ្សេងៗរបស់អាល្លឺម៉ង់ នៅក្នុងប្រទេសប៉ូឡូញ ក្នុងអំឡុងពេលសង្គ្រាម ។ ក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់អាល្លឺម៉ង់ មកលើប្រទេសប៉ូឡូញ ប្រជាជនប៉ូឡូញជាច្រើនត្រូវបានបង្ខំឲ្យធ្វើការជាច្រើនម៉ោងដើម្បីផលិតទំនិញផ្សេងៗ ដែលក្នុងនោះរួមមានស្បៀងអាហារដើម្បីផ្គត់ផ្គង់ដល់ការធ្វើសង្គ្រាមរបស់អាល្លឺម៉ង់ ។ ស្របពេលជាមួយគ្នានេះដែរ ប្រជាជនប៉ូឡូញទទួលបានរបបអាហារតិចតួចបំផុត ដោយសារតែស្បៀងអាហាភាគច្រើនត្រូវបានផ្គត់ផ្គង់ដល់យោធាអាល្លឺម៉ង់ក្នុងការធ្វើសង្គ្រាម ។ បន្ទាប់ពីបានពិចារណាទៅលើតួនាទីរបស់ លោក ហ្វ្រែង ក្នុងការមើលការខុសត្រូវរបស់អាល្លឺម៉ង់ទៅលើប្រទេសប៉ូឡូញ ចៅក្រមតុលាការយោធាអន្តរជាតិបានរកឃើញថា លោក ហ្វ្រែង ពិតជាមានទោសទាក់ទងនឹងបទចោទប្រកាន់ផ្សេងៗ រួមមាន ទំនួលខុសត្រូវរបស់លោក ហ្វ្រែង ទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចជា ការសម្លាប់ អំពើឃាតកម្ម ការយកប្រជាជនប៉ូឡូញធ្វើជាទាសករ ការនិរទេស និងសកម្មភាពសាហាវព្រៃផ្សៃផ្សេងទៀត ដែលប្រឆាំងនឹងប្រជាជនប៉ូឡូញ ។ ការផ្តន្ទាទោសទាំងនេះ ផ្តោតសំខាន់ ទៅលើតួនាទីរបស់ លោក ហ្វ្រែង ដែលបានប្រព្រឹត្តអំពើសាហាវព្រៃផ្សៃទៅលើប្រជាជនប៉ូឡូញ ដើម្បីផ្គត់ផ្គង់ការធ្វើសង្គ្រាមរបស់អាល្លឺម៉ង់ ។

នៅក្នុងសំណុំរឿង លោក ហ្វ្រែង ចៅក្រមបានកត់សម្គាល់ឃើញថា នៅក្នុងគោលនយោបាយរបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ លោក ហ្វ្រែង បានថ្លែងថា "ប្រទេសប៉ូឡូញគួរតែបានចាត់ទុកដូចជាប្រទេសដែលស្ថិតក្រោមអាណានិគម ហើយប្រជាជនប៉ូឡូញនឹងក្លាយជាទាសកររបស់ចក្រភពអាល្លឺម៉ង់" ។ ចៅក្រមបានសន្និដ្ឋានថា "ភ័ស្តុតាងទាំងឡាយបានសបញ្ជាក់ឲ្យឃើញពីគោលនយោបាយរបស់អាល្លឺម៉ង់ ក្នុងការកាន់កាប់ប្រទេសប៉ូឡូញ ដែលផ្អែកទៅលើការបំផ្លិចបំផ្លាញប្រជាជាតិប៉ូឡូញទាំងមូល និងការកេងយកផលប្រយោជន៍ពីប្រជាជន និងសេដ្ឋកិច្ចរបស់ប៉ូឡូញ ដើម្បីបម្រើដល់ការធ្វើសង្គ្រាមរបស់អាល្លឺម៉ង់ ។ ជនដែលប្រឆាំងទាំងអស់ត្រូវបានកម្ទេចចោលយ៉ាងសាហាវឃោរឃៅបំផុត" ។ ជាលទ្ធផលនៃការបំផ្លិចបំផ្លាញដោយគ្មានមេត្តានេះ តុលាការបានកត់សម្គាល់ថា លក្ខខណ្ឌធ្វើការដ៏អាក្រក់ និងការដកហូតសិទ្ធិទទួលបានចំណីអាហារ បានបង្កឲ្យប្រជាជនប៉ូឡូញស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយសារជំងឺ និងការអត់ឃ្លាន ។ តុលាការក៏បានរកឃើញថា ៖

> *"តម្រូវការផ្នែកសេដ្ឋកិច្ច ដែលដាក់ទៅលើប្រទេសប៉ូឡូញ គឺច្រើនលើសពីអ្វីដែលជាតម្រូវការរបស់កងទ័ព ហើយតម្រូវការនេះមិនសមាមាត្រទៅនឹងធនធានរបស់ប្រទេសប៉ូឡូញឡើយ ។ ទិន្នផលស្បៀងរបស់ប៉ូឡូញដែលត្រូវបានដឹកតាមកប៉ាល់ទៅកាន់ប្រទេសអាល្លឺម៉ង់ក្នុងទ្រង់ទ្រាយធំ ដែលបង្កឲ្យមានការថយចុះបរិមាណស្បៀងសម្រាប់ប្រជាជនប៉ូឡូញ ដែលជាកត្តាបង្កឲ្យមាន គ្រោះអត់ឃ្លាន និងជំងឺរាតត្បាតបានរីករាលដាលនៅទូទាំងប្រទេស ។ ស្បៀងមួយចំនួន ត្រូវបានយកទៅចិញ្ចឹមតែប្រជាជនដែលធ្វើការងារកសិកម្មប៉ុណ្ណោះ ។ ចំណែកឯប្រជាជនមួយចំនួនផ្សេងទៀតមិនត្រូវបានយកចិត្តទុកដាក់ឡើយ ។ មេធាវីការពារក្តីរបស់លោក ហ្វ្រែង បានលើកឡើងថា ការឈឺចាប់មួយចំនួនបានកើតឡើងដោយសារតែការហែកហួរនៃសង្គ្រាម និងវិបត្តិសេដ្ឋកិច្ច ។ ប៉ុន្តែទំហំនៃការឈឺចាប់ទាំងនោះបានកើនឡើងថែមទៀត ដោយសារតែគោលនយោបាយបំផ្លិចបំផ្លាញផ្នែកសេដ្ឋកិច្ចរបស់អាល្លឺម៉ង់"* ។

ការប្រើប្រាស់កម្លាំងពលកម្មប្រជាជនប៉ូឡូញរបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ មានលក្ខណៈស្រដៀងគ្នាទៅនឹងខ្មែរក្រហម ដែលបានប្រើប្រាស់កម្លាំងពលកម្មប្រជាជនកម្ពុជាក្នុងការបម្រើដល់

បដិវត្តន៍របស់ខ្លួនដែរ ។ នៅក្នុងស្ថានភាពទាំងពីរ ទាំងបក្សណាហ្ស៊ីអាល្លឺម៉ង់ និងខ្មែរក្រហម ប្រជាជនស៊ីវិលទទួលបាននូវសិទ្ធិមួយចំនួនតូចតែប៉ុណ្ណោះ ដូចជា ចំណីអាហារជាដើម ។ ទាំងនៅក្នុងប្រទេសប៉ូឡូញ និងប្រទេសកម្ពុជា ប្រជាជនស៊ីវិលទទួលរងនូវលក្ខខណ្ឌរស់នៅដ៏អាក្រក់ រួមមាន គ្រោះអត់ឃ្លាន ជំងឺ និងការអត់អាហារ ដែលឈានទៅដល់ការស្លាប់ប្រជាជនក្នុងទ្រង់ទ្រាយធំ ។ ជាចុងក្រោយ តុលាការបានរកឃើញថា «លោក ហ្វ្រែង ជាបុគ្គលមួយរូបដែលបានដឹង និងមានឆន្ទៈក្នុងការប្រព្រឹត្តទង្វើឃោរឃៅក្នុងប្រទេសប៉ូឡូញ ។ មិនតែប៉ុណ្ណោះ ការធ្វើទុក្ខបុកម្នេញផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសប៉ូឡូញ បានបង្កឲ្យប្រជាជនយ៉ាងច្រើនស្លាប់ដោយសារការអត់ឃ្លាន ។ លោក ហ្វ្រែង ក៏ជាប់ពាក់ព័ន្ធនឹងការនិរទេសប្រជាជនប៉ូឡូញជាងមួយលាននាក់ទៅកាន់ប្រទេសអាល្លឺម៉ង់ដើម្បីធ្វើជាទាសករ និងជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិជ្វីហ្វ (Jews) យ៉ាងហោចណាស់បីលាននាក់» ។

សេចក្តីសម្រេចរបស់តុលាការយោធាអន្តរជាតិ ប្រឆាំងនឹងលោក ហ្វ្រែង ជាឧទាហរណ៍មួយ ដែលបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចយកមកជំនុំជម្រះបុគ្គលទាំងឡាយណាដែលរួមចំណែកក្នុងការបង្កឲ្យមានការអត់ឃ្លានចំពោះប្រជាជនស៊ីវិលដែលបណ្តាលឲ្យប្រជាជនយ៉ាងច្រើនត្រូវស្លាប់ ក្នុងលក្ខខណ្ឌរស់នៅមិនសមជាមនុស្ស និងការរើសអើងផ្សេងៗ ។

ការផ្តន្ទាទោស លោក ហ្វ្រែង ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិទាក់ទងនឹងការសម្លាប់ក្នុងទ្រង់ទ្រាយធំ បានបង្ហាញថា បើទោះបីជាជនជាប់ចោទមិនបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅលើបុគ្គលណាម្នាក់ដោយផ្ទាល់ក៏ដោយ ក៏ការសម្លាប់ក្នុងទ្រង់ទ្រាយធំនោះ បានបង្ហាញយ៉ាងច្បាស់ថា ការអត់ឃ្លានបានកើតឡើងចំពោះប្រជាជនស៊ីវិលជាទូទៅ ។ នៅក្នុងករណីនៃការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ការចោទប្រកាន់ចំពោះការសម្លាប់រង្គាលអាចបង្ហាញពីការសម្រេចចិត្តរបស់មេដឹកនាំខ្មែរក្រហមនៅក្នុងទីក្រុងភ្នំពេញដែលបានបង្កឲ្យប្រជាជនតាមទីជនបទទូទាំងប្រទេសស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ ។

តុលាការយោធាអន្តរជាតិ ក៏បានរកឃើញដែរថា លោក ហ្វ្រែង មានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀតដូចជាការចូលរួមនៅក្នុង «ផែនការចុងក្រោយ» *(the Final Solution)* របស់បក្សណាហ្ស៊ីអាល្លឺម៉ង់ក្នុងការសម្លាប់ជនជាតិជ្វីហ្វទាំងអស់ដែលរស់នៅអឺរ៉ុប ។ តុលាការរកឃើញថា នៅក្នុង «ផែនការចុងក្រោយ» របស់បក្សណាហ្ស៊ីអាល្លឺម៉ង់ ជនជាតិជ្វីហ្វដែលរស់នៅក្នុងតំបន់ដែលគ្រប់គ្រងដោយអាល្លឺម៉ង់ទាំងអស់ «ត្រូវបានបង្ខំឲ្យរស់នៅដាច់ដោយឡែក និងក្លាយជាជនរងគ្រោះនៃច្បាប់រើសអើង ។ មិនតែប៉ុណ្ណោះ ជនជាតិជ្វីហ្វទាំងអស់នោះ ត្រូវបានដកហូតសិទ្ធិទទួលបានចំណីអាហារទទួលរងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ជាលក្ខណៈប្រព័ន្ធ» ។ ការធ្វើទុក្ខបុកម្នេញរបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ទៅលើជនជាតិជ្វីហ្វ មានលក្ខណៈស្រដៀងគ្នាទៅនឹងការដឹកនាំរបស់ខ្មែរក្រហម ដែលបានបង្ហាញពីការស្អប់ខ្ពើមទៅលើប្រជាជនថ្មី ។ ប្រជាជនថ្មីជាមុខសញ្ញាមួយក្នុងចំណោមប្រជាជនទូទាំងប្រទេសដែលទទួលបាននូវលក្ខខណ្ឌរស់នៅតិចតួចបំផុត ដូចជាអាហារជម្រក ការថែទាំសុខភាព និងការសម្រាកជាដើម ។

## ភស្តុតាងថ្មីៗដែលរកឃើញនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលពាក់ព័ន្ធនឹងការចែកចាយស្រូវនៅក្នុងរបបខ្មែរក្រហម

ដូចដែលបានលើកឡើងនៅក្នុងវគ្គមុនៗរួចមកហើយ គ្មានរបាយការណ៍មួយណាបានបង្ហាញពីចំនួនស្រូវដែលបានផលិតនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម និងចំនួនស្រូវដែលបាននាំចេញទៅក្រៅប្រទេសនោះទេ ។ បើទោះជាមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើននាក់រាប់បញ្ចូលទាំងកម្មាភិបាលខ្មែរក្រហមបានលើកឡើងក្នុងបទសម្ភាសន៍ថា ខ្លួនបានឃើញចំនួនស្រូវយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាដកហូតពីប្រជាជន និងរៀបចំសម្រាប់ការនាំចេញក៏ដោយ ក៏អ្នកដែលរស់រានមានជីវិតទាំងនោះ មិនបានដឹងច្បាស់ពីដំណើរការនៃការនាំចេញពិតប្រាកដនោះទេ ។ ប៉ុន្តែ នៅក្នុងសក្ខីកម្មរបស់លោក រស់ ស៊ុយ ដែលជាអ្នកគ្រប់គ្រងឃ្លាំងរបស់ខ្មែរក្រហម នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានស្រាយបំភ្លឺពីដំណើរការផលិត និងការនាំចេញស្រូវនៅក្នុងរបបខ្មែរក្រហម ។ លោក រស់ ស៊ុយ បានប្រាប់ថា គាត់ធ្លាប់ធ្វើការក្នុងឃ្លាំងពីរកន្លែងដែលស្ថិតនៅក្នុងនិងជុំវិញក្រុងភ្នំពេញ ចន្លោះពីឆ្នាំ១៩៧៥ ដល់

ឆ្នាំ១៩៧៩ ។ គាត់គិតថា នៅពេលនោះយ៉ាងហោចណាស់ក៏មានឃ្លាំងស្រដៀងគ្នានេះមួយចំនួនផ្សេងៗទៀតមាននៅក្នុងតំបន់នេះដែរ ។ លោក រស់ ស៊ុយ បានបញ្ជាក់ថាមានតែស្រូវទេ ដែលត្រូវបានចែកចាយនៅក្នុងប្រទេស ។ ចំណែកឃ្លាំងដែលគាត់គ្រប់គ្រងមានម៉ាស៊ីនកិនស្រូវ៤-៥គ្រឿង ដើម្បីដំណើរការកិនស្រូវសម្រាប់បំពេញផែនការនាំចេញរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាមួយគ្នានេះដែរ លោក រស់ ស៊ុយ បានលើកឡើងថាស្រូវត្រូវបានរក្សាទុកនៅក្នុងឃ្លាំងសម្រាប់ការបញ្ជាទិញ នៅពេលដែលផលិតផលដទៃទៀតដូចជា អំបិល និងស៊ីម៉ង់ត៍ ត្រូវបានចែកចាយពីឃ្លាំងរដ្ឋទៅកាន់ទីតាំងផ្សេងៗនៅក្នុងប្រទេសកម្ពុជា ។ សក្ខីកម្មរបស់លោក រស់ ស៊ុយ មានភាពស្រដៀងគ្នាទៅនឹងការលើកឡើងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀត ដែលបានផ្តល់បទសម្ភាសន៍ជាមួយលោកសាស្ត្រាចារ្យ បែន ឃៀនិន *(Ben Kiernan)* ដែលបានរៀបរាប់ថា ខ្លួនបានឃើញទូកដឹកស្រូវតាមទន្លេជាច្រើនធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ ។

ឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាមួយចំនួន ដូចជាឯកសាររបស់គណៈកម្មាធិការពាណិជ្ជកម្មរដ្ឋ នៅក្រុងកំពង់សោមក៏បានពិពណ៌នាស្រដៀងគ្នាទៅនឹងអ្វីដែលលោក រស់ ស៊ុយ បានលើកឡើងដែរ ។ ឯកសារទាំងនោះបានបង្ហាញពី «ចំណូលនិងចំណាយ» នៃទិន្នផលស្រូវដែលបានបញ្ជូនទៅមជ្ឈិមបក្ស ។ នៅលើឯកសារមួយចំនួន ត្រូវបានចុះហត្ថលេខាដោយ រឿង ដែលលោក រស់ ស៊ុយ បានអះអាងថាជាមេរបស់ខ្លួន ។ នៅក្នុងឯកសារនោះ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការដឹកជញ្ជូនស្រូវគ្រប់ទីកន្លែងនៅទូទាំងប្រទេស ទៅកាន់ឃ្លាំងនៅទីក្រុងភ្នំពេញ ដើម្បីកិនវេចខ្ចប់រួចបញ្ជូនទៅកាន់កំពង់ផែសមុទ្រកំពង់សោម សម្រាប់ការនាំចេញទៅក្រៅប្រទេស ។ ដំណើរការទាំងអស់នោះ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ រឿង និងគណៈកម្មាធិការពាណិជ្ជកម្មរដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងមិនបានដឹងច្បាស់ពីចំនួនស្រូវដែលត្រូវបាននាំចេញពីប្រទេសកម្ពុជានៅក្រោមការគ្រប់គ្រងនៃរបបខ្មែរនោះទេ ។ ប៉ុន្តែ បើយោងតាមភស្តុតាងដែលមានដូចជាឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាដែលនៅសេសសល់ និងការផ្តល់សក្ខីកម្មរបស់សាក្សីបានបញ្ជាក់ឲ្យឃើញថា បក្សកុម្មុយនីស្តកម្ពុជា បាននាំស្រូវចេញយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្លួន បើទោះបីជាប្រជាជនកម្ពុជារាប់ពាន់នាក់ត្រូវស្លាប់ដោយការអត់ឃ្លានក៏ដោយ ។ លើសពីនេះទៅទៀតសក្ខីកម្មរបស់លោក រស់ ស៊ុយ បានបង្ហាញថា ខ្មែរក្រហមមានប្រព័ន្ធគ្រប់គ្រងថ្នាក់ជាតិរបស់ខ្លួន ដែលតម្រូវឲ្យបញ្ជូនស្រូវទៅកាន់ទីក្រុងភ្នំពេញ សម្រាប់ទុក និងរៀបចំនាំចេញទៅក្រៅប្រទេស ។ នៅពេលដែលមានបញ្ជាទិញស្រូវ ស្រូវទាំងនោះត្រូវបានដឹកជញ្ជូនទៅកាន់កំពង់សោមដើម្បីធ្វើការនាំចេញ ។ អតីតកម្មករធ្វើការនៅកំពង់ផែកំពង់សោម ក៏បានអះអាងដែរថា ខ្លួនបានលើដាក់ស្រូវយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅក្នុងកប៉ាល់ជាច្រើនដែលមើលទៅដូចកប៉ាល់របស់ចិន ។

## សេចក្តីបញ្ចប់

បើទោះបីជាការអត់ឃ្លានពុំត្រូវបានលើកយកមកពិភាក្សានៅក្នុងសំណុំរឿងថ្មីៗ ដែលបានធ្វើការចោទប្រកាន់ពីឧក្រិដ្ឋកម្មអន្តរជាតិក៏ដោយ យ៉ាងហោចណាស់ក៏តុលាការយោធាអន្តរជាតិបានយល់ថា ការចោទប្រកាន់ លោក ហាន់ ហ្វ្រែង ពីបទបង្កឲ្យមានការអត់ឃ្លាន និងលក្ខខណ្ឌរស់នៅមិនសមរម្យ ចំពោះប្រជាជនប៉ូឡូញ គឺជារឿងដែលត្រឹមត្រូវ ។ បើទោះបីជាការជំនុំជម្រះនេះបានធ្វើឡើងប៉ុន្មានទសវត្សរ៍មុនឆ្នាំ១៩៧៥ក៏ដោយ នៅក្នុងលក្ខខណ្ឌជាក់លាក់មួយចំនួន ការបង្កឲ្យមានការអត់ឃ្លានអាចចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិបាន ។ ជាក់ស្តែង ការប្រព្រឹត្តរបស់បក្សណាហ្ស៊ីអាល្លឺម៉ង់ ទៅលើប្រជាជនប៉ូឡូញ មានលក្ខណៈស្រដៀងគ្នាទៅនឹងការគ្រប់គ្រងរបស់ខ្មែរក្រហម ។

ជាមួយគ្នានេះដែរ សក្ខីកម្មនាពេលថ្មីៗនេះ នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានផ្តល់ព័ត៌មានបន្ថែមទៅលើបញ្ហានៃការផលិត និងការនាំស្រូវចេញពីប្រទេសកម្ពុជាក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ជាសរុប ប្រសិនបើសក្ខីកម្មរបស់លោក រស់ ស៊ុយ ជាការពិត នោះសបញ្ជាក់ឲ្យឃើញថា ខ្មែរក្រហមពិតជាបានរៀបចំប្រព័ន្ធមួយសម្រាប់ប្រមូលស្តុក ផលិត និងនាំស្រូវចេញទៅបរទេស ។

**រ៉ាន់ឌល ជីហ្វាល់ក្វ, រ៉ម៉ែន ពិចិត្រ**
**និង លន់ ដាលីន**

# អ្វីទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ?

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាបទល្មើសធ្ងន់ធ្ងរមួយក្នុងចំណោមបទល្មើសធ្ងន់ធ្ងរដទៃទៀតនៅក្នុងច្បាប់អន្តរជាតិ និងត្រូវបានផ្តល់និយមន័យផ្សេងៗគ្នា ដោយតុលាការអន្តរជាតិនានាទៅតាមបរិបទជាក់ស្តែងនៃរឿងក្តីដែលបានកើតឡើង ។

បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានឃើញកើតមាននៅក្នុងប្រទេសកម្ពុជាអំឡុងពេលនៃរបបខ្មែរក្រហមចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះលើបទឧក្រិដ្ឋកម្មនេះ គឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងឆ្នាំ២០០៣ ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាបទឧក្រិដ្ឋកម្មមួយដែលពុំមានអាជ្ញាយុកាល មានន័យថា ទោះបីជាបទឧក្រិដ្ឋកម្មនេះ ត្រូវបានប្រព្រឹត្តនៅក្នុងអតីតកាលអស់រយៈពេលយូរឆ្នាំហើយក៏ដោយ បុគ្គលជាអ្នកប្រព្រឹត្តនៅតែពុំអាចរួចផុតពីការចោទប្រកាន់ ។

យោងតាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្តែងឡើងតាមរយៈការប្រព្រឹត្តបទល្មើសមួយចំនួនដូចជា ៖

◆ ការធ្វើមនុស្សឃាត

◆ ការសម្លាប់រង្គាល

◆ ការធ្វើឲ្យទៅជាទាសករ

◆ ការនិរទេស

◆ ការដាក់ក្នុងមន្ទីរឃុំឃាំង

◆ ការធ្វើទារុណកម្ម

◆ ការរំលោភលើផ្លូវភេទ

◆ ការធ្វើទុកបុកម្នេញដោយហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា និង

◆ រួមទាំងអំពើអមនុស្សធម៌ផ្សេងទៀតដូចជា អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ និងការជម្លៀសប្រជាជនដោយបង្ខំ ។

ទោះបីជាយ៉ាងណា ដើម្បីចាត់ទុកជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាន បទល្មើសទាំងអស់ខាងលើចាំបាច់ត្រូវតែកើតឡើងនៅក្នុងក្របខណ្ឌនៃការវាយប្រហារ ហើយការវាយប្រហារនោះត្រូវតែធ្វើឡើងមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធសំដៅប្រឆាំងនឹងប្រជាជនស៊ីវិល ដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ។ ម្យ៉ាងវិញទៀត ដើម្បីចោទប្រកាន់បុគ្គលណាម្នាក់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាំបាច់ត្រូវតែបង្ហាញឲ្យឃើញថា ការវាយប្រហារដែលកើតឡើង ពិតជាមានជាប់ទាក់ទងនឹងអំពើរបស់ជនដែលត្រូវបានចោទប្រកាន់ ហើយជននោះ ចាំបាច់ត្រូវតែបានដឹងអំពីការវាយប្រហារ ។ ទាំងអស់នេះគឺជាធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

គួរកត់សម្គាល់ថា នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំបានដាក់លក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនឹងជម្លោះប្រដាប់អាវុធនោះទេ ។

### ធាតុផ្សំទូទៅដែលបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

**១) ការវាយប្រហារ**

ការវាយប្រហារគឺជាការប្រព្រឹត្តិនូវអំពើហិង្សាច្រើន ។ ជនជាប់ចោទមិនចាំបាច់ប្រព្រឹត្តអំពើហិង្សាទាំងអស់ ដែលបង្កើតបានជាការវាយប្រហារនោះទេ (អំពើរបស់ជនជាប់ចោទគ្រាន់តែជាផ្នែកនៃការវាយប្រហារទូទៅក៏បានដែរ) ។ នៅក្នុងការវាយប្រហារតែមួយអាចកើតមានអំពើហិង្សាច្រើន ឧទាហរណ៍ អំពើមនុស្សឃាត រំលោភលើផ្លូវភេទ និងទារុណកម្ម ។

ទោះបីជាសញ្ញាណនៃការវាយប្រហារ មានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធក៏ដោយ ការវាយប្រហារសំដៅប្រឆាំងនឹងប្រជាជនស៊ីវិលអាចកើតមានឡើងមុនអាចអូសបន្លាយ

ពេលយូរ ឬបន្តមានរហូតក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ។

## ២) លក្ខណៈទូទៅ ឬជាប្រព័ន្ធ

អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការវាយប្រហារត្រូវតែមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ។ ពាក្យ “លក្ខណៈជាទូទៅ” គឺសំដៅលើការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានចំនួនជនរងគ្រោះច្រើន ។ រីឯពាក្យថា “ជាប្រព័ន្ធ” គឺសំដៅទៅលើអំពើហិង្សាដែលមានការរៀបចំ ហើយអំពើនោះមិនអាចកើតមានដោយចៃដន្យនោះទេ ។ ការបែងចែកលក្ខណៈវិនិច្ឆ័យនៃការវាយប្រហារទាំងពីរទម្រង់ឲ្យដាច់ពីគ្នា គឺជាការលំបាកនៅក្នុងការអនុវត្តជាក់ស្តែង ។ ការវាយប្រហារលក្ខណៈទូទៅដែលកំណត់គោលដៅលើចំនួនជនរងគ្រោះច្រើន ជាទូទៅត្រូវផ្អែកលើទម្រង់មួយចំនួននៃការរៀបចំផែនការឬចាត់ចែង ។ ការវាយប្រហារលក្ខណៈជាទូទៅអាចសំដៅលើ “ទាំងអានុភាពត្រួតគ្នានៃអំពើអមនុស្សធម៌ជាច្រើន ទាំងអំពើអមនុស្សធម៌តែមួយដែលមានទ្រង់ទ្រាយធំ” ។

ដើម្បីកំណត់ថា ការវាយប្រហារដែលកើតឡើងមានលក្ខណៈទូទៅ ឬជាប្រព័ន្ធ ឬការវាយប្រហារនោះមានលក្ខណៈទាំងពីរ ចាំបាច់ត្រូវពិចារណាលើផលវិបាកដែលកើតចេញពីការវាយប្រហារលើប្រជាជនដែលបានកំណត់ថាជាគោលដៅ ជនរងគ្រោះដែលទទួលរងពីការវាយប្រហារនោះមានចំនួនច្រើន ចរិតលក្ខណៈនៃអំពើវាយប្រហារ លទ្ធភាពនៃការចូលរួមរបស់មន្ត្រី ឬអាជ្ញាធរ ឬគំរូនៃឧក្រិដ្ឋកម្មផ្សេងទៀតដែលអាចកត់សម្គាល់បាន ។

## ៣) សំដៅប្រឆាំងលើប្រជាជនស៊ីវិល

ការវាយប្រហារដែលបានរៀបរាប់ខាងលើ គឺត្រូវតែសំដៅប្រឆាំងលើប្រជាជនស៊ីវិល ។ ពាក្យថា “ប្រជាជន” មិនមែនមានន័យថា ទាល់តែមានប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រណាមួយ ដែលមានការវាយប្រហារទើបចាត់ទុកថាជាគោលដៅនៃការវាយប្រហារនោះទេ ។ គ្រាន់តែប្រជាជននៅក្នុងក្រុមមួយចំនួនល្មម ត្រូវបានគេកំណត់ថាជាគោលដៅនៃការវាយប្រហារ ឬគោលដៅនៃការវាយប្រហារនោះត្រូវបានបង្ហាញឲ្យឃើញថាធ្វើឡើងដើម្បីសំដៅប្រឆាំងលើប្រជាជនស៊ីវិលគឺមានលក្ខណៈគ្រប់គ្រាន់នឹងអាចចាត់ទុកថាជាការវាយប្រហារសំដៅប្រឆាំង



កុមារនិងយុវជនកំពុងដឹកជញ្ជូនបាយស្ទូកនិងគ្រាប់រំសេវដើម្បីយកទៅផ្គត់ផ្គង់សមរភូមិមុខរបស់យោធាខ្មែរក្រហម នៅជាយទីក្រុងភ្នំពេញ មុនឆ្នាំ១៩៧៥

ប្រជាជនស៊ីវិល ។ ប៉ុន្តែ ប្រសិនបើការវាយប្រហារនោះសំដៅប្រឆាំងលើតែបុគ្គលមួយចំនួនតូចដែលបានកំណត់ឬត្រូវបានជ្រើសរើសខ្លះៗនោះ គឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ ។ រីឯពាក្យថា "ជនស៊ីវិល" គឺជាជនដែលមិនមានឋានៈជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងអ្នកប្រយុទ្ធផ្សេងទៀត (កងជីវពល ទាហានស្ម័គ្រចិត្ត និងសមាជិករបស់ក្រុមចលនាតស៊ូដែលមានការចាត់តាំង) ។

ដូច្នេះពាក្យថា "ប្រជាជនស៊ីវិល" អាចកំណត់បានថា គឺជាជនដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬមិនមែនជាជនត្រូវទទួលស្គាល់ថាជាអ្នកប្រយុទ្ធ ។ បុគ្គលមួយរូបត្រូវបានចាត់ទុកថាជាជនស៊ីវិល ប្រសិនបើឋានៈរបស់បុគ្គលនោះមិនមានលក្ខណៈច្បាស់លាស់ ។

ចំពោះទាហាន ឬសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ដែលមិនបានចូលរួមនៅក្នុងការប្រយុទ្ធ ឬបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ មិនត្រូវបានចាត់ទុកថាជាជនស៊ីវិលឡើយ ។ ប៉ុន្តែ វត្តមានរបស់បុគ្គល មួយចំនួនដែលមិនស្ថិតនៅក្រោមនិយមន័យនៃជនស៊ីវិល ហើយបុគ្គលទាំងនោះស្ថិតនៅក្នុងចំណោមប្រជាជនស៊ីវិល មិនអាចដកហូតលក្ខណៈជាជនស៊ីវិលរបស់ប្រជាជនទាំងនោះបានទេ ។

ដើម្បីបង្ហាញឲ្យឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតឡើងនៅអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ចាំបាច់ត្រូវតែបញ្ជាក់ឲ្យច្បាស់ថា ប្រជាជនស៊ីវិលត្រូវបានកំណត់ជាគោលដៅចម្បងនៃការវាយប្រហារ ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវឲ្យភាគីនានានៃជម្លោះញែកឲ្យដាច់ពីគ្នាគ្រប់ពេលទាំងអស់រវាងប្រជាជនស៊ីវិល និងអ្នកប្រយុទ្ធ និងតម្រូវមិនឲ្យវាយប្រហារលើគោលដៅយោធា ប្រសិនបើការវាយប្រហារនោះ ទំនងជាបង្កឲ្យមានចំនួនអ្នកស្លាប់ ឬប៉ះពាល់ដល់ជនស៊ីវិលច្រើនលើសលុប គឺលើសពីផលប្រយោជន៍យោធាដែលគេអាចប៉ាន់ស្មានទុកមុន ។

តើត្រូវធ្វើដូចម្តេចដើម្បីកំណត់ថា ការវាយប្រហារមួយជាការវាយប្រហារមានគោលដៅឬគ្មានគោលដៅប្រឆាំងជនស៊ីវិល?

ដើម្បីកំណត់ថាការវាយប្រហារមួយមានគោលដៅប្រឆាំងនឹងជនស៊ីវិល ចាំបាច់ត្រូវពិនិត្យមើលលើកត្តាទាំងឡាយដែលពាក់ព័ន្ធរួមមាន៖

- ◆ មធ្យោបាយ និងវិធីសាស្រ្តដែលប្រើប្រាស់នៅក្នុងការវាយប្រហារ
- ◆ ឋានៈរបស់ជនរងគ្រោះ
- ◆ ចំនួនជនរងគ្រោះ
- ◆ លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងការវាយប្រហារ និងការបង្ក្រាបអ្នកតស៊ូ នាអំឡុងពេលនោះ និង
- ◆ ទំហំនៃកម្លាំងវាយប្រហារដែលអាចនិយាយបានថា បានគោរពតាម ឬមានចេតនាគោរពតាមលក្ខខណ្ឌប្រុងប្រយ័ត្នទាំងឡាយនៃច្បាប់សង្គ្រាម ។

នៅក្នុងករណីដែលការវាយប្រហារសំដៅត្រង់ៗលើប្រជាជនស៊ីវិលជាទូទៅ នៅពេលនោះ គឺពុំចាំបាច់បង្ហាញថា ជនរងគ្រោះទាំងនោះជាប់ទាក់ទងជាមួយក្រុមពិសេសណាមួយខាងនយោបាយ ជាតិពន្ធុ ឬផ្សេងឡើយ ។ មានន័យថា ឲ្យតែការវាយប្រហារនោះសំដៅយកប្រជាជនស៊ីវិលជាគោលដៅដើម្បីធ្វើការវាយប្រហារ ទោះបីជាអ្នកស្ថិតនៅក្នុងចំណោមក្រុមប្រជាជនស៊ីវិលនោះមានឋានៈបុគ្គលជាអ្វីក៏ដោយ អំពើនោះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចរួមបញ្ចូលទាំងការវាយប្រហាររបស់រដ្ឋមួយលើប្រជាជនរបស់រដ្ឋខ្លួនឯងដែរ ។

### ៤) មូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា

ដើម្បីកំណត់ថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាំបាច់ត្រូវមើលលើលក្ខខណ្ឌតម្រូវមួយទៀត គឺការវាយប្រហារនោះ ត្រូវតែជាការវាយប្រហារ ដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ។ ធាតុផ្សំនេះសំដៅទៅលើលក្ខណៈនៃការវាយប្រហារ ពុំមែនជាធាតុផ្សំនៃបទល្មើសណាមួយជាក់លាក់ឡើយ ។ ក្នុងការអនុវត្តការវាយប្រហារចាំបាច់ត្រូវតែមានចេតនារើសអើង ។

គួរគត់សម្គាល់ថា នៅត្រង់លក្ខខណ្ឌនៃការវាយប្រហារត្រូវតែធ្វើឡើងដោយសារមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា គឺមានលក្ខណៈផ្សេងគ្នាពីតុលាការអន្តរជាតិមួយទៅតុលាការអន្តរជាតិមួយទៀត ដូចជា អង្គជំនុំជម្រះវិសាមញ្ញ

ក្នុងតុលាការកម្ពុជា តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ជាដើម ។ ឧទាហរណ៍ នៅត្រង់មាត្រា៥ នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលគ្មានអាជ្ញាយុកាល គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុពូជសាសន៍ ឬសាសនាណាមួយ ។ អង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបកស្រាយមាត្រានេះថា ជាយុត្តាធិការបន្ថែម ដែលចែងទាក់ទងនឹងលក្ខណៈនៃការវាយប្រហារ មិនមែនទាក់ទងនឹងបទល្មើសជាក់លាក់ នោះទេ ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់បន្ថែមទៀតថា នៅក្រោមធម្មនុញ្ញណូរ៉េមប៊ឺក (Nuremberg) ធម្មនុញ្ញ តូក្យូ (Tokyo) និងច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង បានបញ្ជាក់ថា រាល់ធាតុផ្សំជាមូលដ្ឋាននៃការរើសអើង ត្រូវបានកំណត់ត្រឹមបទល្មើសដែល ជាការធ្វើទុក្ខបុកម្នេញ ក្នុងនោះធាតុចេតនានៃការរើសអើងតម្រូវឲ្យមានជាចាំបាច់ ។

រីឯយុត្តិសាស្ត្រនិងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ជាក់ច្បាស់ថា ផ្អែកតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ធាតុផ្សំចេតនានៃការរើសអើងមិនមែនជាធាតុផ្សំផ្លូវច្បាប់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លើកលែងតែការធ្វើទុក្ខបុកម្នេញ ដែលតម្រូវឲ្យមានធាតុចេតនានៃការរើសអើងនេះ ។

ដូច្នេះឃើញថា នៅក្នុងយុត្តិសាស្ត្រ និងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មានការកំណត់ផ្សេងគ្នាពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងធាតុផ្សំចេតនានៃការរើសអើង ។

### ៥) ទំនាក់ទំនងរវាងអំពើរបស់ជនជាប់ចោទនឹងការវាយប្រហារ

អំពើរបស់ជនជាប់ចោទ ត្រូវតែជាផ្នែកមួយនៃការវាយប្រហារជាសត្យានុម័ត ទោះជាអំពើនោះ ជាអំពើប្រភេទណាក៏ដោយ ឬមានផលវិបាកយ៉ាងណាក៏ដោយ ដរាបណាអំពើទាំងនោះមិនត្រូវបានកាត់ផ្តាច់ទាំងស្រុងចេញពីបរិបទនៃការវាយប្រហារ ។

ឧក្រិដ្ឋកម្មមួយដែលត្រូវបានប្រព្រឹត្តឡើងមុន ឬក្រោយការវាយប្រហារជាចម្បងប្រឆាំងលើប្រជាជនស៊ីវិល ក៏អាចចាត់ទុកថាជាផ្នែកមួយនៃការវាយប្រហារដែរ ប្រសិនបើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងការវាយប្រហារនោះ ។ ក៏ប៉ុន្តែ ប្រសិនបើឧក្រិដ្ឋកម្មមួយកើតឡើងនៅដាច់ឆ្ងាយពីកន្លែងដែលមានការវាយប្រហារ ហើយមិនមានហេតុផលសមស្របណាមួយអាចនិយាយបានថា ឧក្រិដ្ឋកម្មនោះជាផ្នែកមួយនៃការវាយប្រហារ នៅពេលនោះឧក្រិដ្ឋកម្មដែលកើតឡើងពុំអាចចាត់ទុកជាការវាយប្រហារបានទេ ។

### ៦) លក្ខខណ្ឌដឹង

ជនជាប់ចោទនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែបានដឹងថា មានការវាយប្រហារលើប្រជាជនស៊ីវិល ព្រមទាំងដឹងថាអំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនោះ ។ ជនជាប់ចោទត្រូវដឹងអំពីបរិបទទាំងមូលដែលអំពើនោះកើតឡើង ប៉ុន្តែមិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារ ឬរួមចំណែកដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារនោះទេ ។

តើធ្វើយ៉ាងណាដើម្បីបង្ហាញថា ជនជាប់ចោទបានដឹង ឬមិនបានដឹងអំពីឧក្រិដ្ឋកម្មដែលបានកើតឡើង?

ចម្លើយនៃសំណួរនេះ គឺថាគេមិនអាចកំណត់អំពីលក្ខខណ្ឌជាក់លាក់បានទេ ប៉ុន្តែភ័ស្តុតាងនៃការដឹង គឺអាស្រ័យលើអង្គហេតុនៃករណីជាក់លាក់នីមួយៗ ហើយការបង្ហាញធាតុផ្សំតាមផ្លូវច្បាប់ថាយ៉ាងណានោះ គឺអាស្រ័យតាមកាលៈទេសៈជាក់ស្តែងនីមួយៗ ។

សូមបញ្ជាក់ថា ប្រសិនបើអវត្តមានធាតុផ្សំណាមួយក្នុងចំណោមធាតុផ្សំទូទៅទាំងអស់ខាងលើ បទល្មើសទាំងឡាយដែលចែងនៅក្នុងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំទាន់អាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាននៅឡើយទេ ។ បទល្មើសដែលកើតឡើង អាចចាត់ទុកបានត្រឹមតែជាឧក្រិដ្ឋកម្មសង្គ្រាម ឬបទល្មើសព្រហ្មទណ្ឌដែលស្ថិតនៅក្រោមច្បាប់ជាតិតែប៉ុណ្ណោះ ។

### បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២

ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំ

ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរកឃើញថា ឌុច បានប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមមាន៖

◆ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែលរួមបញ្ចូលនូវបទល្មើសការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ។

◆ ការធ្វើឲ្យទៅជាទាសករ ។

◆ ការដាក់ក្នុងមន្ទីរឃុំឃាំង ។

◆ ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណី) និង

◆ អំពើអមនុស្សធម៌ផ្សេងៗទៀត ។

ក្រៅពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះសាលាដំបូងក៏បានផ្តន្ទាទោស ឌុច ពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ដែរ ហើយបានសម្រេចដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ។

ទោះបីជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចបដិសេធការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង នៅត្រង់ចំណុចស្រូបបញ្ចូលបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឌុច ជាអ្នកទទួលខុសត្រូវ ។ ប៉ុន្តែបានបន្ថែមទម្ងន់ទោសចំពោះ ឌុច ពីបទសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) បទធ្វើឲ្យទៅជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម និងអំពើអនុស្សធម៌ផ្សេងៗទៀត ។ ដោយសារការបន្ថែមទម្ងន់ទោស ឌុច ត្រូវអង្គជំនុំជម្រះតុលាការកំពូលសម្រេចដាក់ក្នុងពន្ធនាគារអស់មួយជីវិត ។

ចំពោះសំណុំរឿង០០២ នាពេលបច្ចុប្បន្ន មានតែជនជាប់ចោទ ខៀវ សំផន និង នួន ជា តែប៉ុណ្ណោះ ដែលកំពុងទទួលការជំនុំជម្រះនៅក្នុងសវនាការដំណាក់កាលដំបូង ដោយផ្តោតជាសំខាន់លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ផ្នែកដំបូងដែលអង្គជំនុំជម្រះលើកយកមកបើកសវនាការនេះ ត្រូវបានកំណត់ថាជាសំណុំរឿង ០០២វគ្គមួយ ។ អង្គហេតុពាក់ព័ន្ធ ដែលអង្គជំនុំជម្រះសាលាដំបូងលើកយកមកជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងសំណុំរឿង០០២វគ្គមួយនេះ រួមមាន ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃក្នុងខេត្តពោធិ៍សាត់បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាចភ្លាមៗក្នុងឆ្នាំ១៩៧៥ ។ បទល្មើសជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអង្គជំនុំជម្រះលើកយកមកពិចារណាក្នុងសវនាការសំណុំរឿង០០២វគ្គមួយមានដូចជា៖

១) ការធ្វើមនុស្សឃាត នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងការសម្លាប់អតីតទាហាន លន់ នល់ (នៅទួលពោធិ៍ជ្រៃភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច) ។

២) ការសម្លាប់រង្គាល (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច) ។

៣) ការធ្វើទុក្ខបុកម្នេញខាងនយោបាយ (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច) ។

៤) អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២) ។

៥) អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២) ។

៦) ការបាត់ខ្លួនដោយបង្ខំ (នៅអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២) ។

អង្គជំនុំជម្រះគ្រោងនឹងបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២វគ្គមួយ ដោយអនុញ្ញាតឲ្យភាគីធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់នៅក្នុងសវនាការចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ។ អង្គជំនុំជម្រះអាចនឹងចេញសាលក្រមសម្រេចសេចក្តីលើសំណុំរឿង០០២វគ្គមួយ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងឆមាសទី១ឆ្នាំ២០១៤ ។ **លីម ច័យច័ត្ត**

# សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលគឺជាអ្វី?

ក្រោយពីបញ្ចប់ដំណាក់កាលសួរដេញដោលនៅក្នុងសវនាការ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្ដីខ្មែរក្រហមលើសំណុំរឿង ០០២/០១ អស់រយៈពេល ២១២ ថ្ងៃរួចមក អង្គជំនុំជម្រះនេះបានប្រកាសអំពីសវនាការចុងក្រោយ គឺសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ។ តើអ្វីទៅគឺជាសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល?

សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលគឺជាដំណើរការនីតិវិធីជំនុំជម្រះមួយក្នុងចំណោមដំណើរការនីតិវិធីជាច្រើនទៀតដែលប្រព្រឹត្តឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (នេះនិយាយជាពិសេសសម្រាប់សាលាក្ដីកាត់ទោសមេដឹកនាំខ្មែរ) ។ យោងតាមវិធាន៩៤ នៃវិធានផ្ទៃក្នុងសម្រាប់សាលាក្ដីខាងលើ «ក្រោយពេលពិនិត្យលើភ័ស្តុតាងទាំងអស់រួចរាល់ហើយ ប្រធានអង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យជនដូចខាងក្រោមនេះ ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាបន្តបន្ទាប់គ្នា» ។ «ជនដូចខាងក្រោម» រួមមាន សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី, សហព្រះរាជអាជ្ញា ដើម្បីធ្វើការសន្និដ្ឋានប្ដឹងដោយផ្ទាល់មាត់ ដែលខ្លួនយល់ឃើញថា សមស្របនឹងប្រយោជន៍ល្អនៃយុត្តិធម៌, មេធាវីរបស់ជនជាប់ចោទ និងជនជាប់ចោទផ្ទាល់ ។ នៅក្នុងដំណើរការនីតិវិធីបែបនេះ «ប្រធានអង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យ...សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាអាចធ្វើសេចក្ដីសន្និដ្ឋានឆ្លើយតបវិញបាន» ។ លើសពីនេះទៀត «នៅគ្រប់ដំណាក់កាលទាំងអស់ ជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទត្រូវតែមានសិទ្ធិធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយជានិច្ច» ។

ដូចអ្វីដែលសេចក្ដីប្រកាសព័ត៌មានរបស់សាលាក្ដីខ្មែរក្រហមបានប្រកាសនៅត្រង់ថា សវនាការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល គឺតម្រូវឲ្យភាគីទាំងអស់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់របស់ខ្លួនតាមលំដាប់លំដោយ និងពេលវេលាដែលគិតទុក



នួន ជា (ឆ្វេង) និង ខៀវ សំផន នៅក្នុងបន្ទប់សវនាការក្នុងខែតុលា ឆ្នាំ២០១៣ ។ រូបថត អ.វ.ត.ក

មុនដូចជា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (មួយថ្ងៃ), សហព្រះរាជអាជ្ញា (បីថ្ងៃ), មេធាវីរបស់ នួន ជា (ពីរថ្ងៃ), មេធាវីរបស់ ខៀវ សំផន (ពីរថ្ងៃ) ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (មួយថ្ងៃ) និងសេចក្តីសន្និដ្ឋានបញ្ចប់ចុងក្រោយរបស់មេធាវីជនជាប់ចោទទាំងពីររូប (បួនម៉ោង) ។

បើយោងតាមវចនានុក្រមច្បាប់ *(Black's Law Dictionary, Seventh Edition, 1999)* ការធ្វើសេចក្តី សន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល "ត្រូវបានធ្វើឡើងដោយភាគី មុននឹងចៅក្រមធ្វើសម្រេចសេចក្តីលើសំណុំរឿង ដែលតាមរយៈការធ្វើសេចក្តីសន្និដ្ឋាននោះ ភាគីនឹងស្នើសុំចៅក្រមឲ្យពិចារណាលើភ័ស្តុតាង និងអនុវត្តច្បាប់ក្នុងគោលបំណងគាំទ្រភាគីរៀងៗខ្លួន" ។ មានន័យដោយសង្ខេបថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងស្នើសុំឲ្យចៅក្រមធ្វើការសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណងជំងឺចិត្ត និងប្រយោជន៍ផ្សេងៗទៀតដែលដើមបណ្តឹងរដ្ឋប្បវេណីសមនឹងទទួលបានតាមច្បាប់កំណត់ ។ រីឯភាគីសហព្រះរាជអាជ្ញាវិញ គឺប្រាកដជានឹងស្នើសុំឲ្យចៅក្រមផ្តន្ទាទោសជនជាប់ចោទតាមបទចោទដែលខ្លួនបានប្តឹង និងអនុវត្តច្បាប់ដោយផ្អែកលើភ័ស្តុតាង ។ ផ្ទុយទៅវិញ ភាគីមេធាវីជនជាប់ចោទ និងជនជាប់ចោទផ្ទាល់គឺប្រាកដជានឹងស្នើសុំឲ្យចៅក្រមលើកលែងការចោទប្រកាន់ ឬការបន្ធូរបន្ថយទោសទណ្ឌ ដោយផ្អែកលើកាលៈទេសៈសមហេតុផល ប្រសិនបើតុលាការរកឃើញថា ជនជាប់ចោទមានទោសមែននោះ ។

ដូច្នេះ សវនាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដែលនឹងប្រព្រឹត្តទៅនៅពេលខាងមុខ គឺមានលក្ខណៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនកម្ពុជា ដែលទន្ទឹងរង់ចាំទទួលយកយុត្តិធម៌ពីសាលាក្តីខ្មែរក្រហម ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានមានប្រសាសន៍នៅក្នុងអត្ថបទសារព័ត៌មានបាងកកប៉ុស្តិ៍ថា "ជនរងគ្រោះទាំងអស់សមនឹងទទួលបាននូវការផ្សះផ្សាក្នុងដួងចិត្តណាស់" ហើយជាមួយគ្នានេះដែរ "យើងមិនត្រូវបំភ្លេចអតីតកាលឡើយ" ។ **ទ៉ាន់ថាន់ ពៅដារ៉ា**



សិស្ស-និស្សិត និងប្រជាជនតម្រង់ជួររង់ចាំចូលរួមស្តាប់ការអានសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងខែតុលា

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ធសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# ជនសង្ស័យនៅក្នុងសំណុំរឿង០០៤ មិនត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលចេញសេចក្តីសម្រេចតែម្នាក់ឯង បានច្រានចោលសិទ្ធិរបស់ជនសង្ស័យក្នុងសំណុំរឿង០០៣ និង ០០៤ ក្នុងការចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចដំណើរការស៊ើបសួរជាលើកចុងក្រោយ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សំណុំរឿង ០០៣ និង ០០៤ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការស៊ើបសួរចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៩ រហូតមានការតែងតាំងចៅក្រមអន្តរជាតិ ៤រូបផ្សេងគ្នា និងមានការលាតត្រដាងជាបន្តបន្ទាប់នូវការរារាំងផ្នែករដ្ឋបាល និងតុលាការចំពោះដំណើរការរបស់ខ្លួន ។ ទោះបីគ្មានជនសង្ស័យណាម្នាក់ត្រូវបានបញ្ជាក់ឈ្មោះ ឬចោទប្រកាន់ជាផ្លូវការនៅក្នុងសំណុំរឿងទាំងពីរនេះ ឈ្មោះជនសង្ស័យដែលមានវ័យចំណាស់ចំនួន ៥រូប (ជនសង្ស័យម្នាក់ក្នុងចំណោមអ្នកទាំង ៥នាក់នោះ បានទទួលមរណភាពនៅខែមិថុនា ឆ្នាំ២០១៣) និងលក្ខណៈទូទៅនៃបទចោទប្រកាន់ ត្រូវបានគេដឹងជាសាធារណៈចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០១១ មក ហើយជនសង្ស័យទាំងនោះត្រូវបានអ្នកសារព័ត៌មានជាតិ និងអន្តរជាតិស្វែងរក និងសម្ភាសន៍ម្តង ហើយម្តងទៀត ។

នៅដើមឆ្នាំ២០១០ អង្គភាពគាំពារការការពារក្តីរបស់អង្គ



ប្រជាពលរដ្ឋដើរចេញពីបន្ទប់សវនាការ ក្រោយពីបានស្តាប់ការអានសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោល នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ជំនុំជម្រះវិសាមញ្ញ បានព្យាយាមស្នើសុំជាច្រើនដងក្នុងការផ្តល់អ្នកតំណាងផ្លូវច្បាប់ជូនជនសង្ស័យទាំងនោះ រួមបញ្ចូលទាំងការពិនិត្យមើលសំណុំរឿង ដោយអះអាងថា «ការបន្តដំណើរការនីតិវិធីទាំងនោះ ដោយពុំមានការចូលរួមពីមេធាវីការពារក្តី នឹងរំលោភបំពានលើផ្នែកជាច្រើននៃសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយតតាំងក្តី សិទ្ធិទទួលបានការតំណាងប្រកបដោយប្រសិទ្ធភាព និងសិទ្ធិទទួលបានការគោរពគោលការណ៍ចំពោះមុខ» ។ ទាំងសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ បានច្រានចោលសំណើទាំងនោះ ដោយចេញសេចក្តីសម្រេចថា សិទ្ធិទាំងឡាយដែលអង្គភាពគាំពារការការពារក្តីរៀបរាប់នោះ គឺផ្តល់ជូនសម្រាប់តែជនសង្ស័យណាម្នាក់ដែលត្រូវបាននាំមកនៅចំពោះមុខចៅក្រម ឬត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រម ម៉ាក ហាម៉ុន ដែលកំពុងតែកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់នាពេលថ្មីៗនេះថា ដោយសារតែបុព្វាធិការី (អ្នកបម្រើការមុន) របស់គាត់ គឺលោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង កាស្ពើ អានសឺម៉េត បានជូនដំណឹងដល់ជនសង្ស័យក្នុងសំណុំរឿង០០៤ អំពីឋានៈជា «ជនសង្ស័យ» និងប្រាប់ជនសង្ស័យនោះ ថាមានសិទ្ធិទទួលបានមេធាវីការពារក្តី ដូច្នេះជនសង្ស័យនោះត្រូវបានផ្តល់សិទ្ធិទទួលបានមេធាវីការពារក្តីធ្វើជាតំណាង ដូចមានចែងក្នុងវិធាន ២១(១)(យ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ និងទទួលបានមេធាវីដែលបង់កម្រៃសេវាដោយតុលាការ ។ ដូច្នេះ ចៅក្រម ហាម៉ុន ទទួលស្គាល់ជាផ្លូវការនូវឋានៈជាសហមេធាវីការពារក្តីជាតិ និងអន្តរជាតិរបស់ជនសង្ស័យ ។ ទោះបីជាយ៉ាងណា ចៅក្រម ហាម៉ុន មិនអនុញ្ញាតឲ្យសហមេធាវីរបស់ជនសង្ស័យនោះ ពិនិត្យមើលសំណុំរឿងឡើយ ។ ដោយកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហាម៉ុន ធ្លាប់បានអនុញ្ញាតឲ្យមេធាវី ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង០០៤ ចូលពិនិត្យសំណុំរឿង មេធាវីរបស់ជនសង្ស័យអះអាងថា ខ្លួនត្រូវតែបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿងដែរ ដើម្បីធានានូវសមភាពនៃមធ្យោបាយតតាំងក្តីរវាងភាគីទាំងពីរ ។ បន្ថែមលើនេះទៀត មេធាវីជនសង្ស័យកត់សម្គាល់ថា ថ្វីត្បិតការស៊ើបអង្កេតនៅតែបន្តធ្វើជាសម្ងាត់ ប៉ុន្តែឈ្មោះរបស់ជនសង្ស័យ និងបទចោទប្រកាន់ដោយ សហព្រះរាជអាជ្ញាប្រឆាំងនឹងជនសង្ស័យ ត្រូវបានពិភាក្សានៅក្នុងប្រព័ន្ធផ្សព្ផ្សាយព័ត៌មាន ។ ក្រុមមេធាវីជនសង្ស័យចង់ដឹងបទចោទប្រកាន់ជាក់លាក់ ដើម្បីអាចការពារសិទ្ធិកូនក្តីរបស់ខ្លួនបាន ។ ក្រុមមេធាវីការពារក្តីស្នើសុំបន្ថែមទៀតនូវសិទ្ធិតតាំងជាមួយសាក្សីទាំងអស់ដែលបានសម្ភាសន៍ដោយសហចៅក្រមស៊ើបអង្កេត និង សិទ្ធិដែលត្រូវបានអនុញ្ញាតឲ្យចោទសំណួរទៅសាក្សីទាំងនោះតាមរយៈសហចៅក្រមស៊ើបអង្កេត ។

នៅក្នុងសេចក្តីសម្រេចដែលធ្វើនៅខែ កក្កដា បានចេញផ្សាយជាសាធារណៈនៅសប្តាហ៍មុននេះ ចៅក្រម ហាម៉ុន បានឆ្លើយតបថា គឺពុំដូចជាការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ដោយបញ្ជាក់ថា «វិធានផ្ទៃក្នុងបែងចែកយ៉ាងច្បាស់រវាងជនសង្ស័យ និងជនត្រូវចោទ ហើយផ្តល់សិទ្ធិជូនជនត្រូវចោទ កាន់តែទូលំទូលាយ» ។ ចៅក្រម ហាម៉ុន រកឃើញថា វិធានផ្ទៃក្នុងរក្សាទុកសិទ្ធិចូលពិនិត្យមើលសំណុំរឿងសម្រាប់ភាគីនៅក្នុងដំណើរការនីតិវិធី ដែលជនសង្ស័យពុំត្រូវបានរាប់បញ្ចូលជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ ។ ដូចគ្នានេះដែរ នៅក្រោមវិធានផ្ទៃក្នុងមានតែភាគីតែប៉ុណ្ណោះដែលអាចចូលរួមកិច្ចដំណើរការស៊ើបសួរ ។ ការដែលចៅក្រម ហាម៉ុន រកឃើញដូច្នេះ គឺបានផ្តល់ដោយយុត្តិសាស្ត្រអន្តរជាតិ ដែល «បញ្ជាក់ថា លក្ខណៈជាសារវ័ន្តនៃសិទ្ធិពិនិត្យមើលសំណុំរឿងត្រូវបានទទួលស្គាល់ចំពោះជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់» ។

នៅក្រោមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ «សហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាច សម្រេចចោទប្រកាន់ចំពោះជនសង្ស័យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬជនផ្សេងៗទៀតដែលមានភស្តុតាងច្បាស់លាស់ និងអាចជឿជាក់បាន» ។ យោងទៅលើការលើកឡើងរបស់សហចៅក្រមស៊ើបអង្កេតដំណើរការនៃការចោទប្រកាន់ គឺរួមបញ្ចូលទាំងការវាយតម្លៃអំពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម អង្គហេតុនៃអំពើឧក្រិដ្ឋដែលជូនដំណឹងដល់ជនសង្ស័យ និងការកំណត់បទល្មើសនៃអំពើឧក្រិដ្ឋដែលដាក់ឲ្យស្ថិតនៅក្រោមការស៊ើប

សួរ ។ សម្រាប់ហេតុផលនេះ ត្រឹមតែអង្គហេតុ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ជូនដំណឹងដល់ជនសង្ស័យអំពីបទចោទប្រកាន់របស់សហព្រះរាជអាជ្ញា គឺពុំធ្វើឲ្យជនសង្ស័យនោះក្លាយជា "ជនត្រូវចោទ" ឬ ផ្តល់សិទ្ធិឲ្យជន នោះចូលពិនិត្យមើលសំណុំរឿងឡើយ ។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានផ្តល់យ៉ាងជាក់លាក់ឲ្យជនសង្ស័យនោះមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង "នេះជាការរំលោភលើវិធានផ្ទៃក្នុង" ព្រោះថា ជនសង្ស័យនោះពុំទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការហើយ "បង្កើតឲ្យមានការរំលោភបំពានលើឆន្ទានុសិទ្ធិតុលាការ" ពីព្រោះការសម្រេចនេះធ្វើឡើងដោយគ្មានសំអាងហេតុគាំទ្រ ។ អស់រយៈពេលមួយឆ្នាំនៅក្នុងកិច្ចការស៊ើបអង្កេតរបស់ខ្លួន ចៅក្រម ហាម៉ុន "ពុំទាន់បានកំណត់នូវឡើយថា "ភ័ស្តុតាងច្បាស់លាស់ និងអាចជឿជាក់បាន" នេះ ត្រឹមកម្រិតណាអាចទទួលយកបាន" ។ ហេតុដូច្នេះចៅក្រម ហាម៉ុន ធ្វើមោឃភាពសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ត្រង់ចំណុចដែលអនុញ្ញាតឲ្យជនសង្ស័យមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ។

បន្ទាប់មកចៅក្រម ហាម៉ុន បានពិចារណា ថាតើមានកត្តាផ្សេងៗទៀតដែលអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង និងថាតើជនសង្ស័យត្រូវបាន "ប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" ដោយសារការស៊ើបអង្កេតដែរ ឬអត់ ។ ចៅក្រម ហាម៉ុន បានកត់សម្គាល់ថាតាមយុត្តិសាស្រ្តរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងសាលាក្តីពិសេសសម្រាប់លីបង់ ចង្អុលបង្ហាញថា នៅពេលជនណាម្នាក់ត្រូវបានឃុំខ្លួន "ទោះបីគ្មានការចោទប្រកាន់ជាផ្លូវការក៏ដោយ" ជននោះគួរត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង ដើម្បីតតាំងអំពីភាពស្របច្បាប់ចំពោះការឃុំខ្លួន និងបានកំណត់ថា ការដែលគ្រាន់តែទទួលបានការជូនដំណឹងថាជននោះកំពុងដាក់ឲ្យស្ថិតនៅក្រោមការស៊ើបអង្កេតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ គឺមិនមែនជាលក្ខខណ្ឌដែលអាចធ្វើការប្រៀបធៀបបានឡើយ ។

ការដោះស្រាយសម្រាប់ផលប៉ះពាល់ជាលើកដំបូងដោយសារការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ ដែលឈានទៅដល់ការបង្ហាញជនសង្ស័យ និងបទចោទប្រកាន់មុនពេលជនសង្ស័យនោះទទួល បានការជូនដំណឹងអំពីសិទ្ធិមានមេធាវីការពារក្តី និងសិទ្ធិនៅស្ងៀមមិនឆ្លើយតប ចៅក្រម ហាម៉ុន រកឃើញថា "ការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ គឺមិនមែនជាកត្តា" និងមិន "មានទម្ងន់ ឬតម្រូវឲ្យ មានដំណោះស្រាយដូចគ្នា" ទៅនឹងជនណាម្នាក់ដែលត្រូវបានឃុំខ្លួនឡើយ ។ ចៅក្រម ហាម៉ុន សម្រេចថាការតំណាងដោយមេធាវីការពារក្តីសម្រាប់ជនសង្ស័យនៅក្នុងសំណុំរឿង០០៤នាពេលបច្ចុប្បន្ន ការជូន ដំណឹងជនសង្ស័យអំពីបទចោទប្រកាន់ និងប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺ "បានធានាគ្រប់គ្រាន់ សម្រាប់សិទ្ធិរបស់ជនសង្ស័យ និងគោរពតាមបទដ្ឋានយុត្តិធម៌អន្តរជាតិបានយ៉ាងពេញលេញ" ។ដូច្នេះ ចៅក្រម ហាម៉ុន រកឃើញថា ពុំមានយុត្តិកម្មដើម្បីងាកចេញពីលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុងឡើយ ។

**អាន ហាញឌុល**

គម្រោងឃ្លាំមើល
តុលាការខ្មែរក្រហម
CAMBODIA TRIBUNAL MONITOR

តាមដានដំណើរកាត់ទោស ករណី០០២ រៀងរាល់ថ្ងៃ
ចាប់ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ តទៅ

សូមចុច www.cambodiatribunal.org

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm .ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។



# ទណ្ឌិត ផ្លែល្ពៅ

រូបគំនូរដោយអ្នកនិពន្ធ ឆាយ ស៊ូឆាត្រ

**(តពីលេខមុន)**

**៣២) សេ.អ៊ី.អា ប្ក កា.ហេ្យ.បេ**

មេកងដែលមកជំនួស មិត្ត ឌី ជាមិត្តនារីដែលមានឈ្មោះថា មិត្ត គៀន ។ គាត់មានសប្បុរខ្មៅដូចក្អែក រាងទាបកន្ទាល់ ភ្នែកស្រឡៅ និយាយព្ញៗ ជាអ្នកស្រុកតាកែវ ទិសនិរតី នៃប្រទេស ។ មិត្ត គៀន ជាមនុស្សច្បាស់លាស់ ជាកម្មាភិបាលដែលដោគជាំទៅដោយទ្រឹស្ដី បដិវត្តន៍ សំនួនវោហារ ដូចជាសាស្ត្រាចារ្យនៃមហាវិទ្យាល័យ តែគាត់ពុំចេះអក្សរទេ ។ គៀន គឺជាគណៈវរៈ ប្ករសេនា នៃកងចល័តយើង ។ មិត្ត គៀន ត្រួតពិនិត្យលើកម្លាំងទាំងបីរយដែលបែកជាប្រាំមួយកងតូច ដែលក្នុងមួយកងតូចប្កហៅថាក្រុម ។ មេក្រុមមានប្រុសស្រីសុទ្ធសឹងជាអ្នកមូលដ្ឋានចាស់ដែលជាអតីតអ្នកប្រយុទ្ធលើសមរភូមិមុខនៃរណសិរ្សរំដោះជាតិកម្ពុជាដែលដឹកនាំដោយសម្ដេចឪ ។ ចំពោះមិត្ត គៀន បញ្ជាត្រូវអនុវត្តឲ្យបាន យើងគឺជាយុទ្ធជននៅសមរភូមិមុខ គឺជាអ្នកប្រយុទ្ធដែលមិនរាថយ ។ ក្រោមបញ្ជារបស់ មិត្ត គៀន អ្នកដែលមិនទៅធ្វើការនឹងមិនត្រូវផ្ដល់របបអាហារទេ ។ កម្លាំងប្រយុទ្ធត្រូវបែងចែកមួយកងមានក្រុម ហើយ

មួយក្រុមមានដប់គូប ។ ក្នុងមួយគូបមានកម្លាំង៥-៦នាក់ ត្រូវកាប់ និងជញ្ជូនដីឲ្យបានដប់ប្រាំម៉ែត្រគូបក្នុងមួយថ្ងៃ ។ ទោះបីជាថ្ងៃក្ដៅឬមេឃភ្លៀងយ៉ាងណាក៏ដោយ ក៏ពុំត្រូវឈរឡើយ ។ ផែនការនេះពុំអាចសម្រេចបានទេ តែសំណាង មេកង មេក្រុមដែលពុំចេះអក្សរ យើងអាចវាស់បន្លំបានព្រោះយើងយកបណ្ដោយបូក និងទទឹងកម្ពស់បូកកម្ពស់ ពេលខ្លះហួសផែនការទៀតផង ។ ក៏ប៉ុន្តែ តាមការពិត របៀបនៃគណនានេះពុំត្រូវតាមក្បួនគណិតសាស្ត្រទេ ពិតមែនហើយ គៀន ពុំចេះអក្សរទេ ក៏ប៉ុន្តែទ្រឹស្តីរបស់គាត់ខ្លាំងជាងសាស្ត្រាចារ្យមហាវិទ្យាល័យទៅទៀត គាត់និយាយហូរដូចទឹកអំពីទ្រឹស្តីម៉ាក្សលេនីនពីវណ្ណៈអធនកសិករ កម្មករ ពីកំហឹងវណ្ណៈ ហើយគាត់និយាយដដែលៗរាប់ពាន់ដងពីកង់ប្រវត្តិសាស្ត្រ ហើយនឹងស្មារតីឯករាជ្យម្ចាស់ការ ។ រគាំងបន្លឺនៅម៉ោងបួនភ្លឺ ដូច្នេះម៉ោងបួនកន្លះត្រូវភ្ញាក់ពីដំណេកលុបមុខស្លៀកពាក់ឲ្យហើយស្រេចម៉ោងប្រាំចេញដំណើរ ។

អ្នកដែលភ្ញាក់ពុំទាន់នឹងត្រូវចាក់ទឹកពីលើ ឬដុតកែងជើងនឹងរងើកភ្លើង ។ មិត្ត គៀន និយាយញឹកញាប់អំពីមិត្ត ឌី ។ គាត់បានបញ្ជាក់ថា មិត្ត ឌី គឺជាជនក្បត់ ឬជាគិញដែលធ្វើឲ្យស្ទុះចលនាបដិវត្តន៍ជាខ្លាំងស៊ីរូងផ្ទៃក្នុង ជាពួកប្រតិកិរិយា ។ តើមិត្តទាំងអស់ដឹងទេ អាឌី! ជាជនក្បត់ វាជាបញ្ញវន្ត វណ្ណៈសក្តិភូមិ វាចេះនិយាយភាសាបារាំង ដូច្នេះហើយបានជាវាធ្វើជាគិញរបស់សេ.អ៊ី.អា និងកា.ហ្សេ.បេ ។ តាមការពិត មិត្ត គៀន ខ្លួនឯងមិនទាំងយល់ថា សេ.អ៊ី.អា និងកា.ហ្សេ.បេ នោះជាអ៊ីផងទេ ។ ដូច្នេះហើយ នយោបាយរបស់អង្គការគឺត្រូវកម្ទេចឲ្យអស់ជាដាច់ដោះលែងដោយភ័ន្តច្រឡំ ។ ជនណាដែលធ្វើឲ្យបាក់នង្គ័លឬដងចបនឹងត្រូវចាត់ទុកជាខ្មាំងហើយ ។ មេក្រូនៅតែចាក់ចម្រៀងបដិវត្តន៍ រីឯយើងកាន់តែស្គមទៅៗ របបអាហារកាន់តែខ្សត់ទៅ បបរកាន់តែរាវ ហើយការងារកាន់តែធ្ងន់ធ្ងរឡើង ។ យើងម្នាក់ៗចុះស្គមមើលទៅរូបរាងដូចនរកនៅក្នុងព្រះបត់តាមជញ្ជាំងព្រះវិហារ ។ ពេលខ្លះដើរដួលដូចមនុស្សចាស់ជរា ។ ពេលនេះជាចុងខែ សីហា ឆ្នាំ១៩៧៥ អ្នកគ្រប់គ្នាហូបអ៊ីៗគ្រប់មុខដែលរកបានដូចជា បន្លែ ថ្លែន ក្អែប កូនក្អាត់ ព្រមទាំងខ្យងហៀន ។ យើងបេះត្រួយរងៀងដើម្បីយកមកលាយបបរ ។ ក្នុងមួយថ្ងៃយើងឃើញតែមនុស្សស្លាប់ត្រូវសែងទៅកប់នៅជាយព្រៃក្បែរនោះដោយគ្មានពិធីបុណ្យអ៊ីទេគឺកប់ដូចខ្មោចឆ្កែអ៊ីចឹង ។ អតីតមិត្តរួមថ្នាក់របស់ខ្ញុំឈ្មោះ ជា ប៊ុនប៉ា កើតជំងឺរាគមួលឈាមបានដេកស្លាប់នៅការដ្ឋានដោយក្បាលផ្អែកនឹងបង្គី មេក្រុមបានយករំពាត់ទៅគោះដោយមិនដឹងថា ប៊ុនប៉ា ស្លាប់តាំងពីពេលណានោះទេ ។

## ៣៣) ក្រហមដល់ខួរឆ្អឹង

វិន័យអង្គការត្រូវបានអនុវត្តយ៉ាងតឹងតែងខ្លាំងណាស់ ។ តាមបញ្ជារបស់អង្គការមានបទល្មើសប្រាំយ៉ាងដែលត្រូវបានហាមៈ

- ហាមលួច
- ហាមជជែកតវ៉ា
- ហាមរម្លឹករឿងអតីតកាលនិងភាពសប្បុរសប្បាយ
- ហាមត្អូញត្អែរថាហត់នឿយ
- ហាមនិយាយដើមកម្មាភិបាល

យើងត្រូវនិយាយតែអំពីការប្រយុទ្ធ ការសម្រុកការងារយ៉ាងសស្រោកសស្រាំ ហើយត្រូវញញឹមជានិច្ច ពេញចិត្តនឹងភារកិច្ចដែលអង្គការប្រគល់ឲ្យត្រូវជឿលើអង្គការលើការដឹកនាំមហាភ្លីស្វាង មហាលោតផ្លោះ មហាអស្ចារ្យ ត្រូវជឿលើការប្រយុទ្ធដើម្បីបុព្វហេតុវណ្ណៈស្មើភាព ។ គ្រប់ទាំងបទខុសឆ្គងនាមរបស់មិត្ត គៀន តែងតែសង្កត់ធ្ងន់លើកំហឹងវណ្ណៈមូលធននិយមសក្តិភូមិ និងចក្រពត្តិនិយម និងការជ្រោងទង់បដិវត្តន៍ ។

មិត្ត គៀន កើតក្នុងត្រកូលកសិករក្រ ។ ឪពុករបស់គាត់បានចូលមកធ្វើការជាកម្មករលើសែង ។ ថ្ងៃមួយគាត់មានជម្លោះជាមួយថៅកែ ទីបំផុតគាត់ក៏បានសម្លាប់ថៅកែនោះ ។ ឪពុករបស់ គៀន ត្រូវតុលាការកាត់ទោសឲ្យជាប់គុក២៥ឆ្នាំ ។ កាលនោះ គៀន នៅជាកុមារនៅឡើយដោយបងប្អូនច្រើនគ្មានស្រែចម្ការសម្រាប់ដាំដុះដំណាំ ជីវភាពក្រីក្រ ។ បងប្អូនប្រុសៗត្រូវស៊ីឈ្នួលមើលគោ ក្របីឲ្យគេ រីឯបងស្រីពីរនាក់ទៅស៊ីឈ្នួលគេនៅទីក្រុង ជាស្រីបម្រើក្នុងផ្ទះក៏ត្រូវថៅកែប្រុសចាប់រំលោភរហូតដល់មានផ្ទៃពោះ ។ ក្នុងមួយជីវិតរបស់ គៀន ស្គាល់តែការឈឺចាប់និងកំហឹងវណ្ណៈ ។

ថ្ងៃ១៨ មីនា ១៩៧០ ក្រោយរដ្ឋប្រហាររបស់លន់ លន់ ពួកយៀកកុងបានចូលមកដល់ភូមិស្រុក ទ្រឹស្តីកំហឹងវណ្ណៈបានដុតបញ្ឆេះឆន្ទៈរបស់ គៀន ឲ្យឆេះឡើងគឺត្រូវចំចំណុចរបស់ គៀន ចំបានពេលនោះ គៀន ក៏បានចូលរួមក្នុងចលនាបដិវត្តន៍ប្រជាជាតិ

ប្រជាធិបតេយ្យដើម្បីផ្តួលរំលំរបប លន់ នល់ គៀន ពុំបានចាប់អារម្មណ៍នឹងសម្តេចសីហនុ ព្រោះគាត់យល់ថា វណ្ណៈស្តេចក៏ជាវណ្ណៈជិះជាន់មួយដែរ ។ ក្នុងសម័យតស៊ូ គៀន គឺជាសកម្មជនដែលទទួលកិត្តិយសពីអង្គការបដិវត្តន៍ ឬជាជនបដិវត្តន៍ដែលមានជំហរខ្ពស់ដាច់ខាត ។

សម្រាប់មិត្ត គៀន អ្នកដែលរស់ក្នុងរបប លន់នល់ ព្រមទាំងអ្នកមានទាំងអស់សុទ្ធតែប្រតិកិរិយាប្រឆាំងបដិវត្តន៍ទាំងអស់ ។ គៀន និយាយថា ជនដែលរស់នៅក្នុងរបប លន់ នល់ និងពួកកាកសំណល់ពីសង្គមចាស់ប្រៀបដូចជាដើមឈើដែលពុកនិងដង្កូវស៊ីត្រូវតែកាប់ចោលហើយដាំថ្មីដែលត្រង់ល្អ និងរត់ត្រង់ផ្លូវ ។ គៀន ពុំដែលមានមនោសញ្ចេតនាអាណិតអាសូរទេ សម្រាប់ គៀន ច្បាប់គឺច្បាប់ គ្មានការលើកលែងឬយោគយល់ទេ ហើយគាត់មិនអត់ឱនសូម្បីតែពងមាន់មួយក៏ដោយ ។ ជាក់ស្តែង ថ្ងៃមួយយុវជនម្នាក់ឈ្មោះ ចេង ដែលដេកឈឺនៅកន្លែងពុំបានទៅធ្វើការ ។ នៅពេលដែលអ្នកដទៃទៅធ្វើការអស់ ចេង បានដើរទៅរោងបាយ រួចលួចបានពងមាន់មួយ ។ អ្នកចុងភៅបានឃើញហើយចាប់ ចេង នៅនឹងកន្លែង ។ គៀន យកជើងធាក់ក្បាល ហើយយករំពាត់វាយយ៉ាងខ្លាំងរហូតបាក់អស់ពីរបីដើម ដោយជេរថា អាក្បត់! អាខ្មាំង! អាឈ្លើងជញ្ជក់ឈាម! ។ ចេង បែកឈាមពេញផ្ទៃមុខខ្លួន និងក្បាល ។ ចេង ដួលផ្កាប់មុខកម្រើកលែងរួច ។ គៀន បញ្ជាឲ្យឈ្លបពីរនាក់យក ចេង ទៅចងជាប់នឹងគល់ឈើមួយដោយសម្រាតខោអាវអស់ទុកតែខោខ្លីហើយបញ្ជាឲ្យរកអង្ក្រងមកចាក់ពីលើខ្លួនឲ្យខាំ ។ ចេង ត្រូវចងហាលថ្ងៃ ហាលភ្លៀង អត់បាយ អត់ទឹក ។ បីថ្ងៃក្រោយមក ចេង ក៏ដាច់ខ្យល់ស្លាប់ ។ សពរបស់ ចេង កប់នៅក្បែរនោះដោយមានសរសេរស្លាកបិទនៅគល់ឈើថា ខ្មាំងរបស់បដិវត្តន៍កម្ទេចនៅថ្ងៃទី១ ខែ..ឆ្នាំ...(មិនចាំ) ។ ក្នុងអង្គប្រជុំពីរថ្ងៃក្រោយមក គៀន បានបញ្ជាក់ដោយសំឡេងយ៉ាងម៉ឺងម៉ាត់ថា «បើនរណាថា ខ្ញុំជាខ្មែរក្រហមនោះ ជាការពិតហើយ ខ្ញុំមិនត្រឹមក្រហមតែបេះដូង និងឈាមនោះទេ ខ្ញុំក្រហមដល់ខួរឆ្អឹងតែម្តង» ។

## ជំពូកទី៥

### ៣៨) នរកបដិវត្តន៍

ឈានដល់ចុងខែសីហា ឆ្នាំ១៩៧៥ ភ្លៀងធ្លាក់កាន់តែខ្លាំង ហើយជំងឺចាញ់កាន់តែសាហាវដែរ ។ ក្នុងកងវរសេនារបស់យើងមានយុវជន យុវនារី ប្រហែលជាចិតសិបនាក់ ដែលស្លាប់ហើយ ប្រហែលកៅសិបនាក់ទៀតបានក្លាយជាមនុស្សបាក់កម្លាំង ធ្វើការពុំបាន សូម្បីតែកងវរសេនាដទៃទៀតក៏មានស្ថានភាពដូចគ្នា ចំណែកដីក៏លំបាកក្នុងការជញ្ជូនទៅលើខ្នងទំនប់ដែរ ។ មិត្ត គៀន នៅមិនសុខព្រោះពុំបានបំពេញភារកិច្ចជូនអង្គការថ្នាក់លើ ។ ដោយសារមានមនុស្សស្លាប់និងឈឺច្រើននាក់ ដូច្នេះចំនួនបង្គីរបស់ខ្ញុំចាល់ ចំណែកខ្ញុំក៏មានសុខភាពល្អធម្មតា ព្រោះចំណីអាហារដែលរកបាននៅក្នុងព្រៃ ។ នឹកដល់ត្រឹមនោះ ខ្ញុំចងចាំមិនភ្លេចគុណរបស់មិត្ត ឌី ដែលបានបន្សល់ទុកជំនាញនេះដែលរក្សាជីវិត ។

ទំនប់ទឹកកសាងបានមិនដល់ពាក់កណ្តាលទេ ចំណែកក្រុមយុវជនយុវនារីក៏ចុះស្គម ទុរន់ទុរា មើលមិនស្គាល់ ។ មានអ្នកខ្លះលើតែចបមួយក៏ពុំរួចផង ដើរដួលដូចមនុស្សអាយុកៅសិបឆ្នាំ ។ ក្នុងចំណោមអ្នកដែលស្លាប់ទៅហើយនោះ អង្គការពុំដែលបានកត់ឈ្មោះ ឬមានឯកសារថាអ្នកទាំងនោះមកពីណា ត្រកូលអ្វីនោះទេ គឺស្លាប់ដូចខ្មោចឆ្កែ ឪពុកម្តាយបងប្អូននៅឯផ្ទះក៏ពុំដែលទទួលដំណឹងអ្វីសោះ ។ សពត្រូវរំដោយកន្ទេលនិងខោអាវដឹកគ្រេច កប់ចោលក្នុងរណ្តៅដែលជីកយ៉ាងរាក់ ពេលខ្លះសពក៏ត្រូវចចកកាយស៊ីជាអាហារ ។ ប្រហែលជាភ្លៀងធ្លាក់រៀងរាល់ថ្ងៃ ហើយពុំអាចបន្តការដ្ឋានទំនប់តទៅទៀតបានទើបអង្គការសម្រេចរំសាយទំនប់នេះនៅខែកញ្ញា ឆ្នាំ១៩៧៥ ។ ពេលដែលដឹងថា អង្គការរំសាយការធ្វើទំនប់នោះ ខ្ញុំត្រេកអរជាខ្លាំងដោយគិតស្មានថា បានវិលត្រឡប់ទៅសហករណ៍វិញ ដែលនៅសហករណ៍ការងារស្រួលជាង ។ សេចក្តីសង្ឃឹមក៏បានរលាយទៅវិញដោយអង្គការបានបញ្ជូនទៅការដ្ឋានថ្មីមួយទៀតដែលមានឈ្មោះថា ស្រែសម័យ ដែលស្ថិតនៅជើងភ្នំអង្គខាងលិចស្ថានីយ៍រថភ្លើងស្តុកអាចម៍រមាស ។ យុវជនដែលមានជំងឺជាច្រើនដែលដើរពុំរួចហើយគ្មានរទេះជិះបានដួលស្លាប់តាមផ្លូវ ។ ពេលនោះគ្មាននរណាជួយនរណាឡើយ ចំណែកអង្គការឲ្យតម្លៃតែអ្នកដែលមានកម្លាំងតែប៉ុណ្ណោះ ។

### ៣៩) ឡង់រ៉ូវែរពេជ្ឈឃាត

អង្គការហៅថាស្រែសម័យ ព្រោះទីនេះលាតសន្ធឹងលើផ្ទៃដីប្រហែល៣៥០០ហិកតា លាតសន្ធឹងពីខាងលិចផ្សាររមាសតាម

បណ្តោយផ្លូវលេខ៥៣ ខាងត្បូងទៅទល់ភ្នំអង្គរបូតដល់វត្តខ្ទង់ពពក ។ នៅទីនោះ យើងលែងបានជួបមុខ មិត្ត គៀន ទៀតហើយ ព្រោះគាត់ត្រូវបានអង្គការតម្លើងឋានៈជាបញ្ជាការ «គណៈង» ដែលគ្រប់គ្រងលើការដ្ឋានទាំងមូលដែលត្រួតត្រាសមរភូមិស្រែសម័យនេះ ។ តាមខ្ញុំបានឮ គណៈបញ្ជាការដ្ឋាននេះមាន មិត្ត គៀន ជាបញ្ជាការរួម និងសមាជិកពីរនាក់ ដែលមានយុវនារីម្នាក់ឈ្មោះ ផា និង នុត ជាយុវជន ក៏ប៉ុន្តែខ្ញុំពុំដែលឃើញអ្នកទាំងនោះទេ ។ កងប្រយុទ្ធឈានមុខត្រូវបានបែងចែកជាវរសេនាតូចដែលត្រួតត្រាដោយគណៈបញ្ជាការ គណៈ «វ» ហើយត្រូវបែងចែកជាបន្តបន្ទាប់ថ្នាក់ «អនុសេនា» ខ្ញុំត្រូវស្ថិតនៅអនុសេនាធំដែលកាន់ក្តាប់ដោយ គណៈ«គ» ពីរនាក់ ។ អនុសេនារបស់យើងមានកម្លាំង៧០ នាក់ សុទ្ធតែយុវជននៅលីវ ។

គណៈដឹកនាំអនុសេនារបស់យើងទាំងពីរនាក់គឺម៉ែន និង ផល ។ មិត្ត ផល នេះ មិនមែនជាមិត្ត ផល ដែលបានបញ្ជូនខ្ញុំឲ្យទៅអង្គភាពទំនប់ទឹកត្រពាំងខ្ទង់នោះទេ គឺជាយុវជនម្នាក់ផ្សេងទៀតនៅលីវ អាយុប្រហែល២៨ឆ្នាំ ។ ចំណែក ម៉ែន មានវ័យប្រហែល ៣៥ឆ្នាំ សក់រួញ ក្បាលឆក ជាអ្នកមានប្រពន្ធ ។ ម៉ែន និង ផល ជាអ្នកកាន់កាប់អនុសេនាធំប្រតិបត្តិការឈានមុខ ។ ម៉ែនជាអតីតអ្នកបួស ហើយធ្លាប់ជាគ្រូសូត្រនៅវត្តមួយក្នុងឃុំចោងម៉ោង គាត់សម្បុរសស្អាត ទឹកមុខជាអ្នកចេះដឹង ។ ពេលរដ្ឋប្រហារ លន់ លន់ ឆ្នាំ ១៩៧០ ម៉ែន បានសឹកពីផ្នួសចូលព្រៃម៉ាក់គីតស៊ូចលនាបដិវត្តន៍ជាមួយពួកយៀកកុង ។ ម៉ែន ជាមនុស្សសកម្មប្រយុទ្ធណាស់ ព្រោះគាត់មានការសិក្សាខាងផ្លូវធម៌យ៉ាងស្ទាត់ជំនាញនិងវោហារយ៉ាងក្បោះក្បាយផង ។ គុណវិបត្តិរបស់ ម៉ែនគឺគាត់ត្រូវបានអង្គការទម្លាក់ឋានៈដោយសារគាត់ជាមនុស្សលោភលន់ និងចូលចិត្តឲ្យអ្នកដទៃអែបអប ព្រមទាំងជាប់និន្នាការវណ្ណៈអនុធនពុទ្ធសាសនា ទើបបានជាគាត់មិនអាចមានឋានៈអ្វីធំដុំដូចអ្នកដទៃ ។ ម៉ែន ជាមនុស្សមានមហិច្ឆិតាខ្ពស់ព្រមទាំងជាអ្នកចិត្តសាស្ត្រនិងពូកែ ។ លក្ខណៈសម្គាល់របស់ ម៉ែន គឺគាត់ចូលចិត្តស្លៀកសារ៉ុងសូត្រ និងពាក់ខ្សែកមាសធំៗ ដែលមានបណ្តោងធ្វើអំពីខ្លាយគាន់ស្រោបមាស ។ វាផ្ទុយពី ផល ដែលជាមនុស្សសាមញ្ញរួសរាយមិនតម្កើងខ្លួន សម្តីតិចៗមិនដែលបន្ទោសនរណាឡើយ ។ ខ្ញុំពុំដឹងថា ទាំងពីរនាក់នេះ តើនរណាធំជាងនរណាទេ ព្រោះពុំដែលពិភាក្សាអ្វីឲ្យយើងឮសោះឡើយ ។

យើងដេកនៅរោងធ្វើពីឫស្សីប្រក់ស្បូវមានគ្នាប្រហែលចិតសិបនាក់ ។ ចំណែក ក្រុមយុវនារី មានជំរំរបស់ខ្លួនផ្សេង ។ នៅទីនេះ គ្មាននរណាបានគិតគូរពីរឿងស្នេហាអ្វីទេ ព្រោះម្នាក់ៗរកតែពេលដេកពុំបាន អាហារក៏ពុំឆ្អែត រីឯដៃជើងវិញប៉ុនដងរែក សូម្បីតែស្មៅឬវល្លិ៍តាមផ្លូវក៏ដំពប់ដួលដូចតាចាស់ ។ នៅទីនេះ ក៏ដូចជាការដ្ឋានទំនប់ទឹកដែរ រគាំងវាយនៅម៉ោងបួនកន្លះទៀប ម៉ោងប្រាំចេញដំណើរទៅការដ្ឋានស្រែសម័យ ។ យើងត្រូវតែច្រៀងចម្រៀងបដិវត្តន៍ ត្រូវតែសរសើរអង្គការបដិវត្តន៍ ដ៏មហាភ្លឺស្វាង មហាលោតផ្លោះ មហារុងរឿង មហាអស្ចារ្យ ។

ពេលធ្វើការនៅស្រែសម័យ ខ្ញុំបានជួបអតីតមិត្តរួមថ្នាក់ដែលបានជួបម្តងហើយ នៅទំនប់ក្រាំង តាមុំ គឺប៊ូ ឆុន ។ គាត់ជាមនុស្សរឹងមាំ ព្រោះជាកូនកសិករ ចេះធ្វើស្រែភ្ជួររាស់ ដកសំណាបយ៉ាងស្ទាត់ជំនាញ ។ ប៊ូ ឆុន ចេះចាប់ត្រីចាប់ ក្តាម កង្កែប ដូច្នេះគាត់ពុំសូវមានបញ្ហាសុខភាពប៉ុន្មានទេ ។ ពេលធ្វើការ គាត់ច្រៀងបទបដិវត្តន៍យ៉ាងពិរោះ ព្រមទាំងចេះនិយាយកំប្លែងឲ្យសើចគ្រប់គ្នា ។ ប៊ូឆុន បានសួរខ្ញុំថា តើមានលោកប្រវត្តិរូបដែរឬអត់ ខ្ញុំបានប្រាប់គាត់ថាជាកម្មកររត់តុគុយទាវនៅភ្នំពេញ ។ ពេលនោះ ប៊ូឆុន បាននិយាយប្រាប់ខ្ញុំថា រូបគាត់បានសារភាពចំពោះអង្គការថា ជានិស្សិតនៅមហាវិទ្យាល័យជាតិគរុកោសល្យ ។ ពេលនោះខ្ញុំនៅស្ងៀមមិនចេញស្តី ។ ខ្ញុំបារម្ភចំពោះវាសនារបស់មិត្តភក្តិរូបនេះណាស់ តែខ្ញុំក៏បារម្ភនឹងខ្លួនឯងដែរ មិនដឹងថានឹងលាក់បានយូរប៉ុណ្ណា ។

ដូចដែលខ្ញុំបានគិត ថ្ងៃនោះបានមកដល់ចំពោះ ប៊ូឆុន មែន ។ ថ្ងៃមួយខ្ញុំឃើញឡានឡង់រ៉ូវែរមួយបើកចូលក្នុងការដ្ឋានមានយុវជនប្រហែលដប់នាក់ឈរតម្រង់ជួរក្នុងនោះមានប៊ូឆុនដែរ ។ ខ្មែរក្រហមបោះបាវក្រចៅទទេ ចំណុះមួយរយគីឡូក្រាមដល់អ្នកទាំងនោះ ។ អ្នកនៅមុខគេចូលក្នុងបាវ អ្នកទីពីរចងមាត់បាវ ។ អ្នកទីពីរចូលក្នុងបាវ អ្នកទីបីចងមាត់បាវ អ្នកទីបីចូលបាវ អ្នកទីបួនចងមាត់បាវ ។ បន្ទាប់ពីចូលអស់ហើយ ខ្មែរក្រហមលើកបាវមនុស្សដាក់លើឡានហើយដឹកចេញ ។ គួរឲ្យអាសូរមិត្តរបស់ខ្ញុំដែលខំធ្វើការយ៉ាងនេះព្រមទាំងច្រៀងយ៉ាងពិរោះតែនៅពុំអាចសង្គ្រោះជីវិតខ្លួនឯងបាន ។ ឡានឡង់រ៉ូវែរនោះបានបង្ហាញខ្លួនជាញឹកញាប់ហើយរាល់លើកមានមនុស្សយ៉ាងតិចដប់នាក់ត្រូវចាប់បញ្ចូលក្នុងបាវហើយដឹក

ចេញ ។ តាមរយៈមិត្ត ម៉ែន អ្នកដែលចាប់ដាក់ឡានទាំងនោះ សុទ្ធតែជាខ្មាំងសេ.អ៊ី.អា និងកា.ហ្សេ.បេ ដែលត្រូវយកទៅសួរចម្លើយនៅមន្ទីរសន្តិសុខមជ្ឈិមនៅទីក្រុងភ្នំពេញ ។

## ៣៦) ខ្សែអង្រឹង

ស្រមោលឡានឡង់រ៉ូវែរជាព្រលឹងខ្មោចបង្កភ័យខ្លាចពេញការដ្ឋានស្រែសម័យនោះហើយ ដែលខ្ញុំហៅថា ឡានពេជយាត ការឡើងឡានពេជ្ឈឃាតបានន័យថា សេចក្តីស្លាប់ព្រោះខ្ញុំពុំដែលឃើញនរណាត្រឡប់មកវិញសោះ ។ ខណៈនេះ ស្រមោលពេជ្ឈឃាតមួយទៀតក៏បានមកដល់ ។ យុវជនម្នាក់មានអាយុប្រហែល២៥ឆ្នាំ ជាកូនកាត់ចិនឈ្មោះ ហុង សែ ជាមនុស្សដែលពុំសូវនិយាយស្តីដំណើរមួយៗ ហើយមិនដែលសេពគប់នឹងនរណាទេ ។ ប្រហែលជាបួនប្រាំថ្ងៃហើយ ខ្ញុំតែងឃើញគាត់សំលៀងកាំបិតផ្គាក់របស់ខ្លួនយ៉ាងយកចិត្តទុកដាក់ ។ ខ្ញុំតែងតែលួចសរសើរ សែ ថាជាយុវជនដែលខស្វាហ៍ព្យាយាមលត់ដំជីវិតរបដិវត្តន៍ ។

នាខែកញ្ញានេះ ភ្លៀងធ្លាក់ទាំងយប់ យើងទាំងអស់ត្រូវធ្វើការភ្ជួរ ដកស្ទូងទាំងរងាញ័រញាក់ រីឯរបបអាហារមានតិចតួចស្ដើងខ្លាំងណាស់ ជួនពេលខ្លះ បបរមួយវែករាវកក្លូកមើលគ្រាប់អង្ករមិនឃើញ ។ ពេលយប់យើងត្រូវដេកទាំងទទឹក ឬទាំងប្រឡាក់ភក់ដោយសារអស់កម្លាំងពេក ក៏ពុំបានគិតគូររឿងងូតទឹកសម្អាតខ្លួនរាប់ខែមកហើយ ក៏ពុំដែលស្គាល់ជាតិសាប៊ូដុសខ្លួនឬកក់សក់អ្វីដែរ ។ រសៀលថ្ងៃមួយពេលដែលយើងកំពុងស្ទូង ស្រាប់តែភ្ញាក់ដូចរន្ទះបាញ់ដោយឮសូរសម្រែកឆោឡោ និងស្នូរកាំភ្លើង ។ ទាំងអស់គ្នាស្ទុះឡើងពីស្រែបានឃើញកម្មាភិបាលម្នាក់ដួលទៅលើភ្លឺស្រែដែលត្រូវ ហុង សែ កាប់នឹងកាំបិតផ្គាក់ដែលបានសំលៀងពីថ្ងៃមុន រីឯកាំភ្លើងរបស់គាត់ក៏ត្រូវ ហុង សែ ដណ្តើមបាន ។ កងឈ្លប និងនីរសារដទៃទៀតបានមកទាន់និងបាញ់ត្រូវ ហុង សែ ប៉ុន្តែចៃដន្យកាំភ្លើង ហុង សែ នៅសល់គ្រាប់ហើយបាញ់តបវិញត្រូវនីរសារពីរនាក់របួសដែរមុននឹងដាច់ខ្យល់ស្លាប់ ។ សពរបស់ ហុង សែ ត្រូវចងអូសបញ្ច្រាស់ជើងយកមកដាក់ឲ្យយើងមើលនេះហើយ ជាខ្មាំងប្រឆាំងបដិវត្តន៍ ។

ព្រឹត្តិការណ៍ថ្ងៃនេះ បានធ្វើឲ្យស្ថានការណ៍ជីវិតរបស់យើងកាន់តែជួបប្រទះនឹងសភាពធ្ងន់ធ្ងរឡើងៗ ។ ជារៀងរាល់ថ្ងៃមានការចាប់ខ្លួនចំពោះអ្នកណាដែលធ្លាប់ជិតស្និទ្ធឬជាប់បងប្អូនជីដូនមួយជីទួតមួយ សូម្បីតែនៅស្រុកជាមួយគ្នាគឺត្រូវចាប់ខ្លួនទាំងអស់ ចំណែកការផ្សេងៗក៏កាន់តែបង្កើនលើសដើម ។ កាលមុន អង្គការចាប់តែអតីតគ្រូបង្រៀន សាស្ត្រាចារ្យ វេជ្ជបណ្ឌិត អតីតទាហាន លន់ នល់ ពេលនេះ គឺចាប់មិនរើសមុខ សូម្បីតែមនុស្សឆ្កួតមិនគ្រប់ដប់ក៏ត្រូវចាប់ ចំណែកកម្មាភិបាល មេកង មេក្រុម ដែលពុំសូវសកម្ម ពុំត្រូវបង្ខំឲ្យធ្វើការទេគឺត្រូវបានផ្លាស់ចេញទៅបាត់ពុំដឹងជាទៅទីណា ស្លាប់ ឬរស់ព្រោះមិនដែលឃើញត្រឡប់មកវិញសោះ ពេលនោះគឺជាយុគដ៏រន្ធត់មួយនិងគួរខ្លាចរអារ ។ ខ្ញុំមានចម្ងល់មួយថា ការចាប់ខ្លួនមានចំពោះតែយុវជនតែប៉ុណ្ណោះ ចំណែកយុវនារីពុំដែលឃើញបាត់ខ្លួនទេ ឯចំពោះសុខភាពក៏ដូច្នោះដែរ របបអាហារប៉ុនគ្នា តែនារីទាំងនោះទោះជាស្គមក៏មិនស្គមហួសហេតុ ហើយអត្រាស្លាប់នឹងជំងឺក៏តិចជាងយុវជនដែរ ។

ការចាប់ខ្លួនលើកនេះ ពុំមែនដោយឡានឡង់រ៉ូវែរទេ ព្រោះវាមានចំនួនច្រើនណាស់ ។ ប្រធានកងឈ្លបដែលយើងស្គាល់ច្បាស់នៅឈ្មោះថា សមមិត្ត គក់ ។ គក់ តែងតែជិះកង់ចុះឡើងរាល់ថ្ងៃ តាមផ្លូវការដ្ឋានដោយមាននីរសារបួនប្រាំនាក់ជិះកង់តាមក្រោយ ។ ចំពោះយើង វត្តមានរបស់ គក់ គឺជាសញ្ញាអាសន្ន ព្រោះ គក់ ហាក់បីដូចជាពេជ្ឈឃាតក្នុងរឿងព្រេងបុរាណ គ្មាននរណាម្នាក់ហ៊ានមើលមុខគាត់ចំទេ ។ ពេលដែលគាត់និយាយស្តី សំឡេងរបស់គាត់ ហាក់បីដូចជាជួងមរណៈ ។ ចំពោះអ្នកណាដែលត្រូវចាប់ខ្លួនគឺត្រូវចងមុខនឹងក្រណាត់ពណ៌ខ្មៅហើយដឹកខ្សែអូសពីក្រោយកង់ ពេលខ្លះ គក់ បង្គាប់ឲ្យស្រែកថា "យក្សអ៊ុំរ" ហើយឲ្យសើចហាសៗ ។ កាលសម័យនោះ ពុំមានពិលចុចមើលមុខទេ គក់ ប្រើដែកកេះដើម្បីឆ្កុះមើលមុខជនសង្ស័យ ។ មានយប់មួយវេលាម៉ោងដប់មួយ ខ្ញុំបានឮសម្រឹបជើងនិងស្នូរទម្លាក់ឈ្នាន់កង់ ពេលដែលខ្ញុំដេកក្នុងអង្រឹង ។ គក់ ដាស់យុវជនពីរនាក់ឲ្យក្រោករួច ហើយហូតខ្សែអង្រឹងរបស់យុវជននោះចងដៃទៅក្រោយ ខ្ញុំរន្ធត់ខ្លាំងណាស់ ក៏ធ្វើជាពុតដេកលក់ ។ មួយសន្ទុះ អ្នកទាំងនោះបានដើរសំដៅមកអង្រឹងរបស់ខ្ញុំ ។ មិត្ត គក់ បានកេះដែកកេះបំភ្លឺលើមុខរបស់ខ្ញុំ ពេលនោះខ្ញុំស្ទុតស្មារតីស្ទើរបាត់ដង្ហើម តែក្រោយមក ខ្ញុំឮមិត្ត គក់ និយាយទៅកាន់នីរសារថា« មិនមែនទេ រួចហើយក៏ចាកចេញដោយនាំទាំងយុវជនប៉ុន្មាននាក់ចងអូសនឹងខ្សែអង្រឹងដែលធ្លាប់ដេកចេញទៅបាត់»

## ៣៧) លាហើយសញ្ញាបត្រ

ក្នុងចំណោមគណៈដឹកនាំអនុសេនាធំទាំងពីរនាក់ ម៉ែន ពុំចូលចិត្តខ្ញុំទេ ។ ចំពោះ ម៉ែន ខ្ញុំធ្វើអ្វីក៏ខុសដែរ ម៉ែន ថា ដំណើរខ្ញុំដូចកុងស៊ីពេលហូបបាយ ខ្ញុំធ្វើឬកដូចក្នុងហាង ពេលខ្ញុំនិយាយជាមួយយុវជនដទៃទៀត ម៉ែន ថាខ្ញុំនិយាយភាសាស្តេច ។ ខ្ញុំតែងតែចង់ផ្គាប់ចិត្ត ម៉ែន ណាស់ តែគាត់ហាក់បីដូចជាពុំផ្តល់ឱកាសឲ្យខ្ញុំចូលជិតគាត់ទាល់តែសោះ ។ ថ្ងៃមួយពេលសម្រាកបាយថ្ងៃត្រង់ហើយ ខ្ញុំប្រាសខ្លួនដេកលើនាបឬស្សី ម៉ែន បានដើរកាត់ ។ ស្រាប់តែ ម៉ែន ឈប់ទ្រឹងសម្លឹងមកខ្ញុំ តាំងពីក្បាលដល់ចុងជើង ពីចុងជើងដល់ក្បាល ម៉ែន ហៀបនឹងដើរចេញទៅហើយ តែបកមកក្រោយវិញដោយមិនអស់ចិត្តថា នែ៎មិត្ត តើស្នាមថ្មេរនៅជើងរបស់មិត្តឯងនេះត្រូវនឹងអ្វី? បាទ! នេះជាស្នាមរបួសពេលខ្ញុំលេងកីឡាបួនឆ្នាំហើយ ។ តើមិត្តឯងត្រូវរបួសដោយគ្រោះថ្នាក់ធម្មតា ពេលនោះ មិត្ត ម៉ែន បានដើរយ៉ាងលឿនសំដៅទៅផ្ទះបាយ ។ ធម្មតាអង្គការមិនមានការិយាល័យធ្វើការទេ គឺយកផ្ទះបាយជាកន្លែងប្រជុំ ឬសរសេររបាយការណ៍ផ្សេងៗ ។ ប្រហែលប្រាំនាទី ម៉ែន បានប្រើនីសារម្នាក់ឲ្យមកហៅខ្ញុំឲ្យទៅជួប ។ នៅផ្ទះបាយខ្ញុំឃើញ ម៉ែន និង ផល បានរង់ចាំខ្ញុំនៅទីនោះ ។ ម៉ែន ចាប់ផ្តើមក្នុងនាមជាជនបដិវត្តន៍ ខ្ញុំសូមឲ្យមិត្តនិយាយការពិត តើមិត្តមានមុខនាទីជាអ្វីក្នុងរបបរដ្ឋការលន់ នល់? ខ្ញុំជាកម្មកររត់គុយទាវនិងជាតែកុងរឺម៉ក ។ ម៉ែន ក្រោកឈរខឹងញ័រអស់ទាំងខ្លួនហើយនិយាយថា នែ៎មិត្តឯងនិយាយកុហកអង្គការ នេះជាចម្លើយបច្ចេកទេស ។ ម៉ែន សម្លក់ខ្ញុំដូចខ្លែងសម្លក់កូនកណ្តុរ ។ ខ្ញុំកើតក្នុងគ្រួសារអ្នករកស៊ីធម្មតា ខ្ញុំពិតជាតែកុងរឺម៉កមែន ។ ចម្លើយនេះហាក់ដូចជាយកសាំងទៅចាក់ភ្លើង ។ ម៉ែន ស្រែកសន្ធាប់ដាក់មិត្ត ផល ដែលសម្លឹងមកខ្ញុំដោយក្រសែភ្នែកអាណិតអាសូរថា នែ៎ផល តើមិត្តជឿសម្តីរបស់វាឬទេ? តាមពិតវាជាទាហានពាក់សក្តិពីរ ។ មិត្ត ផល មិនឆ្លើយតបនឹង ម៉ែន តែងាកមកខ្ញុំហើយប្រាប់ថា ត្រឡប់ទៅធ្វើការវិញចុះ ខ្ញុំដឹងហើយថានឹងធ្វើយ៉ាងម៉េច ។

ខ្ញុំត្រឡប់មកកន្លែងដេកវិញ ហើយយកបង្វិចមករើ ។ ខ្ញុំបានទុករូបថតដែលថតជាមួយមិត្តភក្តិកាលនៅរៀនថ្នាក់មធ្យមសិក្សាទុតិយភូមិ និងសៀវភៅខ្លះជាភាសាបារាំង ។ ខ្ញុំធ្វើជាចេញទៅមុជទឹកត្រពាំងក្បែរជំរំដោយដណ្តប់ក្រមាដោយកំពៀកទាំងរូបថត និងឯកសារទាំងនោះក្រោមក្លៀក ។ នៅមាត់ត្រពាំងខ្ញុំបានបោចវល្លិ៍ និងយកថ្មមួយដុំ ចងឯកសារទាំងនោះភ្ជាប់នឹងដុំ ហើយចុះមុជទឹកត្រពាំង និងទម្លាក់សញ្ញាបត្រ និងរូបថតទៅបាតត្រពាំងដោយពោលតិចៗថា លាហើយ សញ្ញាបត្រជាទីស្រឡាញ់! ។ ដុំក្រដាស់ដែលចងជាប់ដុំថ្មបានលិចបាត់ក្នុងជម្រៅទឹក គឺដោយសារតែគំនិតនេះហើយដែលបានជួយជីវិតខ្ញុំ ។ ពេលត្រឡប់ពីធ្វើការពេលល្ងាច នៅកន្លែងដេករបស់ខ្ញុំ មានកងឈ្លបបួននាក់បានរង់ចាំខ្ញុំ ហើយបង្គាប់ឲ្យខ្ញុំលើកដៃឡើងលើ ។ ខ្ញុំមានការរន្ធត់ចិត្តណាស់លើកដៃឡើងលើ ខ្ញុំគិតថា ជីវិតរបស់ខ្ញុំនឹងត្រូវចប់តែត្រឹមនេះហើយ ។ ឈ្លបពីរនាក់យកបង្វិចរបស់ខ្ញុំមករលាក់ដើម្បីឆែកមើល ប៉ុន្តែមិនមានរបស់អ្វីដែលគួរឲ្យសង្ស័យក្រៅពីអាវកញ្ចាស់មួយ និងប្រអប់ស៊ីរ៉ាវាយស្បែកជើងម៉ាកឃីវីមួយទេ ។ ឈ្លបម្នាក់បានបើកប្រអប់ឃីវីឃើញតែធ្មេញពីរគ្រាប់ ហើយសួរថា នេះជា ស្អី? ជាធ្មេញរបស់ម្តាយខ្ញុំ កាលពីបូជាសពម្តាយខ្ញុំបានដើរធ្មេញរបស់គាត់ពីគំនរផេះក្នុងបំណងទុកឲ្យប្អូនរបស់ខ្ញុំ សម្រាប់ធ្វើបន្តោងខ្សែក ។ ចោលវាទៅ! មេឈ្លបបង្គាប់ បដិវត្តន៍មិនត្រូវការជំនឿអរូបិយរបៀបនេះទេ ។ ថាហើយ មេឈ្លបក៏ក្រវាត់ធ្មេញរបស់ម្តាយខ្ញុំចោលទៅក្នុងគុម្ពោតព្រៃបាត់ រួចនិយាយមកកាន់ខ្ញុំថា បានហើយ ទៅហូបបាយចុះ! ។ ពេលនេះខ្ញុំបានផុតទុក្ខមួយគ្រាហើយ បើសិនជាឈ្លបឆែកឃើញរូបថត និងសញ្ញាបត្រដែលសរសេរជាភាសាបារាំងម៉្លេះវាសនាខ្ញុំដឹងទៅជាយ៉ាងណា?

## ៣៨) នឹមបដិវត្តន៍

ទោះបីជា ម៉ែន ស្អប់ខ្ញុំយ៉ាងណាក៏ដោយ ផល នៅការពារខ្ញុំជានិច្ច ។ ផល តែងតែបង្ហាញពីទឹកចិត្តសន្តោសដល់ខ្ញុំដោយមិនសូវជាបង្ខំឲ្យខ្ញុំធ្វើការធ្ងន់ៗទេ ផល បានចាត់តាំងឲ្យខ្ញុំត្បាញបង្គី វេញខ្សែគោ និងឃ្វាលគោជាដើម ។ នាចុងខែកញ្ញា ឆ្នាំ១៩៧៥ យុវជនជាច្រើនធ្លាក់ខ្លួនឈឺដោយមានជំងឺគ្រុនចាញ់ និងគ្មានអាហារបរិភោគ ។ អ្នកដែលកម្លាំងខ្សោយក៏អស់ជីវិតនៅលើទឹកដីស្រែសម័យនោះ ឯខ្លះទៀតត្រូវអង្គការបញ្ជូនទៅមន្ទីរពេទ្យស្រុក១៤ នៅខ្ទង់ពពក ។ កងអនុសេនាធំរបស់យើងមាននៅសល់ប្រហែលជាងសាមសិបនាក់ប៉ុណ្ណោះ ក្នុងនោះមានខ្ញុំម្នាក់ដែរ ។ ដោយតម្រូវការឫស្សី និងវល្លិ៍សម្រាប់ត្បាញ និងវេញខ្សែគោ ខ្ញុំត្រូវដើរចូលព្រៃជារៀងរាល់ថ្ងៃ

ថ្ងៃមុន ។ ខ្ញុំស្គាល់ព្រៃដូចជាស្គាល់ផ្សារថ្មីដូច្នោះដែរ ខ្ញុំដើរកាត់ជ្រោះជ្រលងផងអូរ កាត់ព្រៃខ្មោច ។ ខ្ញុំបានជួបប្រទះនឹងអន្លង់កប់ខ្មោច មានធំ មានតូច ។ អន្លង់ធំមានចំនួនប្រហែលពីររយនាក់ រីឯអន្លង់តូចមានចំនួនប្រហែល២០នាក់ ។ មានអន្លង់ខ្លះយូរហើយដោយមានស្នាមលុបនិងស្មៅដុះ តែមានអន្លង់ខ្លះនៅថ្មីប្រេះដី ខ្លះទៀតមានលេចដៃឬជើងមកក្រៅដោយសារអន្លង់នោះរាក់ពេក ក្លិនស្អុយឆ្អួលច្រមុះ ។ ពេលខ្លះខ្ញុំដើរមិនប្រយ័ត្នក៏ជុំជើងត្រឹមជង្គង់ ពេលដកជើងមកវិញ ក៏មានជាប់ដង្កូវរវ៉ាម ។ ខ្ញុំមិនខ្លាចខ្មោចទេ ប៉ុន្តែនឹកស្រណោះទៅដល់គ្រួសាររបស់ម្តាយមីងខ្ញុំដែលស្គាល់ថា ប៉ែ គឺព្រមទាំងកូន និងចៅ២៦នាក់ ត្រូវអង្គការសម្លាប់ចោលកប់ក្នុងអន្លង់តែមួយគឺតែប៉ុន្មានថ្ងៃក្រោយជម្លៀសថ្ងៃ១៧ មេសា ១៩៧៥ ។

នៅក្នុងព្រៃក្បែរភ្នំអង្គនេះ មិនខ្វះអ្វីហូបទេ ខ្ញុំរកបានផ្សិតខ្យង ដំឡូងជ្រូក ដំឡូងទឹក បន្លែ ផ្ទៃ ដែលខ្ញុំអាចដុតចម្អិនរួចបានហូបនៅក្នុងព្រៃមុននឹងត្រឡប់មកជំរំវិញ ។ បន្លែដែលខ្ញុំត្បាញស្អាតល្អ ហើយមាំណាស់ ដែលជាហេតុធ្វើឲ្យមិត្តផល សប្បាយចិត្ត ប៉ុន្តែម៉ែនពុំដែលសរសើរខ្ញុំឡើយ ។

ថ្ងៃមួយ ខ្ញុំបានតាមដានជើងសត្វស្វា ដើម្បីរៀបចំអន្ទាក់ក៏ជួនជាបានមកដល់ជំរំអាថ៌កំបាំងមួយនៅជំណាក់ផ្ទឹកខាងជើងភ្នំអង្គ ។ ពេលមកដល់ជាយព្រៃ ខ្ញុំក៏ប្រទះឃើញព្រឹត្តិការណ៍ដ៏រន្ធត់មួយ គឺមនុស្សអូសនង្គ័ល ។ បុរសដ៏ស្គមស្គាំងពីរនាក់ទាញនឹមនង្គ័លដែលភ្ជួរដោយកម្មាភិបាលខ្មែរក្រហមកាន់រំពាត់ស្រែកបញ្ជាឲ្យដើរឲ្យលឿនឡើង ។ ទោះបីជានៅឆ្ងាយបន្តិចក្តី ក៏ខ្ញុំអាចចំណាំភិនភាគបុរសម្នាក់ ដែលក្បាលទំពែកកំពុងទាញនឹមនង្គ័លនោះដែរ ។ នោះគឺវេជ្ជបណ្ឌិតម្នាក់ដែលធ្វើការនៅកំពង់ឆ្នាំង ហើយម្នាក់ទៀតគឺសាស្ត្រាចារ្យបរិញ្ញាបត្រដែលធ្លាប់បង្ហាត់ខ្ញុំនៅវិទ្យាល័យព្រះសុរាម្រិត ។ ខ្ញុំបានបង្ហាញខ្លួននៅចំពោះមិត្តដែលកាន់ខ្សែតី ។ គាត់បានសួរខ្ញុំថា តើឯងមកទីនេះធ្វើអ្វី? ខ្ញុំដើរកាប់ឫស្សី និងបោចវល្លិ៍យកទៅធ្វើបង្គី ។ មិត្តនោះក៏ប្រាប់ថា ឆាប់ចេញពីនេះទៅ! ទីនេះជាជំរំដុសខាត់ខួរក្បាល! ។ មិត្តម្នាក់នោះបានប្រាប់ខ្ញុំថា នៅទីនេះ អ្នកដែលមានជីវិតរស់នៅលុះត្រាតែឆ្លងកាត់បទពិសោធន៍នៃការងាររលត់ដំយ៉ាងខ្លាំងបំផុត ដូចជាពីរនាក់នោះអ៊ីចឹង គឺត្រូវបំពាក់នឹមបដិវត្តន៍បានន័យថាក្នុងការងាររបស់អង្គការពុំចាំបាច់តែមានគោឬក្របីនោះទេ មនុស្សក៏អាចអូសនង្គ័លបានដែរ ។ បន្ទាប់ពីបាននិយាយសំណេះសំណាលជាមួយបានបន្តិច ខ្ញុំមានបំណងចង់សុំឲ្យដឹងថា តើបងប្រុស ប៊ុនថាន បានមកដល់ទីនេះដែរឬទេ?

## ៣៩) ដីលេខមួយ

មិត្តម្នាក់នោះបានប្រាប់ខ្ញុំថា ក្នុងជំរំមានអ្នកទោសជាច្រើនដែលចាប់មកពីសហករណ៍និងការដ្ឋាន ខ្លះស្លាប់បាត់ទៅហើយ តែខ្លះទៀតកំពុងធ្វើដីលេខមួយ ជាដីម្យ៉ាងដែលយើងយកដីដំបូកឲ្យម៉ដ្ឋលាយទឹកឲ្យស្អិតទើបយកលាមកមនុស្សមកលាយ ហើយចាក់ពុម្ពដូចជាដីឥដ្ឋ ។ បន្ទាប់មក ខ្ញុំក៏បានលាត្រឡប់មកវិញ ប៉ុន្តែខ្ញុំព្យាយាមមកទីនេះយ៉ាងញឹកញាប់ ព្រោះខ្ញុំសង្ស័យថា បងប្រុសប្រហែលជាបានមកដល់ទីនេះដែរ ។ ក្រោយមកខ្ញុំ ក៏បានក្លាយជាមិត្តភក្តិស្និទ្ធស្នាលជាមួយមិត្តកងសន្តិសុខរូបនេះ ។ គាត់ឈ្មោះថា មិត្ត ហ៊ឹម ។ ជារៀងរាល់លើកដែលខ្ញុំឆ្លងកាត់ទីនេះ ខ្ញុំតែងតែនាំនូវសត្វទន្សាយព្រៃ លលក ឬស្វា ដែលខ្ញុំដាក់អន្ទាក់បានមកផ្ញើមិត្ត ហ៊ឹម ហើយយើងចម្អិនសត្វហូបជាមួយគ្នា ព្រោះថា សូម្បីតែកងសន្តិសុខទាំងនោះក៏ពុំមានអ្វីហូបគ្រប់គ្រាន់ផងដែរ ។ ក្រោយមក ខ្ញុំក៏បានស្គាល់មិត្តបីបួននាក់ទៀត ជាហេតុធ្វើឲ្យងាយស្រួលក្នុងការស្វែងរកបងប្រុសខ្ញុំ ។ មិត្ត ហ៊ឹម បាននិយាយប្រាប់ខ្ញុំរឿងរ៉ាវជាច្រើនអំពីជំរំលត់ដំមួយនេះ ។

តាមខ្ញុំបានចាំ ទីនេះប្រហែលមានឈ្មោះថា មន្ទីរ៧១៤ ដែលមានទីតាំងនៅជើងភ្នំជំណាក់ផ្ទឹក ជាទីស្នាក់ការសន្តិសុខនៃស្រុក១៤ ។ មន្ទីរ៧១៤ នេះទើបនឹងបង្កើតក្រោយថ្ងៃជម្លៀស១៧ មេសា ១៩៧៥ ប៉ុណ្ណោះ ។ អ្នកទោសត្រូវបែងចែកជាបីកម្រិត ។ កម្រិតទីមួយគឺបញ្ញវន្តដែលមិនកាន់អាវុធ ដូចជា សាស្ត្រាចារ្យ គ្រូបង្រៀន វេជ្ជបណ្ឌិត និស្សិត អ្នកជំនាញ វិស្វករ ។ កម្រិតទីពីរ ជាទាហាន កម្ម៉ង់ដូមេហាសិបខ្ទង់ ។ កម្រិតពិសេស គឺអតីតកម្មាភិបាល មេបញ្ជាការកងទ័ពរំដោះ គណៈសហករណ៍ គណៈការដ្ឋានដែលវង្វេងក្បត់បដិវត្តន៍ ក្បត់វណ្ណៈអធន ។ កម្រិតទីបីនេះ ត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរណាស់ ព្រោះត្រូវចាត់ទុកថា ខ្មាំងស៊ីរូងផ្ទៃក្នុងក្បត់បដិវត្តន៍ក្បត់ប្រជាជន ។ ចំពោះអ្នកដែលបានមកដល់ទីនេះ សេចក្តីសង្ឃឹមថានឹងបានរស់នោះមានតិចតួចណាស់ ហើយក៏មានកងសន្តិសុខខ្លះក៏ត្រូវបានអង្គការរកឃើញជាខ្មាំងសេ.អ៊ី.អា ដែរ ។ អ្នកទាំងនោះនឹងត្រូវកម្ទេចភ្លាមៗ ។ នៅទីនេះគឺ ប្រើពាក្យថា “កសាង និងកម្ទេច” ។ យ៉ាងយូរ

អ្នកទាំងនោះរស់នៅទីនេះ បានបីខែប៉ុណ្ណោះ ឬតិចជាងនេះ ព្រោះតាំងពីបង្កើតមន្ទីរនេះ គឺមានអ្នកទោសស្លាប់ប្រហែលជាងពីរពាន់នាក់ហើយ ក៏ប៉ុន្តែសព្វថ្ងៃ គឺនៅសល់តែពីរបីរយនាក់ប៉ុណ្ណោះ ខ្លះមកបានតែមួយថ្ងៃក៏ត្រូវបានកម្ទេចទៅហើយ ។ មិត្ត ហ៊ឹម បានបញ្ជាក់ប្រាប់ខ្ញុំទៀតថា ឯងគិតមើលដើម្បីចិញ្ចឹមពួកនេះ មិនមែនជាការងាយស្រួលទេ ។ អ្នកទោសមានគ្នាបីរយនាក់ តើមួយថ្ងៃត្រូវស៊ីអស់អង្ករប៉ុន្មាន អង្គការគិតថា ត្រូវកម្ទេចទើបជាការល្អព្រោះ បើទុកក៏មិនចំណេញដកចេញក៏មិនខាតដែរ ។ នេះគឺជាពាក្យស្លោកដែលខ្ញុំបានឮស្ទើរតែរាល់ថ្ងៃទៅហើយពាក្យស្លោកនេះប្រហែលជាត្រូវអង្គការថ្នាក់លើបានដាក់បញ្ជាឲ្យប្រើទូទៅពេញផ្ទៃប្រទេសជាក់ជាពុំខាន ។

## ៤០) ក្បាលមនុស្សម្នាក់ដូរឡេវអាវមួយគ្រាប់

ខ្ញុំបានបង្កើនភាពស្និទ្ធស្នាលជាមួយសន្តិសុខដទៃទៀតដើម្បីឆ្លៀតឱកាសស៊ើបដំណឹងបងប្រុស ក៏ប៉ុន្តែហាក់ដូចជារកម្ដុលនៅបាតទន្លេរហូតដល់ថ្ងៃមួយ ខ្ញុំបានជួបនឹងសាស្ត្រាចារ្យ ឃី លឹមហេង ដែលជាអតីតសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ កាលខ្ញុំរៀននៅវិទ្យាល័យព្រះបាទសុរាម្រិត ។ កាលនៅរៀនខ្ញុំពុំចូលចិត្តលោកគ្រូ ឃី លឹមហេង ទេ ខ្ញុំស្អប់គាត់ដែលបានវាយក្បាលខ្ញុំនឹងបន្ទាត់ធ្វើឲ្យខ្ញុំខ្មាសមិត្តរួមថ្នាក់ ប៉ុន្តែពេលនេះខ្ញុំអាសូរលោកគ្រូខ្លាំងណាស់ ព្រោះលោកគ្រូមានរូបរាងស្គមស្គាំងហើយ ស្លេកស្លាំងដូចអ្នកសុំទាន ឬក៏ដូចពួកនរកនៅស្ថានយមបាល ។

ខ្ញុំនឹកខ្មាសខ្លួនឯងដែលតែងតែមានគំនុំជាមួយលោកគ្រូ ហើយពេលនេះខ្ញុំភ្លេចរឿងរ៉ាវអតីតកាលអស់រលីងដោយសម្លឹងមើលទៅអតីតសាស្ត្រាចារ្យម្នាក់ដែលបានបាត់បង់អស់សេចក្ដីថ្លៃថ្នូរ វិប្បដិសារីនេះស្ថិតជាប់ក្នុងចិត្តខ្ញុំរហូតដល់សព្វថ្ងៃ ។ គ្រាន់តែឃើញខ្ញុំភ្លាមលោកគ្រូបានស្រែកដោយអំណរ ។ ខ្ញុំបានជូនលោកគ្រូនូវដំឡូងដែលខ្ញុំជីកនៅព្រៃ គាត់ទទួលយកដោយស្រេកឃ្លាន ។ លោកគ្រូជាទីគោរព! កាលដើមឡើយជាបុគ្គលដែលមានចំណេះដឹងខ្ពង់ខ្ពស់ទាំងសេចក្ដីថ្លៃថ្នូរ ទាំងសេចក្ដីគោរពពីសិស្សានុសិស្ស និងពីមហាជន ឥឡូវនេះគ្រាន់តែដំឡូងពីរដុំធ្វើឲ្យគាត់ត្រេកអរជាងបានឡានម៉ែសឺដែសមួយទៅទៀត ខ្ញុំចង់យំក៏យំមិនចេញនៅពេលជួបទិដ្ឋភាពបែបនេះ ។ លោកគ្រូទាំងបីនាក់ក៏ប្រាប់ថា បងប្រុសខ្ញុំក៏បានមកដល់ទីនេះដែរ តែគាត់បានស្លាប់ដោយសារជំងឺចុះរាកយ៉ាងខ្លាំង ។ អ្នកទាំងបីបានជួបលោកនាយកបឋមសិក្សា និងសាស្ត្រាចារ្យដែលខ្ញុំស្គាល់ជាច្រើននាក់ទៀត សុទ្ធតែស្លាប់នៅទីនេះទាំងអស់ ។

ខ្ញុំតក់ស្លុតខ្លាំងណាស់ដោយបដិវត្តន៍បានឆក់យកជីវិតសាស្ត្រាចារ្យ វេជ្ជបណ្ឌិតទៅវិញ ។ កំពុងតែជជែកស្រាប់តែ ហ៊ឹម បានស្រែកហៅខ្ញុំឲ្យទៅមើលសន្តិសុខភ្នាល់គ្នាបាញ់ចំពាមកៅស៊ូ ។ មិត្ត ហ៊ឹម បានអូសដៃខ្ញុំឲ្យទៅខាងក្រោយ ក៏ឃើញសន្តិសុខពីរនាក់កំពុងតែលេងល្បែងភ្នាល់ ។ «បើឯងបាញ់ចំក្បាលវាមួយគ្រាប់ អញនឹងឲ្យឡេវអាវមួយ» ។ ពេលនោះសន្តិសុខម្នាក់ក៏យិតចំពាមកៅស៊ូតម្រង់ទៅអ្នកទោសដែលកំពុងតែធ្វើដីលេខមួយ ហើយគ្រាប់ចំពាមក៏ហើរទៅត្រូវក្បាលអ្នកទោសម្នាក់ គាត់ដួលផ្កាប់មុខទៅនឹងដីកំពប់លាមកប្រឡាក់ពេញរាងកាយ ។ ឈ្លបទាំងនោះក៏ស្ទុះទៅទាត់ធាក់អ្នកទោសនោះហើយលើកឲ្យឈរឡើង ។ មិត្ត ហ៊ឹម បានពន្យល់ថា អាខ្មាំងអស់នេះ គង់តែត្រូវកម្ទេចដដែល ដូច្នេះក្បាលរបស់វាមិនមានតម្លៃអ្វីទេគឺថោកជាងឡេវអាវទៅទៀត ។

## ៤១) អ្នកជិះជាន់ពលកម្មអ្នកដទៃ

បើអ្នកដទៃកំពុងធ្វើការហើយយើងបែរជាគេចទៅរកចាប់ត្រីឬរកក្ដាម នោះយើងត្រូវចោទថាជិះជាន់លើពលកម្មអ្នកដទៃ ។ អ្នកដែលធ្វើដូច្នេះត្រូវចាត់ទុកជាខ្មាំងបដិវត្តន៍គឺត្រូវតែកម្ទេច ។ រឿងនេះបានកើតឡើងចំពោះយុវជនពីរនាក់គឺ ទាំ និង ម៉ុន ។ ដោយម៉ែន ជាមនុស្សលោភលន់ និងចង់បានមុខមាត់ដោយសារតែគាត់ត្រូវបានអង្គការចាត់ទុកថា វណ្ណៈអនុធនពុទ្ធសាសនានោះ គាត់តែងតែរកមធ្យោបាយដើម្បីឲ្យអង្គការទុកចិត្តលើរូបគាត់ ។ យើងធ្វើការដោយមិនចេះចប់ ទោះបីជាដល់ខែកញ្ញាដែលជាខែភ្លៀងធ្លាក់ទាំងយប់ទាំងថ្ងៃ ក៏យើងត្រូវបង្ហើយសំណាបដែលបានសាបលើសយ៉ាងច្រើននោះឲ្យអស់ដែរ ។

ព្រមជាមួយនឹងទស្សនកិច្ចរបស់ តាសារុន គណៈតំបន់៣១ គ្រប់វរៈត្រូវធ្វើការពីព្រលឹមទល់ព្រលប់ដោយគ្មានសម្រាកសោះ គឺដើម្បីបំពេញចិត្ត តាសារុន ។ ថ្ងៃនោះ ភ្លៀងបង្អុរយ៉ាងខ្លាំង ម្នាក់ៗរងាររញ៉េរញ៉ៃដែលបានចែកចេញជាកងរែកសំណាប កងពង្រាបដី និងកងស្ទូង ។ តាមធម្មតារគាំងវាយនៅម៉ោងប្រាំ ហើយយើងហូបបាយនៅម៉ោងប្រាំមួយ ។ យើងបន្តការងារចាប់ពីម៉ោងប្រាំបី

ដល់ម៉ោងដប់យប់ ដើម្បីដាំបន្លែដូចជាស្ពៃ ឆៃថាវ ថ្នាំជក់ ក៏ប៉ុន្តែថ្ងៃនេះ ម៉ែន បានចាត់តាំងឲ្យយើងស្ទូងរហូតដល់បង្ហើយសំណាបអស់ ។ រហូតដល់ម៉ោងប្រាំពីរកន្លះទើបស្ទូងហើយ គ្រប់គ្នារងាររណ្តំថ្គាម ដៃក៏ស្ពឹក ជើងធ្ងន់ដើរពុំចង់រួច ។ ស្នូរកញ្ចែរបស់ ម៉ែន ក៏បន្លឺឡើងម្នាក់ៗ ត្រេកអរឥតឧបមានាំគ្នាស្ទុះចេញពីស្រែរត់សំដៅមកជំរំស្រាប់តែពេលនោះ ម៉ែន បានរាប់កម្លាំងយុវជនក៏ឃើញថាបាត់យុវជនពីរនាក់គឺ ទាំ និង ម៉ុន ។ ម៉ែន ផ្ទុះកំហឹងយ៉ាងខ្លាំង ដាក់បញ្ជាឲ្យកងឈ្លបស្វែងរកអ្នកទាំងពីរ ។ ឈ្លបបានរកឃើញអ្នកទាំងពីរនៅក្បែរមាត់ស្ទឹងកំពុងចាប់ត្រី ហើយក៏ចាប់យកមកដោយឲ្យពាក់ត្រណោតត្រីពាក់នឹងកមកបង្ហាញខ្លួនចំពោះមុខមិត្ត ម៉ែន ។ ម៉ែន បានបញ្ជាឲ្យអ្នកទាំងពីរអង្គុយលុតជង្គង់ហើយឱ្យស៊ីត្រីនៅលើដីដូចសត្វឆ្កែរហូតទាល់តែអស់ ។

យប់នោះសមមិត្តផល មិនបាននៅកន្លែងទេ ដោយគាត់ត្រូវទៅប្រជុំនៅកំពង់ឆ្នាំង ហេតុនេះ ម៉ែន បានសម្រេចចិត្តធ្វើទណ្ឌកម្មដ៏ព្រៃផ្សៃនេះ ។ បន្ទាប់ពីស៊ីត្រីរួចហើយ ម៉ែន បង្គាប់ឲ្យចងអ្នកទាំងពីរជាប់នឹងដើមចំបក់ក្បែររោងដើម្បីទុកជាមេរៀនដល់អ្នកដទៃទៀត រយៈពេលពីរថ្ងៃទើបដោះលែង ។ មួយថ្ងៃបន្ទាប់មកទៀត ទាំ ក៏ធ្លាក់ខ្លួនឈឺស្លាប់ទៅ ឯ ម៉ុន ក៏បានក្លាយជាមនុស្សឆ្កួតនិងស្លាប់ប្រហែលកន្លះខែក្រោយមក ។

## ជំពូកទី៦ សំណល់បដិវត្តន៍

### ៤៣) បក្សកុម្មុយនីស្តកម្ពុជា

ចុងឆ្នាំ១៩៧៥ យើងរស់នៅយ៉ាងលំបាកគោកយ៉ាកនៅស្រែសម័យ ។ ស្រូវចាប់ផ្តើមទុំពណ៌លឿងចាស់ប្រាលពេញវាលស្រែគឺជារដូវចម្រូត ។ របបអាហារបានគ្រាន់បើជាងមុន ។ អង្គការបានផ្តល់បាយរឹងមួយថ្ងៃពីរពេល រីឯសម្លក៏មានសាច់ត្រីខ្លះៗ ក៏ប៉ុន្តែសមាជិកយើងជាច្រើនមិនបានរស់នៅដើម្បីបរិភោគអាហារទាំងនេះទេ ព្រោះអ្នកខ្លះបាត់បង់ជីវិតដោយជំងឺរាគ ហើមខ្លួននិងគ្រុនចាញ់ហើយខ្លះទៀតត្រូវបានបញ្ជូនទៅមន្ទីរពេទ្យស្រុកនៅខ្ទង់ពពក រីឯអ្នកខ្លះទៀតត្រូវឡានឡង់រ៉ូវែរដឹកយកទៅបាត់ ។ គ្មានឃើញអ្នកណាម្នាក់វិលមកវិញសោះ ដូច្នេះយើងនៅសល់មិនដល់សែសិបនាក់ទេ ។

ជីវិតរស់នៅដូចជាប្រសើរបន្តិច មេក្រូនៅការដ្ឋានក៏បេះតែបន្តចាក់បទចម្រៀងប្លែកៗ ព្រមទាំងមានភ្លេងជាតិថ្មីផង ។ ភ្លេងជាតិច្រៀងពីការបដិវត្តន៍ដែលប្រកបទៅដោយឈាមក្រហមប្រាលស្រោចសព្វវាលកម្ពុជាមាតុភូមិដែលបានរំដោះប្រជាជនឲ្យផុតពីភាពខ្ញុំគេ និងពន្លឺបដិវត្តន៍ដែលរុងរឿងលើសម័យអង្គរ ។ អង្គការក៏បានយកសម្លៀកបំពាក់ពណ៌ខៀវ និង ស យកមកចែកឲ្យយើងពាក់ ក៏ប៉ុន្តែមិនបានចែកស្បែកជើងកង់ឡានទេ ព្រោះមានតិចពេក គឺបានតែថ្នាក់កម្មាភិបាលតែប៉ុណ្ណោះ ។

ខ្ញុំពុំបានចាំច្បាស់ថ្ងៃខែទេ ក៏ប៉ុន្តែគឺក្នុងឆ្នាំ១៩៧៦ ពេលនោះរដូវច្រូតកាត់ បានកន្លងផុតទៅហើយ យើងក៏បានបរិភោគឆ្អែតពីព្រោះថាក្នុងជង្រុករបស់យើងមានស្រូវពេញតែចំនួនមនុស្សដែលបរិភោគមានចំនួនតិចជាងមុន ។ តាមខ្ញុំស្មាន ក្នុងការដ្ឋានទាំងមូលចំនួនមនុស្សរស់នៅប្រហែលពាក់កណ្តាលតែប៉ុណ្ណោះ ព្រោះពាក់កណ្តាលទៀតបានស្លាប់ដោយគ្រុនចាញ់ បាក់កម្លាំង ទៅរៀនសូត្រ គឺថយពី២.០០០នាក់មកនៅប្រហែល៩០០នាក់ប៉ុណ្ណោះ ។

**(នៅមានត)**

**ឆាយ ស៊ុំឆាត្រ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# ទិដ្ឋភាពសោកសៅនៅជំរំជនភៀសខ្លួន

ខ្ញុំរស់នៅទីក្រុងបាងកក ចន្លោះខែកុម្ភៈ ឆ្នាំ១៩៧៩ ដល់ខែសីហា ឆ្នាំ១៩៨០ ។ ក្នុងនាមជាភរិយាមន្ត្រីទូតសហរដ្ឋអាមេរិក ខ្ញុំមិនអាចទៅធ្វើការនៅកន្លែងផ្សេងទៀត ដែលជាការងារទទួលប្រាក់កម្រៃបានទេ ។ ទន្ទឹមពេលដែលរស់នៅក្នុងទីក្រុងបាងកក ហើយចំពេលដែលស្វាមីរបស់ខ្ញុំបំពេញការងារជាប់២៤ម៉ោងនោះ ខ្ញុំចង់ចំណាយពេលវេលាផ្ទាល់របស់ខ្ញុំដើម្បីបំពេញការងារដែលមានប្រយោជន៍ ទោះបីជាក្នុងនាមជាអ្នកស្ម័គ្រចិត្តក៏ដោយ ។ មិត្តភក្តិជនជាតិអាមេរិកដែលទើបតែស្គាល់គ្នាថ្មីៗរបស់ខ្ញុំម្នាក់ បានជំរុញឲ្យខ្ញុំចូលរួមកម្មវិធីជួយជនភៀសខ្លួនរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។ ខ្ញុំបានទទួលដំណឹងអំពីតម្រូវការជំនួយ និងការងារដែលត្រូវបំពេញនៅជំរំភៀសសឹកនៅជិតកន្លែងស្នាក់នៅរបស់ខ្ញុំនៅផ្លូវរុមវ៉ូឌី ទីក្រុងបាងកក ។ និទាឃរដូវ (មីនា-ឧសភា) ឆ្នាំ១៩៧៩ ខ្ញុំបានចូលធ្វើការជាអ្នកស្ម័គ្រចិត្ត ។ រៀងរាល់បីថ្ងៃក្នុងមួយសប្តាហ៍ ខ្ញុំបម្រើការជាអ្នកស្ម័គ្រចិត្តនៅជំរំលំពីនី ដែលជាជំរុំជនភៀសខ្លួនដ៏ធំ សម្បូរទៅដោយមនុស្សជជែកភាសាផ្សេងគ្នា ស្ថិតនៅកែងផ្លូវសុខុមវីដ និងផ្លូវឡាំង ក្នុងទីក្រុងបាងកកដ៏មមាញឹកមួយនេះ ។

នៅក្នុងជំរំនោះ ជនភៀសខ្លួនត្រូវបានផ្តល់កន្លែងស្នាក់នៅក្រោមដំបូលអាលុយមីញ៉ូម រាងអង្កាញ់ ហើយមានជញ្ជាំង និងទ្វារធ្វើពីក្តារឈើកញ្ចាស់ ។ កាលនោះ ដំបូលអាលុយមីញ៉ូមបានធ្វើឲ្យកំដៅព្រះអាទិត្យរឹតតែក្តៅ ។ នៅក្នុងជំរុំមើលទៅដូចជាបន្ទាយធំនោះ មានពន្លឺថ្ងៃចាំងចូលព្រិលៗ អាកាសធាតុក្តៅ ហើយទិដ្ឋភាពខាងក្នុងគួរឲ្យអសោចន៍ ។ ជំរំនោះមិនមែនជាកន្លែងគាប់ចិត្តធ្វើការងារមួយថ្ងៃ រួចហើយរង់ចាំលទ្ធផលសម្រេចជាច្រើនខែនោះ



ជនភៀសខ្លួនខ្មែរនៅជំរំស្រះកែវ ប្រទេសថៃ ក្នុងឆ្នាំ១៩៧៩ ។ រូបថតរបស់អ្នកនិពន្ធ ។

ឡើយ ។

នៅក្នុងជំរំ គំនរសំរាមរលួយដែលមាននៅហ្នឹងកន្លែង និងក្លិនស្អុយនៃសំរាមនោះ កើតឡើងដោយសារកម្តៅ និងសំណើម ។ សត្វកន្លាតតំបន់អាស៊ីពណ៌ខ្មៅដ៏ធំ និងសត្វពស់ដ៏វែង បានធ្វើឲ្យគ្រួសារជាច្រើនខ្លាចរអារបោះទីលំនៅ ។ អំឡុងពេលដែលខ្ញុំធ្វើដំណើរទៅកាន់ជំរំលំពីនី ខ្ញុំអង្កេតឃើញថា យើងត្រូវចំណាយពេលគួរឲ្យធុញទ្រាន់ជាច្រើនម៉ោង ជាច្រើនថ្ងៃ ។ មនុស្សមួយចំនួនលេងបាល់ អានកាសែត ឬជជែកជាមួយនឹងគ្រួសារ និងមិត្តភក្តិ ។ កុមារលេងជាមួយនឹងតុក្កតា ដែលធ្វើពីស្លឹកចេក ឬវាយបាលជាមួយនឹងដំបង ឬវាយកំប៉ុង ។ ការរស់នៅតែឯង ឬរស់នៅបែបឯកជនភាព គឺជារឿងកើតឡើងដោយកម្រនៅក្នុងជំរំ ។

ជំរំលំពីនីបានផ្តល់ជម្រកដល់ជនភៀសខ្លួនរាប់រយនាក់មកពីប្រទេសលាវ ប្រទេសភូមា ប្រទេសកម្ពុជា និងប្រជាជនវៀតណាមមួយចំនួនតូច ។ ជំរំនោះបានផ្តល់ទីជម្រក នៅពេលដែលជនភៀសខ្លួនរង់ចាំការអនុញ្ញាតពិនិត្យសុខភាព ដើម្បីធ្វើចំណាកស្រុកទៅកាន់សហរដ្ឋអាមេរិក អូស្ត្រាលី និងប្រទេសដទៃនៅទ្វីបអឺរ៉ុប ។

នៅពេលដែលខ្ញុំនៅជំរំ ខ្ញុំបានបង្រៀនសន្ទនាភាសាអង់គ្លេសដល់អ្នកដែលទៅរស់នៅប្រទេសអាមេរិក ។ មានថ្ងៃខ្លះ ខ្ញុំបរិច្ចាគស្បែកជើង និងសម្លៀកបំពាក់ផ្សេងៗជាច្រើន ។ ជនភៀសខ្លួនដែលធ្វើដំណើរនៅរដូវរងារប្រាកដជាត្រូវការអាវរងាធំៗជាក់ជាមិនខាន ។ ខ្ញុំបានណែនាំជនភៀសខ្លួនអំពីរបៀបធ្វើដំណើរតាមផ្លូវអាកាសទៅកាន់ប្រទេសអឺរ៉ុប ឬអាមេរិកខាងជើង ។ សម្រាប់ជនភៀសខ្លួនទាំងនោះ នេះនឹងក្លាយជាបទពិសោធន៍ធ្វើដំណើរតាមផ្លូវអាកាសលើកដំបូង ។ គោលបំណងនៃការណែនាំ ជនភៀសខ្លួនគឺដើម្បីជួយជនទាំងនោះយល់ដឹងអំពីអ្វីដែលនឹងជួបប្រទះនៅពេលធ្វើដំណើរតាមផ្លូវអាកាសជួយកាត់បន្ថយការភ័យខ្លាច និងយល់ដឹងអំពីការធ្វើដំណើរតាមផ្លូវអាកាសលើកដំបូង ។ មុនពេលផ្តល់ការណែនាំនេះ ខ្ញុំចង់ចាំពាក្យសម្តីរបស់អ្នកណែនាំជនភៀសខ្លួនទាំងនោះថា ការអប់រំនេះមានសារសំខាន់ចំពោះការធ្វើដំណើរប្រកបដោយសុវត្ថិភាព ។ មានការគួរឲ្យអង្កេតដែលថា ជាច្រើនខែកន្លងមកនេះ ជនភៀសខ្លួនដែលនឹងធ្វើដំណើរតាមយន្តហោះ មិនបានយល់ដឹងថា មានបន្ទប់ទឹកនៅលើយន្តហោះនោះឡើយ ។ ជនភៀសខ្លួនមួយចំនួនបានប៉ុនប៉ងបន្ទាត់ភ្លើងចម្អិនអាហារនៅលើយន្តហោះ ។ ជនភៀសខ្លួនទាំងនោះបានញាត់កាកសំណល់សំរាម និងលាមកក្រោមកៅអីអង្គុយរបស់ខ្លួន ។ ទាំងនោះបានបង្កការខូចខាតជាច្រើនដល់យន្តហោះ ។

## ព្រំដែនកម្ពុជា-ថៃ

ជំរំស្រះកែវ ស្ថិតនៅតាមព្រំដែនកម្ពុជា-ថៃ ដោយត្រូវធ្វើដំណើរពីរឬបីម៉ោងពីទីក្រុងបាងកក ឆ្ពោះទៅទិសខាងកើត ។ ជំរំនោះត្រូវបានរៀបចំឡើងយ៉ាងប្រញាប់ប្រញាល់ដោយរដ្ឋាភិបាលថៃ ដើម្បីផ្តល់ទីជម្រកជាបន្ទាន់ដល់ជនភៀសខ្លួនខ្មែរដែលស្វែងរកការការពារ និងសិទ្ធិជ្រកកោន ។ ជំរំនោះមានទីតាំងនៅក្បែរទីប្រជុំជនស្រះកែវដ៏តូច ហើយស្ថិតនៅលើផ្ទៃដី ១៦០ពាន់ម៉ែត្រក្រឡា ដែលប្រើសម្រាប់ធ្វើស្រែ ។ មុនពេលបង្កើតជំរំស្រះកែវ ជនភៀសខ្លួនជាច្រើនត្រូវបានផ្តល់ទីជម្រកក្បែរព្រំដែនកម្ពុជា-ថៃ ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រាប់ផ្លោងបានបង្ខំឲ្យជនភៀសខ្លួន ធ្វើដំណើរថ្មើរជើងរាប់សិបគីឡូម៉ែត្រ ។ នោះគឺជាពេលវេលាដ៏គ្រោះថ្នាក់សម្រាប់ប្រជាជនកម្ពុជា ។ ពាក់កណ្តាលទសវត្សរ៍៧០ មេដឹកនាំចលនាកុម្មុយនីស្តកម្ពុជា ប៉ុល ពត ត្រូវបានស្គាល់នៅពេលដែលខ្មែរក្រហមបានត្រួតត្រាប្រទេសកម្ពុជា ។ ប្រជាជនកម្ពុជាបានជួបប្រទះការគ្រប់គ្រងដ៏ឃោរឃៅរបស់ប៉ុលពត ។ ប្រជាជនត្រូវបានសម្លាប់យ៉ាងសាហាវ គ្រួសារបែកបាក់គ្នា ហើយប្រជាជនមួយចំនួនត្រូវបានបញ្ជូនទៅជំរំលត់ដំ ។ ដូច្នេះហើយ ប្រជាជនកម្ពុជារាប់ពាន់នាក់ទទួលរងទុក្ខវេទនា ។ ដោយសារ ប៉ុល ពត ប្រើចំណាត់ការដ៏សាហាវប្រឆាំងទៅនឹងប្រជាជនកម្ពុជា អំពើប្រល័យពូជសាសន៍ត្រូវបានមើលឃើញ ថាជាគោលបំណងនៃរបបខ្មែរក្រហម ។ ប្រជាជនកម្ពុជារាប់សិបម៉ឺននាក់ បានស្វែងរកជម្រកនៅប្រទេសថៃ ។ ប្រជាជនកម្ពុជាទាំងនោះ បានមកដល់ជំរំដោយគ្មានឥវ៉ាន់អ្វីក្រៅពីសំលៀកបំពាក់មួយបន្ទិចនៅលើខ្លួន ។ នៅពេលដែលសង្គ្រាមបានបញ្ចប់ ប្រជាជនកម្ពុជាជាងពីរលាននាក់បានស្លាប់ ។

## ការចងចាំរបស់ខ្ញុំ ចន្លោះខែវិច្ឆិកា ដល់ខែធ្នូឆ្នាំ១៩៧៩

ភ្លាមៗបន្ទាប់ពីប្រជាជនកម្ពុជាជាច្រើនបានចូលមកដល់ជំរំ ខ្ញុំក្នុងចំណោមអ្នកដទៃមកពីស្ថានទូតអាមេរិក បានធ្វើការងារស្ម័គ្រ

ចិត្តជួយដល់អ្នកជម្លៀសទាំងនោះ ដែលមកដល់ជំរំស្រះកែវដំបូង ។

មួយយប់មុនខ្ញុំធ្វើដំណើរទៅកាន់ជំរំស្រះកែវ ខ្ញុំបានចងចាំថា ខ្ញុំបានជួបប្រទះផលវិបាកនៅពេលដំណេក ។ ខ្ញុំបានឮសាច់រឿងគួរឲ្យភ័យខ្លាចពីអ្នកដទៃដែលបាននៅទីនោះ ។ សាច់រឿងនោះហាក់បីដូចជា មិនអាចនឹកស្មានបាននោះឡើយ ។

នៅថ្ងៃដំបូង ជំរំស្រះកែវបានផ្តល់កន្លែងស្នាក់នៅ និងអាហារដល់ប្រជាជនកម្ពុជាជិតពីរម៉ឺនប្រាំបួនពាន់នាក់ដែលបានរត់ភៀសខ្លួនទៅប្រទេសថៃដើម្បីសុវត្ថិភាព ។ ខ្ញុំមិនអាចស្រមៃឃើញ ថាតើប្រជាជន ទាំងនោះត្រូវបានជួយយ៉ាងដូចម្តេច ។

នៅពេលដែលខ្ញុំដេកនៅលើគ្រែនោះ ម៉ាស៊ីនត្រជាក់បានបញ្ចេញខ្យល់ត្រជាក់នៅក្នុងអគារ ដែលស្ថានទូតអាមេរិកបានជួលដែលមានគ្រែដេកចំនួនពីរ ទោះបីជាមានសំឡេងរំខានក៏ដោយ ។

ខ្ញុំអាចឮរ៉ឺម៉កកង់បី ដែលបើកនៅក្រោមបង្អួចគ្រែដេករបស់ខ្ញុំដែលកំពុងធ្វើដំណើរចុះផ្លូវ សូរាមរូឌី ។ ខ្ញុំដេកប្រែខ្លួនទៅមកៗ ។ ខ្ញុំមានកង្វល់ក្នុងចិត្តថា តើខ្ញុំនឹងឃើញអ្វី នៅថ្ងៃបន្ទាប់ នៅជំរំ? តើខ្ញុំនឹងក្លាយជាជំនួយឬក៏ជាការរាំងស្ទះដល់ការងារ? តើខ្ញុំនឹងមានអារម្មណ៍រឹងមាំ ធ្វើការងារអ្វីនៅចំពោះមុខខ្ញុំនោះទេ? ខ្ញុំគិតថា ខ្ញុំមិនបានដេកលក់នៅយប់នោះឡើយ ។

នៅពេលនោះ ខ្ញុំនៅក្មេង ហើយជាស្ត្រីអាមេរិកអាយុ២៧ឆ្នាំដ៏ឆោតល្ងង់ ។ ខ្ញុំមិនបានយល់ដឹងទាល់តែសោះអំពីនយោបាយដែលធ្វើឲ្យប៉ះពាល់ដល់ប្រជាជន វប្បធម៌ និងប្រទេសជាតិ ។ ការធ្វើការងារ ជាអ្នកស្ម័គ្រចិត្តនៅជំរំស្រះកែវ នៅជំរំប្រទេសថៃ-កម្ពុជា បានបើកភ្នែករបស់ខ្ញុំឲ្យយល់ដឹងអំពីការឈឺ ចាប់ ។

បន្ទាប់ពីធ្វើដំណើរអស់រយៈពេលបួនម៉ោងពីទីក្រុងបាងកកមក រថយន្តក្រុងរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានមកដល់ជំរំស្រះកែវ ។ តាមរយៈបង្អួចរថយន្តក្រុង ខ្ញុំឃើញបុគ្គលិកនៅជំរំដែលកំពុងតម្លើងរនាំងសំពត់តង់ ។ ធុងទឹកដែកធំៗពណ៌ប្រផេះ តម្រៀបនៅពាសពេញលើដីចាំប្រកទឹក ហើយមនុស្សជាច្រើនដែលមានទឹកមុខសោះកក្រោះ អង្គុយលើដីជាក្រុមតូចៗ ។ ទឹកមុខរបស់ប្រជាជនទាំងនោះ មើលទៅហាក់បីដូចជាកំពុងជិតបាត់បង់ជីវិត ឬអស់ក្តីសង្ឃឹម ។ នោះគឺជាទិដ្ឋភាពដ៏សោកសៅ ។

មិនយូរប៉ុន្មានបន្ទាប់ពីមកដល់ជំរំ ខ្ញុំបានកត់សម្គាល់អំពីក្លិនស្អុយ ព្រមទាំងរបស់អ្វីមួយពណ៌ខ្មៅ ដែលធ្លាក់ចុះពីលើមេឃមក ។ ខ្ញុំបានសួរអំពីរឿងនោះ ។ បុគ្គលិកនៅជំរំបានប្រាប់ខ្ញុំថា ពណ៌ខ្មៅនេះ គឺជាផេះដែលហោះចេញពីភ្លើងកន្លែងបូជាសព ។ គាត់បានពន្យល់ខ្ញុំថា ជនភៀសខ្លួនបានស្លាប់នៅក្នុងជំរំយ៉ាងឆាប់រហ័ស រហូតដល់យើងមិនមានពេលវេលាកប់សាកសពទាំងនោះ នៅក្នុងរណ្តៅតែមួយ ។ ការព្រួយបារម្ភជាចំបងនៅគ្រានោះ គឺសុខភាពរបស់អ្នកដែលព្យាយាមរស់ ។ ខ្ញុំធំក្លិនឈ្ងៀមសាច់មនុស្ស ។

នៅពេលដែលខ្ញុំដើរកាត់ជំរំ ខ្ញុំមានអារម្មណ៍ថា ព្រះអាទិត្យកំពុងតែចាំងកម្តៅដាក់ខ្ញុំ ។ កម្តៅនោះ បានបង្កផលវិបាកដល់មនុស្សគ្រប់គ្នា ។ ក្លិនស្អុយ សំណើម និងទឹកដោតជាំនៅលើដី ហើយទិដ្ឋភាព នៃការរងទុក្ខមាននៅគ្រប់ទីកន្លែង ។

នៅថ្ងៃនោះ និងថ្ងៃបន្ទាប់ ខ្ញុំឃើញទារករូបរាងស្គមខ្វះអាហារ និងកុមារមានពោះកំប៉ោង និងមុខផត ហាក់បីដូចជាគ្មានវិញ្ញាណ ។ ខ្ញុំឃើញទារក និងកុមារតូចៗយំដោយគួរអាណិតអាសូរ ។ ខ្ញុំបានឃើញមនុស្ស បាត់បង់ដៃជើងដោយសារមីនឬ ដោយសារតែរោគឆ្លងបង្កឡើងដោយជំងឺ ។ ខ្ញុំឃើញបុរសចំណាស់ និងស្ត្រីចំណាស់ខ្វះអាហារូបត្ថម្ភ ។

នៅពេលដែលខ្ញុំបានមកដល់ស្រះកែវជាមួយនឹងអ្នកស្ម័គ្រចិត្តដទៃ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅមន្ទីរពេទ្យរបស់អង្គការវើលវីស៊ិន ។ កាលគ្រានោះ ខ្ញុំមិនមានការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រនោះទេ ។ គ្រូពេទ្យម្នាក់បានបង្ហាញខ្ញុំអំពីរបៀបបំបៅទារកតូចដែលខ្ញុំមិនធ្លាប់ឃើញជាមួយនឹងទឹកដោះគោ ។ គ្រូពេទ្យម្នាក់នោះបានបង្រៀនខ្ញុំអំពីការបញ្ចូកទឹកដោះគោតាមទុយយូតូចចូលក្នុងមាត់ទារក ។ ខ្ញុំបានមើលឃើញយ៉ាងច្បាស់ថា ទារកតូចម្នាក់នោះមិនមានកម្លាំង ហើយទន់ខ្សោយ រហូតដល់មិនអាចជញ្ជក់បាន ។ ខ្ញុំបានបីទារកនោះដោយប្រុងប្រយ័ត្ន ហើយបំបៅបន្ទាប់មកបន្តទៅទារកដទៃ ។ ឪពុកម្តាយទារកទាំងនោះឈឺធ្ងន់រហូតដល់មិនអាចថែទាំកូនរបស់ខ្លួនបាន ។ ទារកទាំងនោះបានក្លាយជាទារកកំព្រា ហើយរងរបួសនៅក្នុងមន្ទីរពេទ្យរបស់អង្គការវើលវីស៊ិន ។ នៅពេលដែលខ្ញុំគិតដល់គ្រានោះ នាពេលបច្ចុប្បន្នខ្ញុំឆ្ងល់ថា តើខ្ញុំបានធ្វើអ្វី ។

នៅក្នុងមន្ទីរពេទ្យរបស់អង្គការវើលវីស៊ិន ខ្ញុំបានឃើញរឿងជាច្រើនដែលធ្វើឲ្យខ្ញុំរន្ធត់ អ្នកជំងឺនិងអ្នកស្លាប់ដេកដួលលើកន្ទេលដោយឥតវិញ្ញាណ ហើយមនុស្សមួយចំនួនដេកលើលាមករង់ចាំការព្យាបាល ។ អ្នកខ្លះត្រូវបានចាក់សេរ៉ូមរួចរាល់ ។ គួរឲ្យភ្ញាក់ផ្អើលនោះទៀត សេរ៉ូមត្រូវបានចងភ្ជាប់ទៅនឹងបំពង់ឫស្សីដែលដោតជាប់នឹងដី ហើយចងព្យួរលើអ្នកជំងឺ ។ នេះគឺជាការព្យាបាលតាមបែបវេជ្ជសាស្ត្រ ។ វិធីសាស្ត្រអ្វីក៏ដោយដែលចាត់ទុកថា មានប្រសិទ្ធភាពលឿនត្រូវបានប្រើប្រាស់កាលគ្រានោះ ។

ការវ្លួតទឹកឲ្យអ្នកជំងឺបុរស ស្ត្រី និងកុមារដែលទន់ខ្សោយគឺជាការងារផ្សេងមួយទៀតដែលផ្តល់ឲ្យខ្ញុំ ។ អ្នកជំងឺទាំងអស់នៅក្នុងមន្ទីរពេទ្យ ដេកនៅលើកន្ទេលផ្ទាល់ដីក្បែរៗគ្នា ក្រោមសំពត់តង់ធំ ដែលមានច្រកចូលបួន ។ អ្នកជំងឺដែលខ្ញុំមើលថែទាំ កើតរោគរាកមួល ហើយប្រឡាក់ទៅដោយលាមក ។ ខ្ញុំគិតថា «តើខ្ញុំអាចធ្វើការងារទាំងនោះដោយរបៀបណា?» ។ ខ្ញុំត្រូវបានផ្តល់នូវទឹកមួយកន្ទន់ ក្រណាត់ស្អាតមួយដុំ ហើយបានប្រាប់កន្លែងដែលខ្ញុំអាចរកក្រណាត់ និងទឹកបន្ថែមនៅពេលដែលខ្ញុំត្រូវការ ។ ខ្ញុំចងចាំការធ្វើដំណើរកាត់ដីភក់ ដើម្បីទៅដងទឹកពីធុងទឹកដែកដ៏ធំនៅក្បែរនោះ ។

ខ្ញុំនឹងមិនភ្លេចមនុស្សម្នាក់ដែលខ្ញុំមើលថែនោះឡើយ ។ គាត់ជាបុរសចំណាស់មានរូបរាងស្គម ដែលដេកលើកន្ទេលក្រាលផ្ទាល់ដីនៅក្នុងមន្ទីរពេទ្យនោះ ។ សម្លៀកបំពាក់តែមួយប៉ុណ្ណោះរបស់គាត់ គឺជាក្រណាត់ប្រឡាក់ស្អិត ដែលរំលេចឆ្អឹងស្គមចេញឆ្អឹង ហើយគ្របរហូតដល់ជង្គង់ ។ ខ្ញុំចាប់ផ្តើមសម្អាត គាត់ចាប់ពីក្បាលចុះក្រោម ។ នៅពេលដែលខ្ញុំធ្វើដូច្នេះ គាត់បានញញឹមដាក់ខ្ញុំដោយទទួលស្គាល់ការងារដែលខ្ញុំកំពុងធ្វើ ។ ខ្ញុំបានសម្អាតរាងកាយគាត់ ស្របពេលដែលខ្ញុំហូរទឹកភ្នែកមកជាមួយ ហើយខ្ញុំបានគិតអំពីអ្នកដទៃដែលត្រូវការការថែទាំ និងក្តីមេត្តា ។

នៅពេលដែលខ្ញុំជិះរថយន្តក្រុងត្រឡប់ទៅផ្ទះនៅទីក្រុងបាងកក នៅយប់ដំបូង ខ្ញុំមានអារម្មណ៍នឿយហត់ ។ រាងកាយទាំងមូលរបស់ខ្ញុំមានការឈឺចុកចាប់ ។ ខ្ញុំប្រឡាក់ ហើយមានក្លិនស្អុយ និងចង់ងូតទឹកក្តៅឲ្យបានយូរ ។ អំឡុងពេលធ្វើដំណើរយ៉ាងយូរនោះ ខ្ញុំគិតដល់ការសម្អាតកុមារ ដែលមានរាងកាយស្គមស្គាំង មានសត្វចៃនៅលើក្បាល ហើយកើតជំងឺរមាស់ ។ ខ្ញុំគិតអំពីមនុស្សដែលស្ថិតនៅក្រោមផ្សែងពណ៌ប្រផេះដែលគួចនៅក្នុងខ្យល់ចេញពីកន្លែងដុតខ្មោច ហើយបានមើលឃើញទឹកមុខរបស់ប្រជាជនកម្ពុជាដែលឆ្លុះបញ្ចាំងអំពីការភ័យខ្លាច ។ តាមរយៈបទពិសោធរបស់ខ្ញុំនៅជំរំស្រះកែវ ខ្ញុំបានបាត់បង់ការមិនយល់ដឹង និងភាពអវិជ្ជាដែលមាននៅក្នុងគំនិតរបស់ខ្ញុំ ។ ខ្ញុំបានទទួលអ្វីមួយដែលមានន័យយ៉ាងជ្រាលជ្រៅដល់ខ្ញុំ ។ ខ្ញុំដឹងថា ខ្ញុំបានធ្វើការកែប្រែដល់ជីវិតអ្នកដែលខ្ញុំបានជួយទាំងនោះ ។ ខ្ញុំមានជំនឿយ៉ាងមុតមាំក្នុងចិត្តដូចជា «ចូរយើងចែករំលែកព្រះធម៌ ប្រសិនបើចាំបាច់» ។

សេចក្តីដកស្រង់ខាងក្រោមយកចេញពីសំបុត្រ ដែលខ្ញុំសរសេរនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៩ បន្ទាប់ពីខ្ញុំបានធ្វើដំណើរទៅកាន់ជំរំស្រះកែវ ។ ខ្ញុំបានសរសេរសំបុត្រនេះទៅម្តាយរបស់ខ្ញុំនៅទីក្រុងសានហ្វ្រាន់ស៊ីស្កូ ដើម្បីប្រាប់គាត់អំពីបទពិសោធរបស់ខ្ញុំ ហើយស្នើសុំឲ្យគាត់ចែករំលែកព័ត៌មានអំពីការងារល្អៗដែលអង្គការវើលវីស៊ិនបានធ្វើ ។ ខ្ញុំមានការរីករាយដែលទទួលដំណឹងថា គ្រួសាររបស់ខ្ញុំនៅសហរដ្ឋអាមេរិក បានធ្វើការបរិច្ចាគសប្បុរសដល់ការងាររបស់អង្គការវើលវីស៊ិន នៅអាស៊ីអាគ្នេយ៍ ។

«យើងបានមកដល់ជំរំជនភៀសខ្លួននៅម៉ោង១១ព្រឹក ។ បន្ទាប់មក យើងត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងមន្ទីរពេទ្យគ្របដោយសំពត់តង់ ។ ខ្ញុំបានងូតទឹក និងសម្អាតអ្នកជំងឺ ដែលរាករុសផ្តល់ថ្នាំពេទ្យតាមវេជ្ជបណ្ឌិតបង្គាប់ ផ្តល់ទឹកជាទៀងទាត់ដល់ប្រជាជនដែលបាត់បង់ជាតិទឹកក្នុងខ្លួន ផ្តល់ទឹកបន្ថែម និងលាងសម្អាតសក់ដោយប្រើសាប៊ូកក់សក់សម្លាប់ចៃ និងកំចាត់ជំងឺរមាស់ ។ មនុស្សជាច្រើននៅក្នុងជំរុំនេះបានស្លាប់ជារៀងរាល់ថ្ងៃ ហើយខ្ញុំបានឃើញរណ្តៅសាកសពនៅក្បែរនោះ ។ ជំងឺខ្វះអាហារូបត្ថម្ភ និងជំងឺឆ្លងកើតឡើងពាសពេញកន្លែង ។ ប្រជាជនដ៏គួរឲ្យអាណិតអាសូរទាំងនេះ បានទទួលរងការឈឺចាប់យ៉ាងច្រើន ។

ខ្ញុំបានងូតទឹកមនុស្សជាច្រើនដែលមានដៃដូចមែកឈើ ។ ខ្ញុំត្រូវតែសំអាតពួកគេថ្នមៗ ដោយខ្ញុំបារម្ភថាឆ្អឹងពួកគេនឹងបាក់ ។ ខ្ញុំបានងូតទឹកឲ្យកុមារជាច្រើនដែលកើតជំងឺគ្រុនញាក់ ដោយសារជំងឺគ្រុនចាញ់ ។ មនុស្សជាច្រើនមិនអាចហូបអាហាររឹងបាន ហើយត្រូវការព្យួរសេរ៉ូម ដែលចងព្យួរភ្ជាប់ទៅនឹងដងឫស្សី ។ មន្ទីរពេទ្យមានលក្ខណៈខុសប្លែកគ្នាពីជីវភាពរស់នៅក្នុងជំរំជនភៀស

ខ្លួន ។ មានអ្នកជំងឺជាច្រើនរង់ចាំការថែទាំ ប៉ុន្តែមានគ្រូពេទ្យមួយចំនួនតូចប៉ុណ្ណោះនៅប្រចាំការ ។

ខ្ញុំយំនៅពេលដែលខ្ញុំសម្អាតកុមារដ៏តូចដែលបាត់បង់ស្មារតី ហើយខ្ញុំត្រូវទប់ទឹកភ្នែកខ្លួនឯង ។ ប៉ុន្តែបន្ទាប់ពីនោះមក ខ្ញុំបន្តធ្វើការងាររបស់ខ្ញុំដូចជាអ្នកដទៃ ។ ខ្ញុំបានជួបជនជាតិអាមេរិកាំង អង់គ្លេស បារាំង អូស្ត្រាលី និងអាល្លឺម៉ង់ ជាច្រើនដែលប្រឹងប្រែងធ្វើការងារដើម្បីរៀបចំសណ្តាប់ធ្នាប់នៅជំរំ និងដើម្បីសម្រេចការងារទាំងអស់ ។ ប៉ុន្តែតើអ្នកត្រូវធ្វើយ៉ាងដូចម្តេច? ប្រជាជនពីរម៉ឺនប្រាំពាន់នាក់ អង្គការវើលវីស៊ិន អង្គការជំនួយសង្គ្រោះរបស់កាតូលិកសហរដ្ឋអាមេរិក អង្គការសម្ព័ន្ធភាពបុព្វជិតគ្រិស្ត និងអង្គការកាកបាទក្រហម គឺជាអង្គការមួយចំនួនតូចក្នុងចំណោមអង្គការ ដែលផ្គត់ផ្គង់គ្រូពេទ្យ និងអ្នកជំនាញដទៃ ។ ឧត្តមស្នងការអង្គសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានបង្កើតជំរំ ហើយបុគ្គលិកទាំងនោះមានចារិតល្អ» ។

ដោយសារខ្ញុំមានបទពិសោធន៍នៅស្រះកែវ ខ្ញុំបានចិញ្ចឹមកូនស្រីពីរនាក់រហូតដល់ពេញវ័យ ហើយបានឃើញចៅបីនាក់ចាប់កំណើត និងបានទទួលការបណ្តុះបណ្តាលផ្នែកថែទាំដ៏មានតម្លៃ ។ ខ្ញុំមានសំណាងដែលបានរស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ អឺរ៉ុប អាហ្វ្រិក និងតំបន់មជ្ឈិមបូព៌ា បានធ្វើការនិងថែទាំអ្នកជំងឺអស់រយៈពេល១០ឆ្នាំកន្លងមកនេះ ហើយបានរីករាយនឹងអាពាហ៍ពិពាហ៍ជាមួយស្វាមីដ៏ល្អអស់រយៈពេលជាង៣៨ឆ្នាំ ។ ខ្ញុំពិតជាអរគុណចំពោះមេរៀនជីវិតដែលបានបង្ហាញ និងបង្រៀនដល់រូបខ្ញុំ ។

ខ្ញុំបានគិតច្រើនម៉ោងនៅក្នុងជីវិតរបស់ខ្ញុំ អំពីបទពិសោធនៅជំរំស្រះកែវ ។ ខ្ញុំបានគិតអំពីអំពើអយុត្តិធម៌នៅក្នុងសង្គ្រាម និងការស្អប់ខ្ពើម ដែលមនុស្សមានចំពោះជនរួមជាតិរបស់ខ្លួន ។ ខ្ញុំបានគិត អំពីការដែលប្រជាជនទាំងអស់សក្តិសមទទួលបានការសណ្តោសប្រណី ការថែទាំ និងក្តីមេត្តា ។ ខ្ញុំបានគិត អំពីអ្វីជាការទទួលពរជ័យនៅពេលទទួលបានក្តីស្រឡាញ់ ។

ពិភពលោក គឺជាកន្លែងមួយដ៏ធំ ដែលពោរពេញទៅដោយការឈឺចាប់ និងឱកាសជាច្រើន ដើម្បីបំបាត់ការឈឺចាប់ និងទុក្ខព្រួយ ។ ខ្ញុំបានសម្រេចចិត្តប៉ុន្មានឆ្នាំកន្លងមកនេះ ថាខ្ញុំនឹងខំប្រឹងធ្វើឲ្យពិភពលោកប្រសើរឡើង សូម្បីតែខ្ញុំមានតែម្នាក់ឯងក៏ដោយ ។

បាវចនាក្នុងជីវិតរបស់ខ្ញុំ «វាជាការប្រសើរដែលត្រូវដុតបំភ្លឺទៀនជាជាងដាក់បណ្តាសារដល់ភាពងងឹត» ។ **លីន ចយ**

# ដំណឹងស្វែងរកគ្រួសារ



ខ្ញុំបាទឈ្មោះ ញ៉ានស៊ី ធ្វើការនៅក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ សូមប្រកាសរកឈ្មោះ អៀរ អៀង ភេទប្រុស អាយុ៤២ឆ្នាំ កើតឆ្នាំ១៩៣៣ នៅភូមិត្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ មុនឆ្នាំ១៩៧៥ អៀង ជានាវិក បម្រើការងារនៅកប៉ាល់ក្រុមហ៊ុនមួយនៅប្រទេសសិង្ហបុរី ។ ក្រោយមក អៀង បានមករស់នៅសង្កាត់លេខ៣ ក្រុងភ្នំពេញ ។ អៀង បាត់ខ្លួនក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅស្រុកកំពង់ត្រាច ខេត្តកំពត ។ តាមដំណឹងពីប្រជាជនថា អៀង បានត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ព្រោះបានប្រទះឃើញគាត់នៅតាមផ្លូវក្នុងស្រុកកំពង់ត្រាចខេត្តកំពត ។ ក្រោយឆ្នាំ១៩៧៩ ប្រពន្ធ និងកូន អៀង បានទៅរស់នៅប្រទេសអាល្លឺម៉ង់រហូតមកដល់សព្វថ្ងៃនេះ ។ ប្រសិនបើបងប្អូនណាបានស្គាល់ ឬឮឈ្មោះ អៀង សូមទាក់ទងមកខ្ញុំបាទតាមរយៈអាសយដ្ឋានលេខ៤៧៦G មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទលេខ ០១២ ៩៥៨ ៥៤៦ អ៊ីម៉ែល: nhansy04@yahoo.com ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ។

**សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 166, October 2013 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.